

# ពលករ កុមារ នៅសិប្បកម្មឥដ្ឋ

## មូលហេតុ និង ផលវិបាក

ការសិក្សាស្រាវជ្រាវសំរាប់យុទ្ធនាការប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរ
បំផុតនៃពលកម្មកុមារនៅកម្ពុជា

ខែសីហា ឆ្នាំ ២០០៧

ដោយ បណ្ឌិត ប៉ូច ប៊ុណ្ណាក់

នាយកនៃមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីប្រជាជននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

លីកាដូ

LICADHO

World Vision

# ពលករកុមារនៅសិប្បកម្មឡឥដ្ឋ
# មូលហេតុនិងផលវិបាក

## ការសិក្សាស្រាវជ្រាវ សំរាប់យុទ្ធនាការ
## ប្រយុទ្ធប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារកម្ពុជា

អង្គការលីកាដូ និង អង្គការទស្សនៈពិភពលោកកម្ពុជា

ខែសីហា ឆ្នាំ២០០៧

(បកប្រែជាភាសាខ្មែរ នៅខែឧសភា ឆ្នាំ២០០៨)

ដោយ បណ្ឌិត ប៉ូច ប៊ុណ្ណាក់
នាយកនៃមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីប្រជាជន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# មាតិកា


មាតិកា---------------------------------------------------------- i

បញ្ជីតារាង ------------------------------------------------------ iv

បញ្ជីក្រាហ្វិក ------------------------------------------------------v

សេចក្តីសង្ខេប ---------------------------------------------------- vi

សេចក្តីថ្លែងអំណរគុណ ---------------------------------------------- xiii

ជំពូកទី១: សេចក្តីផ្តើម ---------------------------------------------- ១

គោលបំណងនៃការសិក្សា------------------------------------------- ១

ជំពូកទី២: ការពិនិត្យមើលឡើងវិញនូវឯកសារ -------------------------------- ២

១. ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ----------------------------- ២

២. ហេតុផលនាំអោយមានពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋ------------------------៤

៣. ផលប៉ះពាល់នៃពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋទៅលើការអភិវឌ្ឍន៍របស់កុមារ -------- ៦

ជំពូកទី៣: វិធីសាស្ត្រស្រាវជ្រាវ ---------------------------------------------៩

១. ការជ្រើសរើសសំណាក និងសំណាក --------------------------------------៩

១.១ សំណាកពលករកុមារ ---------------------------------------------៩

១.២ សំណាកមាតាបិតារបស់ពលករកុមារ ------------------------------ ១០

១.៣ សំណាកម្ចាស់ ឬមេការសិប្បកម្ម ---------------------------------- ១០

២. ឧបករណ៍ស្រាវជ្រាវ---------------------------------------------- ១០

៣. ការប្រមូលទិន្នន័យ ----------------------------------------------- ១០

៤. បញ្ហាក្រមសីលធម៌នៃការស្រាវជ្រាវ ---------------------------------- ១១

ជំពូកទី៤: ព័ត៌មានសំខាន់ៗរបស់អ្នកឆ្លើយ ------------------------------------ ១២

១. ព័ត៌មានមូលដ្ឋានរបស់ពលករកុមារ------------------------------------ ១២

២. ព័ត៌មានមូលដ្ឋានរបស់មាតាបិតា ឬមនុស្សពេញវ័យ --------------------------១៣

ជំពូកទី៥: របកគំហើញ -------------------------------------------------- ១៥
១. ចំនួនពលករកុមារនៅសិប្បកម្មឡឥដ្ឋ ---------------------------------------- ១៥
២. លក្ខណៈសំខាន់ៗអំពីការសិក្សារបស់ពលករកុមារ ---------------------------------- ១៦
២.១ ស្ថានភាពនៃការរៀនសូត្រ ---------------------------------------------- ១៦
២.២ ហេតុអ្វីពលករកុមារបោះបង់សាលា ---------------------------------------- ១៧
៣. លក្ខណៈសំខាន់ៗនៃការងាររបស់កុមារ ---------------------------------------- ១៩
៣.១ បទពិសោធន៍ការងារកន្លងមក -------------------------------------------- ១៩
៣.២ អាយុនៅពេលចាប់ធ្វើការដំបូង -------------------------------------------- ២០
៣.៣ ការងារកុមារ -------------------------------------------------------- ២១
៣.៤ ថ្ងៃធ្វើការ និងម៉ោងធ្វើការ ------------------------------------------------ ២៣
៣.៥ ប្រាក់ចំណូល -------------------------------------------------------- ២៤
៤. ការយល់ឃើញពីពលកម្មកុមារនៅឡឥដ្ឋ -------------------------------------- ២៥
៤.១ ការយល់ឃើញរបស់ពលករកុមារ ---------------------------------------- ២៥
៤.២ ការយល់ឃើញរបស់ឪពុកម្តាយ -------------------------------------------- ២៧
៥. ការពាក់ព័ន្ធរបស់កុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ -------------------- ២៧
៦. មូលហេតុដែលធ្វើការនៅសិប្បកម្មឡឥដ្ឋ -------------------------------------- ២៩
៦.១ មូលហេតុដែលចូលរួមក្នុងពលកម្មកុមារ : ចម្លើយរបស់កុមារ ------------------ ២៩
៦.២ មូលហេតុដែលកុមារធ្វើការនៅសិប្បកម្មឡឥដ្ឋ : ចម្លើយរបស់កុមារ ------------- ៣០
៦.៣ មូលហេតុនៃការចូលប្រឡូកក្នុងពលកម្មកុមារ : ចម្លើយរបស់ឪពុកម្តាយ ---------- ៣១
៦.៤ មូលហេតុដែលជួលកុមារអោយធ្វើការ : ចម្លើយរបស់ម្ចាស់សិប្បកម្ម ឬមេការ ------- ៣៣
៧. លក្ខខណ្ឌការងារនៅសិប្បកម្មឡឥដ្ឋ ------------------------------------------ ៣៦
៧.១ ការវាយតំលៃរបស់ពលករកុមារអំពីកន្លែងធ្វើការរបស់ពួកគេ ------------------ ៣៧
៧.២ សិប្បកម្មឡឥដ្ឋជាកន្លែងមានសុវត្ថិភាពសំរាប់កុមារ : ចម្លើយរបស់ឪពុកម្តាយ ------- ៣៩
៨. សុវត្ថិភាពការងារ និងបទបញ្ជាការងារ ---------------------------------------- ៣៩
៨.១ ការងារហាមឃាត់សំរាប់ពលករកុមារ -------------------------------------- ៤០
៨.២ ការទទួលបាននូវព័ត៌មានអំពីសុវត្ថិភាពការងារ ------------------------------ ៤១
៩. ផលប៉ះពាល់នៃពលកម្មកុមារ ---------------------------------------------- ៤២
៩.១ ផលប៉ះពាល់របស់ពលកម្មកុមារទៅលើការអប់រំ ------------------------------ ៤៣

៩.២ ផលប៉ះពាល់នៃពលកម្មកុមារទៅលើសុខភាព ---------------------------- ៤៤
៩.២.១ ការស្មង់ពីបញ្ហាសុខភាពដោយខ្លួនឯង ----------------------------- ៤៤
៩.២.២ ការកើតមានជំងឺញឹកញាប់ដោយសារតែការងារ --------------------- ៤៥
៩.២.៣ ការកើតមានគ្រោះថ្នាក់ និងរបួសញឹកញាប់ ------------------------ ៤៧
១០. ការអនុវត្តន៍ដ៏ល្អបំផុតដើម្បីកាត់បន្ថយគ្រោះថ្នាក់ការងារ------------------------- ៤៩
១១. ការយល់ដឹងអំពីសេចក្តីប្រកាសអំពីពលកម្មកុមារ ------------------------------ ៥០
១២. ការរំពឹងទុកចំពោះអនាគតនៃពលករកុមារ---------------------------------- ៥១
១៣. សំណើដើម្បីកែលម្អស្ថានភាពការងាររបស់កុមារនៅសិប្បកម្មឡឥដ្ឋ ----------------- ៥១

ជំពូកទី៦: សេចក្តីសន្និដ្ឋាននិងអនុសាសន៍ ------------------------------------------៥៣
១. សេចក្តីសន្និដ្ឋាន----------------------------------------------------៥៣
២. អនុសាសន៍------------------------------------------------------------ ៥៥

ឯកសារយោង ------------------------------------------------------------- ៥៨

ឧបសម្ព័ន្ធទី១: កម្រងសំណួរសម្ភាសន៍ជាមួយពលករកុមារ------------------------------ ៥៩
ឧបសម្ព័ន្ធទី២: កម្រងសំណួរសម្ភាសន៍ជាមួយមាតាបិតារបស់ពលករកុមារនៅឡឥដ្ឋ-------------- ៦៩
ឧបសម្ព័ន្ធទី៣: កម្រងសំណួរសម្ភាសន៍ជាមួយម្ចាស់-មេការឡឥដ្ឋ -------------------------- ៨១
ឧបសម្ព័ន្ធទី៤: ------------------------------------------------------------ ៨៨
១-ក្រុមអ្នកស្រាវជ្រាវ------------------------------------------------------ ៨៨
២-កំណត់សំគាល់ពីការប្រមូលទិន្នន័យ ---------------------------------------- ៨៨

# បញ្ជីតារាង

តារាងទី១ : លក្ខណៈសំខាន់ៗរបស់សំណាកកុមារទៅតាមកន្លែងរស់នៅ ---------------------- ១២
តារាងទី២ :លក្ខណៈសំខាន់ៗរបស់សំណាកឪពុកម្តាយទៅតាមកន្លែងរស់នៅ ------------------- ១៤
តារាងទី៣ :ប្រវត្តិនៃការសិក្សាទៅតាមកន្លែងរស់នៅ ----------------------------------- ១៧
តារាងទី៤ :មូលហេតុនៃការបោះបង់ការសិក្សា -------------------------------------- ១៨
តារាងទី៥ :ការពេញចិត្តចំពោះពលករកុមាររបស់ម្ចាស់ និងមេការសិប្បកម្មឡឥដ្ឋ ---------------៣៦
តារាងទី៦ :ការទទួលបានព័ត៌មានអំពីសុវត្ថិភាពការងារ --------------------------------- ៤២
តារាងទី៧ :ឥទ្ធិពលការងារទៅលើការសិក្សា--------------------------------------- ៤៤

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១ : បទពិសោធន៍ការងារពីមុនរបស់ពលករកុមារ ------------------------------ ១៩
ក្រាហ្វិកទី២ : អាយុនៅពេលចាប់ផ្តើមធ្វើការដើម្បីលុយ -------------------------------- ២០
ក្រាហ្វិកទី៣ : ប្រភេទការងាររបស់ពលករកុមារ --------------------------------------២៣
ក្រាហ្វិកទី៧ : ភាគរយកុមារ ដែលចូលរួមក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ------------------ ២៨
ក្រាហ្វិកទី៨ : មូលហេតុដែលធ្វើការ :ចម្លើយរបស់កុមារ---------------------------------៣០
ក្រាហ្វិកទី៩ : ហេតុអ្វីបានជាកុមារធ្វើការនៅសិប្បកម្មឡឥដ្ឋ? ----------------------------៣១
ក្រាហ្វិកទី១០ : មូលហេតុដែលចូលប្រឡូកក្នុងពលកម្មកុមារ :ចម្លើយរបស់ឪពុកម្តាយ ------------៣២
ក្រាហ្វិកទី១១ : ស្ថានភាពការងារនៅសិប្បកម្មឡឥដ្ឋ -----------------------------------៣៨
ក្រាហ្វិកទី១២ : ការងារដែលហាមឃាត់មិនអោយកុមាធ្វើ :របាយការណ៍របស់កុមារ ------------- ៤០
ក្រាហ្វិកទី១៣ : របាយភាគរយកុមារទៅតាមការវាយតម្លៃដោយខ្លួនឯង --------------------- ៤៥
ក្រាហ្វិកទី១៤ : ឧប្បត្តិហេតុនៃជំងឺដែលកើតមានជាញឹកញាប់ ---------------------------- ៤៦
ក្រាហ្វិកទី១៥ : ឧប្បត្តិហេតុនៃការរងរបួសដែលកើតមានជាញឹកញាប់ ----------------------- ៤៨
ក្រាហ្វិកទ១៦ : ភាគរយនៃពលករកុមារដែលមិនពាក់អ្វីការពារពេលធ្វើការ ------------------- ៥០
ក្រាហ្វិកទី១៧ : ការរំពឹងទុកទៅថ្ងៃអនាគតរបស់ពលករកុមារ ---------------------------- ៥១
ក្រាហ្វិកទី១៨ : ការកែលម្អស្ថានភាពការងារសំរាប់កុមារនៅសិប្បកម្មឡឥដ្ឋ------------------- ៥២

# សេចក្តីសង្ខេប


ពលកម្មកុមារបានក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាសង្គមនានានៅក្នុងប្រទេសកម្ពុជា ក្រោយពីរដ្ឋាភិបាល បានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិ នៅក្នុងខែតុលា ឆ្នាំ២០០៥ ។ កង្វល់មួយ គឺថា ការងារដែលធ្វើដោយកុមារនៅក្នុងសិប្បកម្មឡឥដ្ឋជាប្រភេទការងារធ្ងន់ធ្ងរ និងមានគ្រោះថ្នាក់ បន្ថែមពីលើម៉ោងធ្វើការយូរ ការប៉ះពាល់ដល់ការសិក្សានៅសាលារៀន និងការទទួលបានថ្លៃឈ្នួលទាប។ អាស្រ័យហេតុនេះ វាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការរីកលូតលាស់របស់កុមារជាពិសេស ការសិក្សា និងសុខភាព។ ប៉ុន្តែ ឪពុកម្តាយមួយចំនួននៅតែបន្តបញ្ជូនកូនរបស់ខ្លួនអោយទៅធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ ហើយនិយោជកជាច្រើនត្រូវបានសង្ស័យថានៅតែបន្តទទួលកុមារអោយធ្វើការងារនៅក្នុងសិប្បកម្មឡឥដ្ឋ ។

ដើម្បីរួមចំណែកក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងដើម្បីសុខមាលភាពរបស់កុមារកម្ពុជា អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស-លីកាដូ (LICADHO) និងអង្គការទស្សនៈពិភពលោកកម្ពុជា (WVC) បានចាត់តាំងក្រុមស្រាវជ្រាវមួយដែលដឹកនាំដោយបណ្ឌិត ប៉ូច ប៊ុណ្ណាក់ ដើម្បីធ្វើការសិក្សាអំពីកុមារដែលធ្វើ ការងារនៅក្នុងសិប្បកម្មឡឥដ្ឋ។ ការសិក្សានេះត្រូវបានធ្វើឡើង នៅក្នុងខែកក្កដា ឆ្នាំ២០០៧ ដើម្បីកំណត់អំពីមូលហេតុ និងផលវិបាកនៃពលកម្មកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ នៅស្រុកសង្កែ និងស្រុកបាត់ដំបង ដែលជាតំបន់នៅជុំវិញទីរួមខេត្តបាត់ដំបង។ ក្រុមស្រាវជ្រាវបានប្រមូលទិន្នន័យដោយប្រើប្រាស់កម្រងសំណួរបំពេញដោយអ្នកធ្វើសម្ភាសន៍មកពីប្រភពសំខាន់ៗចំនួន ៣ (កម្មករជាកុមារចំនួន ១៣២ នាក់ ឪពុកម្តាយចំនួន ៤៣ នាក់ និងម្ចាស់សិប្បកម្ម ឬអ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋចំនួន ១៥ នាក់) មកពីសិប្បកម្មឡឥដ្ឋចំនួន ២៦ កន្លែង។ គេបានសន្និដ្ឋានថា កុមាររវាងពី ៤០០ ទៅ ៥០០ នាក់ធ្វើការជារៀងរាល់ថ្ងៃ នៅក្នុងសិប្បកម្មឡឥដ្ឋទាំងនេះនៅក្នុងកំឡុងរដូវដែលមានតម្រូវការការងារខ្ពស់។

ពលករកុមារចំនួន ១៣២នាក់ បានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ។ ក្នុងចំណោមកុមារដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ (កុមារ ៩៦ នាក់) មាន ៧១,៩% ជាកុមារី ១០,៤% មានអាយុក្រោម ១៥ឆ្នាំ ៦២,៥% រស់នៅក្នុងគ្រួសារមិនបែកបាក់ និង១៧,៧%ជាកូនច្បងនៅក្នុងគ្រួសារ។ ក្នុងចំណោមកុមារដែលរស់នៅក្នុងបរិវេណសិប្បកម្ម ឡឥដ្ឋ (កុមារ ៣៦ នាក់) មាន ៤៤,៤%ជាកុមារី ៤១,៧%មានអាយុក្រោម១៥ឆ្នាំ ៦៩,៤% រស់នៅក្នុងគ្រួសារមិនបែកបាក់ និង ៣៦,១%ជាកូនច្បងនៅក្នុងគ្រួសារ ។

ភាគច្រើននៃឪពុកម្តាយទាំង ៤៣នាក់ ដែលបានធ្វើសម្ភាសន៍ជាស្ត្រីដែលមិនមានការបែកបាក់គ្រួសារមានអាយុជាមធ្យម ៤០ឆ្នាំ។ ពួកគាត់មកពីគ្រួសារដែលមានសមាជិកច្រើននាក់ (មានកូន៤នាក់ជាមធ្យម) ដោយមានកូនជាច្រើនធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ (ជិត ៧០% នៃកូនរបស់ពួកគាត់ដែលមានអាយុពី ៧ ដល់ ១៧ឆ្នាំ)

ហើយមិនទៅសាលារៀន (ប្រហែល៥០%)។ ឪពុកម្តាយមានបទពិសោធន៍ពេញលេញក្នុងការធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ (ប្រហែល ៥០% មានបទពិសោធន៍យ៉ាងតិចណាស់ ៥ ឆ្នាំ) ហើយរកប្រាក់កម្រៃជាមធ្យមលើស ២០០.០០០រៀលបន្តិច ក្នុងមួយខែ។ ឪពុកម្តាយស្ទើរតែទាំងអស់ដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ ជាជនចំណាកស្រុក ។

## ប្រវត្តិនៃការសិក្សារបស់ពលករកុមារ

ពលករកុមារជាច្រើននៅក្នុងសិប្បកម្មឡឥដ្ឋមិនបានចូលសាលារៀនទេ (៧៤,០% ក្នុងចំណោមកុមារនៅក្នុងភូមិ និង៥៥,៥%ក្នុងចំណោមកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ)។ កុមារចំនួនប្រហែលបីភាគបួនបានបោះបង់ចោលការសិក្សាអស់រយៈពេលជាងពីរឆ្នាំមកហើយ ដោយសារមូលហេតុជាច្រើន ដូចជា មូលហេតុគ្រួសារ (កង្វះខាតផ្នែកសេដ្ឋកិច្ចគ្រួសារតម្រូវការការងារដោយឪពុកម្តាយ ឪពុកម្តាយមានជំងឺ និងបំណុលគ្រួសារ) បញ្ហាពាក់ព័ន្ធនឹងសាលារៀន (ខ្វះខាតប្រាក់កាសសម្រាប់បង់ថ្លៃសិក្សា កង្វះមធ្យោបាយធ្វើដំណើរ ដោយសារសាលារៀននៅឆ្ងាយសម្រាប់កម្រិតថ្នាក់របស់ពួកគេ និង បញ្ហាវិន័យសាលារៀន) និងមូលហេតុផ្ទាល់ខ្លួន (ពិន្ទុខ្សោយ ឥរិយាបថអវិជ្ជ-មានចំពោះការសិក្សា ចង់នៅជាមួយមិត្តភក្តិដែលធ្វើការ ចង់បានប្រាក់សម្រាប់តម្រូវការផ្ទាល់ខ្លួន ឬចង់នៅឆ្ងាយពីឪពុកម្តាយដែលតែងតែឈ្លោះគ្នាជាញឹកញាប់) ។

## ប្រវត្តិការងាររបស់កុមារឆ្លើយសម្ភាសន៍

ជាធម្មតា កុមារមួយចំនួនដែលធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋបច្ចុប្បន្ន ធ្លាប់ធ្វើការនៅកន្លែងផ្សេងពីមុនមកទាំង នៅក្នុងសិប្បកម្មឡឥដ្ឋ (២២%)ឬនៅក្នុងវិស័យសេដ្ឋកិច្ចផ្សេងទៀត (២០,៥%)។ ភាគរយនៃការធ្លាប់មានបទពិសោធន៍ ការងារពីមុនមកក្នុងចំណោមកុមារដែលរស់នៅក្នុងបរិវេណសិប្បកម្មឡឥដ្ឋ មានទាបជាងកុមារដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ (១៣,៩% ទល់នឹង ២៥,០% រៀងគ្នា) ដោយសន្និដ្ឋានថា កុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋប្រហែលជា ចាប់ផ្តើមធ្វើការងារដំបូង នៅក្នុងសិប្បកម្មឡឥដ្ឋបច្ចុប្បន្ន របស់ពួកគេតែម្តង (រូបភាពទី ១)។

ពលករកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ មានទំនោរចាប់ផ្តើមធ្វើការងារ នៅអាយុក្មេងជាងកុមារដែលរស់ នៅក្នុងភូមិ (៥៧% ទល់នឹង ២១,៨% រៀងគ្នា ដែលចាប់ផ្តើមធ្វើការនៅអាយុក្រោម ១២ឆ្នាំ) (រូបភាពទី ២)។ ចំណុច នេះហាក់ដូចជាបង្ហាញអោយឃើញនូវការប្រឈមមុខនឹងការងារអូសបន្លាយពេលយូរ និងភាពងាយរងគ្រោះខ្ពស់ចំពោះ ការងារប្រកបដោយគ្រោះថ្នាក់ក្នុងចំណោមកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ។ ការឆាប់ចូលរួមធ្វើការក្នុងពលកម្មកុមារ គឺបណ្តាលមកពីតម្រូវការរបស់ឪពុកម្តាយអោយពួកគេធ្វើការ បន្ថែមពីលើកង្វះខាតសេដ្ឋកិច្ចគ្រួសារ ។

ជាធម្មតា ពលករជាកុមារនៅក្នុងសិប្បកម្មឡឥដ្ឋបំពេញភារកិច្ចជាច្រើន។ ភារកិច្ចទូទៅបំផុត គឺការរុញរទេះដឹក ឥដ្ឋ លើកឥដ្ឋដាក់ក្នុង និងរើឥដ្ឋចេញពីឡ លើកឥដ្ឋដាក់ក្នុង និងចេញពីរទេះ លើកឥដ្ឋដាក់ក្នុងឡាន និងតំរៀបឥដ្ឋហាល។ កុមារមួយចំនួនក៏ធ្វើជាអ្នកបញ្ជាម៉ាស៊ីនកាត់ឥដ្ឋ ឬអ្នកដុតភ្លើងឡឥដ្ឋ (រូបភាពទី ៣)។

ពលករជាកុមារស្ថិតនៅក្នុងស្ថានភាពការងារបីប្រភេទ : ការងារចុះកិច្ចសន្យាពេញម៉ោង ឬប្រចាំថ្ងៃ ឬការងារមិនពេញម៉ោង ឬការងារចុងសប្តាហ៍ (រូបភាពទី ៤)។ ជាធម្មតា កុមារចុះកិច្ចសន្យាធ្វើការច្រើនម៉ោង ជាងកុមារដែល ស្ថិតក្នុងស្ថានភាពផ្សេងទៀត។ ប៉ុន្តែកុមារជាច្រើនធ្វើការពេញម៉ោងនៅក្នុងសិប្បកម្មឡឥដ្ឋ (កុមារ ៩៣ នាក់) ។

ប្រាក់ឈ្នួលជាមធ្យម គឺ ៥.000រៀល សម្រាប់ការងារ ៨ម៉ោង (ស្មើនឹង ១,២ ដុល្លារអាមេរិក)។ ជាធម្មតា កុមារដែលធ្វើការដោយចុះកិច្ចសន្យា ដូចជា ដុតភ្លើងឡឥដ្ឋ រៀបចំដីឥដ្ឋ ឬកាត់ឥដ្ឋ ទទួលបានប្រាក់ឈ្នួលច្រើនជាងបន្តិច។ ទោះជាយ៉ាងណាក៏ដោយ កុមារតូចៗមួយចំនួន (មានអាយុពី ៨ ទៅ ១០ ឆ្នាំ) ទទួលបានប្រាក់ឈ្នួលតិចតួចត្រឹមតែ ១.000 រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ ពីព្រោះពួកគេធ្វើការមិនពេញម៉ោង ហើយមិនរៀងរាល់ថ្ងៃ ។

## ការយល់ឃើញអំពីពលកម្មកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ

ការងារធ្ងន់ធ្ងរត្រូវបានរកឃើញថាជាការងារចុះកិច្ចសន្យា (រូបភាពទី ៥) ចំណែកឯកុមារជាច្រើន ដែលធ្វើការ ដោយចុះកិច្ចសន្យា (៨១,៣%) ឬធ្វើការពេញម៉ោង (៨៣,៩%)បានរអ៊ូរទាំចំពោះ ម៉ោងធ្វើការយូរ។ ការសិក្សាស្រាវជ្រាវបានរកឃើញថា ការងារចុះកិច្ចសន្យាមិនល្អសម្រាប់កុមារទេ ពីព្រោះវាតម្រូវអោយមានការងារធ្ងន់ ម៉ោងធ្វើការយូរ និងប៉ះពាល់ដល់ការសិក្សានៅសាលារៀន។

ផ្ទុយទៅវិញ ៣០,២% នៃឪពុកម្តាយចំនួន ៤១ នាក់ បាននិយាយថា ការងាររបស់កូនគាត់មិនធ្ងន់ពេកទេ សម្រាប់ពួកគេ ហើយ ៤៤,២%នៃឪពុកម្តាយចំនួន ៤១ នាក់ បាននិយាយថា ម៉ោងធ្វើការមានភាពសមល្មម សម្រាប់កូនរបស់ពួកគាត់។ ការរកឃើញបានជួយពន្យល់មូលហេតុដែលឪពុកម្តាយតម្រូវអោយកូនធ្វើការ។

## ការចូលរួមរបស់កុមារនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ការរួមផ្សំគ្នារវាងម៉ោងធ្វើការ និងការទៅរៀនរបស់ពលករកុមារ ត្រូវបានប្រើប្រាស់ដើម្បីបង្កើតសន្ទស្សន៍នៃ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ (រូបភាពទី ៧)។ លទ្ធផលបានបង្ហាញថា ពលករជាកុមារ ចំនួនប្រហែល ៨៥% បានពាក់ព័ន្ធក្នុងទម្រង់ពលកម្មធ្ងន់ផ្សេងៗ (៥២,៣%) ឬទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (៣២,១%)។

## មូលហេតុនៃការធ្វើការក្នុងសិប្បកម្មឡឥដ្ឋ

បើតាមចម្លើយរបស់កុមារ (រូបភាពទី ៨) មានមូលហេតុ ១០យ៉ាង នៃការធ្វើការគឺ កង្វះខាតផ្នែកសេដ្ឋកិច្ច គ្រួសារ តម្រូវការផ្ទាល់ខ្លួន (ដូចជា សម្លៀកបំពាក់ ស្បែកជើង ចំណីអាហារ ។ល។) ឪពុកម្តាយ ឬអាណាព្យាបាលបង្ខំ អោយធ្វើការដោយសារបំណុលគ្រួសារ (២២,២%)។ ចម្ងាយទៅកន្លែងធ្វើការ គឺជាមូលហេតុឈានមុនគេដែលធ្វើអោយ កុមារធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ (រូបភាពទី៩)។ នៅក្នុងចំណោមពលករកុមារដែលរស់នៅក្នុងបរិវេណសិប្បកម្មឡឥដ្ឋ មូលហេតុចម្បងរបស់ពួកគេគឺថាពួកគេធ្វើការ ពីព្រោះគ្រួសាររបស់ពួកគេធ្វើការ និងរស់នៅទីនោះ។ មូលហេតុផ្សេងទៀត មានដូចជា ភាពងាយស្រួលក្នុងការរកការងារធ្វើនៅក្នុងសិប្បកម្មឡឥដ្ឋ (១៩,០%) ស្គាល់អ្នកណាម្នាក់នៅក្នុងសិប្បកម្មឡឥដ្ឋ (១៧,៩%) ពុំចាំបាច់មានជំនាញ ឬបទពិសោធន៏ (៩,៥%) ងាយស្រួលរកប្រាក់ (៧,១%) និងអ្នកគ្រប់គ្រង ចិត្តល្អ (៨,៣%)។

ចម្លើយរបស់កុមារដូចគ្នាទាំងស្រុងនឹងចម្លើយរបស់ឪពុកម្តាយរបស់ពួកគេ។ មូលហេតុមួយ គឺកង្វះខាតផ្នែកសេដ្ឋកិច្ចគ្រួសារ (ឪពុកម្តាយប្រហែល ៩០%)។ មូលហេតុមួយទៀត គឺគ្រួសារត្រូវការពលកម្មកុមារ។ ម្យ៉ាងវិញទៀត កុមារត្រូវបានជំរុញអោយធ្វើការដោយឪពុកម្តាយរបស់ពួកគេ ពីព្រោះគ្រួសាររបស់ពួកគេរស់នៅទីនោះ ឪពុកម្តាយត្រូវការជំនួយពីពួកគេដើម្បីបំពេញការងាររបស់ពួកគាត់ ឪពុកម្តាយត្រូវការអ្នកជំនួស នៅពេលពួកគាត់មានជំងឺឬចាស់ជរា ឬការងារនៅក្នុងសិប្បកម្មឡឥដ្ឋបានក្លាយទៅជាប្រពៃណីគ្រួសារ (៥៤,៨%)។ ការរកឃើញនេះអាចបញ្ជាក់បន្ថែមផង ដែរថា កុមាររស់នៅក្នុងបរិវេណសិប្បកម្មឡឥដ្ឋនឹងត្រូវជំរុញ អោយធ្វើការងារទីនោះ នៅទីបំផុត ដោយឪពុកម្តាយរបស់ពួកគេ ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ (រូបភាពទី ១០)។

បើតាមចម្លើយរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋ កុមារមកធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ ដោយសារ មូលហេតុបីយ៉ាង : ការងារងាយស្រួលដោយគ្មានតម្រូវការ ឬលក្ខខណ្ឌកំហិត ទីតាំងជិតផ្ទះ និងកុមារជាច្រើនបានបោះបង់ចោលការសិក្សា ហើយស្វែងរកការងារធ្វើដើម្បីទទួលបានប្រាក់កម្រៃ ។

មូលហេតុសំខាន់ ៣ ក្នុងការទទួលកុមារអោយធ្វើការ ក៏ត្រូវបានបញ្ជាក់ជូនដោយអ្នកគ្រប់គ្រង ឬម្ចាស់សិប្បកម្មឡឥដ្ឋដែលក្រុមយើងបានធ្វើទស្សនកិច្ច : កង្វះខាតផ្នែកសេដ្ឋកិច្ចគ្រួសារ ភាពអាណិតអាសូរចំពោះកុមាររបស់ម្ចាស់/អ្នកគ្រប់គ្រងសិប្បកម្មនិងសំណើសុំរបស់ឪពុកម្តាយអោយកូនរបស់ខ្លួនធ្វើការ (ឪពុកម្តាយស្នើសុំអោយគេអនុញ្ញាត្តិដល់ កូនរបស់ខ្លួនដើម្បីធ្វើការដែរ បើមិនអញ្ចឹងទេឪពុកម្តាយមិនធ្វើការឡើយ)។ ប៉ុន្តែមានតែ ៦ នាក់ប៉ុណ្ណោះក្នុងចំណោមម្ចាស់/អ្នកគ្រប់គ្រងសិប្បកម្មចំនួន ១៥ នាក់ ដែលបានបញ្ជាក់ថា ពួកគេមានការពេញចិត្តដែលមានកុមារមកធ្វើការក្នុងសិប្បកម្មរបស់ពួកគេ (តារាងទី ៥)។ ម្ចាស់/អ្នកគ្រប់គ្រងសិប្បកម្មអះអាងថា កុមារងាយស្រួលគ្រប់គ្រងមកធ្វើការទៀងទាត់ពេលវេលា អាចធ្វើការដោយឯករាជ្យតាមកិច្ចសន្យា ធ្វើការលឿន និងខិតខំធ្វើការ ហើយសមស្របសម្រាប់ការលើកឥដ្ឋ។

## លក្ខខណ្ឌការងារនៅក្នុងសិប្បកម្មឡឥដ្ឋ

ការអង្កេតមើលការងារនៅនឹងកន្លែងបានបង្ហាញថា បរិយាកាសការងារនៅក្នុងសិប្បកម្មឡឥដ្ឋ មានភាពគ្រោះថ្នាក់ចំពោះសុខភាពកុមារ ដោយសារតែបរិស្ថានគ្មានអនាម័យ (មិនស្អាត ផ្សែង ក្លិនមិនល្អនៃជីលាមកសត្វ និងការប្រើប្រាស់ទឹកស្រះ) បរិយាកាសការងារគ្មានសុវត្ថិភាព (ដូចជា ក្តៅ ផេះក្តៅ កំទេច ផេះហុយ និងកំទេចឥដ្ឋបាក់បែកនៅគ្រប់ទីកន្លែង) និងការងារប្រកបដោយគ្រោះថ្នាក់ (ម៉ោងធ្វើការយូរ ការងារធ្ងន់ និងមានគ្រោះថ្នាក់)។

សន្ទស្សន៍លក្ខខណ្ឌការងារចំនួន ៧ ត្រូវបានបង្កើតឡើង (សូមមើលអត្ថបទខាងក្នុង)។ ពលករកុមារជាង ៥០% នៅក្នុងសិប្បកម្មឡឥដ្ឋទាំងអស់ យល់ឃើញថា មានលក្ខខណ្ឌការងារមិនល្អចំពោះសន្ទស្សន៍ចំនួន ៣ : កំដៅមិន អាចទ្រាំទ្របាន (១០០%) កំទេចផេះហុយ (១០០%) និងឥដ្ឋធ្លាក់លើកម្មករ (១០០%)។ លើសពីនេះទៅទៀត សិប្បកម្មឡឥដ្ឋជាច្រើនត្រូវបានចាត់ទុកថាមានលក្ខខណ្ឌការងារមិនល្អចំពោះសន្ទស្សន៍ចំនួន ៤ ផ្សេងទៀត : ខ្វះអនាម័យ (៩៤%) គ្មានប្រអប់ថ្នាំពេទ្យសង្គ្រោះបឋម (៩៤%) ទីកន្លែងគ្មានសុវត្ថិភាពសម្រាប់កុមាររស់នៅ (៧៥%) និងទីកន្លែង ធ្វើការប៉ះពាល់ដល់សុខភាព (៧៥%)។

ប៉ុន្តែ ឪពុកម្តាយមួយចំនួនយល់ឃើញថា សិប្បកម្មឡឥដ្ឋជាកន្លែងដែលមានសុវត្ថិភាព សម្រាប់កុមាររស់នៅ និងធ្វើការ (មួយភាគបីនៃឪពុកម្តាយទាំងអស់)។ ទោះបីជាយ៉ាងនេះក៏ដោយ ឪពុកម្តាយជាច្រើនពិតជាយល់ស្របថា សិប្បកម្មឡឥដ្ឋមិនមានសុវត្ថិភាពសម្រាប់កុមារក្នុងការរស់នៅ និងធ្វើការទេ ពីព្រោះមានកំទេចផេះហុយ ដើរលើផេះក្តៅ ប្រឈមមុខនឹងឥដ្ឋធ្លាក់លើ ដាច់រលាត់ ឬរបួសដោយដុំឥដ្ឋ របួសដោយម៉ាស៊ីនកាត់ឥដ្ឋ បញ្ហាអនាម័យ ឬឡានអាចបើកកិន។

## សុវត្ថិភាពការងារ និងបទបញ្ជាការងារ

បើតាមពលករកុមារ សិប្បកម្មឡឥដ្ឋជាច្រើនមិនមានបទបញ្ជាការងារ ឬវិធានការសុវត្ថិភាពឡើយ ។ ជាឧទាហរណ៍ កុមារ ៩៤% បាននិយាយថា ពួកគេមិនដែលត្រូវបានហាមមិនអោយធ្វើកិច្ចការណាមួយឡើយ ចាប់តាំងពីពួកគេចូលធ្វើការមក។ កុមារផ្សេងទៀតបានអះអាងថា ពួកគេទទួលរងនូវការដាក់កំហិតចំពោះភារកិច្ចមួយចំនួន ។ ភារកិច្ច រួមមានដូចជា បញ្ជាម៉ាស៊ីនកិនឥដ្ឋ កាត់ឥដ្ឋឆៅ ជញ្ជូនកាយ និងលាយ ដីឥដ្ឋ ជញ្ជូនដីឥដ្ឋ ដុតភ្លើងឡឥដ្ឋ និងសម្អាតផេះក្តៅ (រូបភាពទី ១២)។

ភាគច្រើននៃឪពុកម្តាយដែលបានឆ្លើយសម្ភាសន៍ និងម្ចាស់/អ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋ ក៏បានអះអាងផងដែរថា មានការហាមឃាត់មិនអោយកុមារធ្វើការជាអ្នកបញ្ជាម៉ាស៊ីន (២៨ នាក់ ក្នុងចំណោមឪពុកម្តាយ ៤៣ នាក់ និង ១០ នាក់ក្នុងចំណោមអ្នកគ្រប់គ្រងសិប្បកម្ម ១៥ នាក់)។ អ្នកគ្រប់គ្រងសិប្បកម្មបីនាក់បាននិយាយថា សិប្បកម្មរបស់ពួកគេ មិនមានការដាក់កំហិតបែបនេះឡើយ។

ចំពោះការណែនាំពាក់ព័ន្ធនឹងសុវត្ថិភាពការងារ សិប្បកម្មឡឥដ្ឋស្ទើរតែទាំងអស់ បានធ្វើការណែនាំដល់ពលករកុមារ មុននឹងចាប់ផ្ដើមធ្វើការ។ ប៉ុន្តែ ពលករកុមារតិចជាង ៥០% បានអះអាងថា បានទទួលពត៌មានបែបនេះ (តារាងទី ៦) ។ នៅតែមានម្ចាស់ ឬអ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋជាច្រើន (៩នាក់ ក្នុងចំណោម ១៥នាក់) មិនបានដឹងសេចក្ដីថ្លែងការណ៍ ឬសេចក្ដីប្រកាសអំពីពលកម្មកុមារនៅក្នុងប្រទេសកម្ពុជាដែលមាននៅឡើយ ។

## ផលប៉ះពាល់នៃពលកម្មកុមារ

បើប្រៀបធៀបទៅនឹងអ្នកដែលធ្វើការងារក្នុងរយៈពេលខ្លីជាង ពលករកុមារដែលធ្វើការបានរយៈពេលយូរ ជាង២ឆ្នាំ បង្ហាញនូវអត្រាបោះបង់ចោលការសិក្សាខ្ពស់ជាងយ៉ាងខ្លាំង (៣៧,៨% ទល់នឹង ៧,៧% រៀងគ្នា) ពិន្ទុខ្សោយ (៥២,៦% ទល់នឹង ២១,៤%) ទៅរៀនយឺតពេល (៤៧,៤% ទល់នឹង ២៨,៦%) និងគេចសាលា (៤២,១% ទល់នឹង ៧,១%) ។ ឪពុកម្ដាយដែលបានឆ្លើយសម្ភាសន៍ក៏បានបញ្ជាក់អះអាងផងដែរថា តាំងពីចាប់ផ្ដើមធ្វើការ កូនរបស់ពួកគាត់មានឥរិយាបថអវិជ្ជមានចំពោះការសិក្សារបស់ពួកគេ ទៅរៀនមិនទៀងទាត់ និងទទួលបានពិន្ទុខ្សោយជាងមុន។

ពលករកុមារជិតបួនភាគប្រាំដែលរស់នៅក្នុងបរិវេណសិប្បកម្មឡឥដ្ឋ បានវាយតម្លៃលក្ខខណ្ឌសុខភាពរបស់ពួកគេផ្ទាល់ថាមធ្យម ឬធ្ងន់ធ្ងរ ដោយផ្អែកទៅលើសន្ទស្សន៍សុខភាពទូទៅ (សូមមើលអត្ថបទ អំពីការពន្យល់) សម្រាប់រយៈពេលធ្វើការងារទាំងពីរក្រុម។ ប៉ុន្តែ ចំពោះពលករកុមារ ដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ ក្នុងចំណោមកុមារដែលធ្វើការរយៈពេលវែង ភាគរយនៃការអះអាងថា មានបញ្ហាសុខភាពមធ្យម ឬធ្ងន់ធ្ងរមានកម្រិតខ្ពស់ជាង កុមារដែលធ្វើការរយៈពេលខ្លី (៩១,៥% ទល់នឹង ៧៤,៥% រៀងគ្នា) (រូបភាពទី ១៣) ។

ពាក់ព័ន្ធនឹងបញ្ហាសុខភាពជាក់លាក់ដែលតែងតែជួបប្រទះជាញឹកញាប់ ទាំងពលករជាកុមារដែលរស់នៅនិងមិន រស់នៅក្នុងសិប្បកម្មឡឥដ្ឋ ភាគច្រើនហាក់ដូចជាកើតជំងឺហៀរទឹកភ្នែក ឬរមាស់ភ្នែក ដោយសារតែផ្សែងនិងកំទេចផេះ ហុយ (រូបភាពទី ១៤)។ បញ្ហាសុខភាពផ្សេងទៀតអាស្រ័យលើកន្លែងរស់នៅ។ កុមាររស់នៅក្នុងភូមិហាក់ដូចជាកើត ជំងឺឈឺឆ្អឹងខ្នង (៤០,០% ទល់នឹង ១៨,២%) ឈឺទ្រូង (៣១,៩% ទល់នឹង ១៥,២%) ឈឺក្បាល (៣៣,០% ទល់នឹង ២១,១%) កន្ទួលរមាស់លើស្បែក (៣៧,២% ទល់នឹង ២៤,២%) ពិបាកដកដង្ហើម (២៥,៥% ទល់នឹង ១៨,២%) និង ឈឺក្រពះ (១៦,០% ទល់នឹង ៩,១%) ច្រើនជាងកុមារ ដែលរស់នៅក្នុងសិប្បកម្ម។ ការពន្យល់ដ៏សមស្របមួយគឺថា កុមារនៅក្នុងភូមិមិនទម្លាប់ទៅនឹងបរិយាកាសការងារនៅក្នុងសិប្បកម្មឡឥដ្ឋ ដូចកុមារក្នុងសិប្បកម្មដែលរស់នៅ និងធ្វើការនៅក្នុងបរិយាកាសដូចគ្នា ។

លើសពីនេះទៅទៀត ពលករកុមារជិតមួយភាគពីរមានរបួសស្រាល ដោយសារការងារ ដោយមិនគិតពីកន្លែងរស់នៅ និងរយៈពេលធ្វើការ (រូបភាពទី ១៥) ។ មូលហេតុទូទៅ គឺបណ្ដាលមកពីឥដ្ឋធ្លាក់លើ មុតឥដ្ឋនៅពេលលើកចេញ/ដាក់ចូល និងជញ្ជូនឥដ្ឋ និងមុតជើងដោយវត្ថុស្រួច។ ការរលាកស្រាល ក៏កើតមានជាទូទៅផង

ដែរ ដោយសារតែការលើកឥដ្ឋចេញនៅពេលឥដ្ឋក្តៅ។ ការរបួសធ្ងន់ធ្ងរ និងរលាកធ្ងន់ធ្ងរពិតជាកើតមានជាញឹកញាប់ចំពោះពលករកុមារប្រហែលពី ១០ ទៅ ១៥%។ ភាគរយទាបនៃរបួស ដែលបានរាយការណ៍ត្រូវបានប៉ាន់ប្រមាណថាទាប ដោយសារតែការប្រើប្រាស់បទពិសោធន៍ញឹកញាប់។

ការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា ការពាក់វ៉ែនតា និងពាក់ម៉ូក មិនមែនជាទម្លាប់សម្រាប់ពលករកុមារទាំងអស់នោះទេហើយមានតែកុមារតិចតួចប៉ុណ្ណោះដែលអះអាងថាពាក់ស្បែកជើងធ្វើការ (១២.១% ក្នុងចំណោមកុមាររស់នៅក្នុងសិប្បកម្ម និង២៧.៧%ក្នុងចំណោមកុមាររស់នៅក្នុងភូមិ)។ មូលហេតុ ចម្បងជាងគេមួយនៃការមិនពាក់សម្ភារៈទាំងនេះ គឺដោយសារថាកុមារមិនមានលទ្ធភាពទិញ ឬមិនមានទម្លាប់ពាក់សម្ភារៈការពារសុវត្ថិភាព (រូប-ភាពទី ១៦) ។

## ការរំពឹងទុកសម្រាប់អនាគតរបស់ពលករកុមារ

ពលករកុមារភាគច្រើនមិនចង់បន្តការសិក្សាឡើយ ផ្ទុយពីការរំពឹងទុករបស់ឪពុកម្តាយ ជាពិសេសឪពុកម្តាយដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ។ ចំណុចនេះ អាចបណ្តាលមកពីកត្តាដែលថា ពលករកុមារភាគច្រើន ដែលបានឆ្លើយសម្ភាសន៍បានបោះបង់ចោលការសិក្សារួចទៅហើយ។ ផ្ទុយទៅវិញ កុមារជាច្រើនចង់រកការងារធ្វើនៅកន្លែងផ្សេង (រូបភាពទី១៧)។

## សំណូមពរសម្រាប់ការកែលម្អលក្ខខណ្ឌការងារសម្រាប់កុមារនៅក្នុងសិប្បកម្មឡឥដ្ឋ

សំណូមពរសម្រាប់ការកែលម្អលក្ខខណ្ឌការងារនៃពលកម្មកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ ត្រូវបានផ្តល់ដោយអ្នកឆ្លើយសម្ភាសន៍មួយចំនួនតូច ដែលនេះបង្ហាញអំពីកង្វះចំណេះដឹងអំពីលក្ខខណ្ឌការងារល្អប្រសើរជាងមុន (រូបភាពទី ១៨)។ ប៉ុន្តែអ្នកឆ្លើយសម្ភាសន៍មួយចំនួនបានលើកឡើងជាសំណូមពរល្អៗមួយចំនួនតូច ដូចជាការកាត់បន្ថយបន្ទុកការងារសម្រាប់កុមារ ការតម្លើងប្រាក់ឈ្នួលអោយកុមារ ការផ្តល់គ្រឿងបរិក្ខារ ការពារដល់កុមារ ការបង្ខំអោយអនុវត្តវិធានដែលហាម ឃាត់កុមារមិនអោយធ្វើកិច្ចការប្រកបដោយគ្រោះថ្នាក់ ការបង្កើតវិធានដែលហាមឃាត់សិប្បកម្មមិនអោយបង្ខំកុមារ អោយធ្វើការហួសពីសមត្ថភាពរាងកាយ នៅពេលកម្មករធ្លាក់ខ្លួនឈឺដោយសារការងារត្រូវអោយឈប់សម្រាក និងការផ្តល់ការគាំទ្រដល់ការសិក្សារបស់កុមារ ។

## អនុសាសន៍

អនុសាសន៍ត្រូវបានផ្តល់នៅក្នុងជំពូកសន្និដ្ឋាននៃរបាយការណ៍នេះ ។

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះ នឹងមិនអាចបញ្ចប់ដោយជោគជ័យបានទេ ប្រសិនបើគ្មានការគាំទ្រ និងការចូលរួមយ៉ាងសំខាន់ ពីសំណាក់អង្គការនិងបុគ្គល ដូចខាងក្រោមនេះ :

- ឯកឧត្តម សៀង ស៊ុតថង ជាអភិបាលរងខេត្តបាត់ដំបង ព្រមទាំងខុទ្ទកាល័យខេត្តបាត់ដំបង ដែលបានអនុញ្ញាតិ អោយក្រុមស្រាវជ្រាវចុះធ្វើការស្រាវជ្រាវទៅតាមតំបន់គោលដៅ ។
- អង្គការទស្សនៈពិភពលោកកម្ពុជា ដែលបានផ្តល់ថវិកាសំរាប់ការស្រាវជ្រាវ ។
- គំរោងប្រយុទ្ធប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលបានបញ្ជូន បុគ្គលិករបស់ខ្លួនចំនួនបីនាក់អោយជួយក្នុងការងារប្រមូលទិន្នន័យ ជួយដឹកនាំក្រុមស្រាវជ្រាវទៅកាន់សិប្បកម្មគោលដៅ និងជួយសំរួលដល់ការងារទំនាក់ទំនងជាមួយម្ចាស់ឬមេការសិប្បកម្មឡឥដ្ឋ ។
- អង្គការលីកាដូ សាខាខេត្តបាត់ដំបង ដែលបានផ្តល់ទីកន្លែងសំរាប់ហ្វឹកហ្វឺនអ្នកប្រមូលទិន្នន័យ និងដែលបានបញ្ជូនបុគ្គលិកពីរនាក់អោយជួយការងារប្រមូលទិន្នន័យ ។
- លោក ឡោ មុន្នីរិទ្ធ ប្រធានគំរោងប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ របស់អង្គការទស្សនៈពិភពលោកកម្ពុជា ដែលបានផ្តល់ការគាំទ្រការសិក្សានេះ ។
- លោក យ៉ុង សុខន អ្នកសំរបសំរួលការងារយុទ្ធនាការ របស់អង្គការលីកាដូ ចំពោះការប្រឹងប្រែងដែលមិនចេះនឿយហត់ ក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋអំណាចមូលដ្ឋាន ដើម្បីសុំការអនុញ្ញាតិ ធ្វើការស្រាវជ្រាវ ។
- ម្ចាស់និងមេការសិប្បកម្មឡឥដ្ឋ កុមារដែលកំពុងធ្វើការនៅសិប្បកម្មឡឥដ្ឋ និងមាតាបិតាទាំងអស់ ដែលបានចូលរួមក្នុងការសិក្សានេះ ចំពោះការចែករំលែកបទពិសោធន៏និងព័ត៌មានចាំបាច់សំរាប់ការសិក្សានេះ ។
- ក្រុមអ្នកស្រាវជ្រាវ ដែលបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីស្វែងរកសិប្បកម្មឡឥដ្ឋ និងអ្នកឆ្លើយ និងបញ្ចប់ការសម្ភាសន៏ដោយជោគជ័យនិងទាន់ពេល ។
- លោក រ៉ៃ សាណូ ប្រធានកម្មវិធីកុមារស្ថិតក្នុងវិបត្តិ របស់អង្គការទស្សនៈពិភពលោកកម្ពុជា និងអ្នកពិនិត្យទាំងអស់ ដែលបានពិនិត្យឡើងវិញនិងផ្តល់អនុសាសន៏ អំពីសេចក្តីព្រាងដើមនៃរបាយការណ៏នេះ ។

# ជំពូកទី១: សេចក្តីផ្តើម

ពលកម្មកុមារបានក្លាយទៅជាបញ្ហាមួយរបស់សង្គមនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិ ដោយរាជរដ្ឋាភិបាល នៅខែតុលា ឆ្នាំ២០០៥។ ការខ្វល់ខ្វាយមួយ អំពីពលកម្មកុមារ គឺការងារដែលពួកគេធ្វើនៅសិប្បកម្មឡឥដ្ឋ។ ចរិតនៃការខ្វល់ខ្វាយនេះ គឺស្ថិតនៅត្រង់ការងារដែលធ្ងន់ធ្ងរ និងមានគ្រោះថ្នាក់ រយៈពេលធ្វើការយូរម៉ោង និងមានប្រាក់ចំណូលតិច ហើយនិងផលប៉ះពាល់យូរអង្វែងនៃពលកម្មនេះទៅលើសុខភាព និងការរៀនសូត្ររបស់កុមារ។ ឧទាហរណ៍ មានរបាយការណ៍មួយចំនួនអំពីគ្រោះថ្នាក់ ដូចជាកុមារបាត់បង់ដៃរបស់គេ ដោយសារម៉ាស៊ីនធ្វើឥដ្ឋ។ យ៉ាងដូច្នេះក្តី ឪពុកម្តាយខ្លះនៅតែបញ្ជូនកូនចៅអោយទៅធ្វើការនៅសិប្បកម្មឡឥដ្ឋ ហើយការជួលកុមារអោយធ្វើការនៅសិប្បកម្មឡឥដ្ឋដោយនិយោជកជាច្រើន ត្រូវបានគេសង្ស័យថានៅតែបន្ត។

អង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជាបានផ្តួចផ្តើមការសិក្សាស្រាវជ្រាវមួយ ដែលជាផ្នែកនៃយុទ្ធនាការប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជា ដើម្បីស្វែងយល់អោយកាន់តែប្រសើរឡើង អំពីមូលហេតុនានាជុំវិញពលករកុមារដែលធ្វើការនៅសិប្បកម្មឡឥដ្ឋ អំពីស្ថានភាពការងាររបស់ពលករកុមារ និងអំពីផលប៉ះពាល់ទៅលើការលូតលាស់របស់កុមារ។ ជាពិសេសការសិក្សានេះសំដៅប្រមូលទិន្នន័យ ដើម្បីពណ៌នាពីស្ថានភាពគ្រួសារ និងស្ថានភាពការងាររបស់ពលករកុមារនៅសិប្បកម្មឡឥដ្ឋ រួមមាន មូលហេតុដែលគេធ្វើការ មូលហេតុដែលគេអនុញ្ញាតិអោយកុមារធ្វើការ មូលហេតុដែលគេជួលកុមារ និងផលប៉ះពាល់នៃពលកម្មកុមារទៅ លើការអភិវឌ្ឍន៍សង្គម ផ្លូវចិត្ត និងរូបកាយរបស់កុមារ។ លទ្ធផលនៃការសិក្សានេះត្រូវបានរំពឹងទុកថានឹងរួម ចំណែកផ្តល់ការយល់ដឹងអោយបានកាន់តែប្រសើរអំពីពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋ និងរួមចំណែកក្នុងយុទ្ធនាប្រយុទ្ធប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជា។

## គោលបំណងនៃការសិក្សា

គោលបំណងនៃការស្រាវជ្រាវនេះរួមមាន :

១. ពណ៌នាអំពីលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅរបស់ពលករកុមារដែលកំពុងធ្វើការនៅសិប្បកម្ម ឡឥដ្ឋ

២.កំណត់រកកត្តាដែលជះឥទ្ធិពលលើការលូតលាស់របស់កុមារ ដូចជា ការអប់រំ សុខភាព និងសុវត្ថិភាពរបស់កុមារនៅសិប្បកម្មឡឥដ្ឋ

៣. វិភាគពីមូលហេតុ ថាតើហេតុអ្វីនិយោជកជួលកុមារអោយធ្វើការ

៤. វិភាគពីមូលហេតុ ថាតើហេតុអ្វីមាតាបិតាអនុញ្ញាតិអោយកូនរបស់គាត់ធ្វើការនៅសិប្បកម្មឡឥដ្ឋ

៥. វិភាគពីមូលហេតុ ថាតើហេតុអ្វីកុមារទទួលធ្វើការងារនៅសិប្បកម្មឡឥដ្ឋ

៦. ផ្តល់អនុសាសន៍អំពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋ។

# ជំពូកទី២: ការពិនិត្យមើលឡើងវិញនូវឯកសារ

## ១. ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ពលកម្មកុមារសំដៅដល់គ្រប់ទម្រង់ការងារទាំងអស់ដែលធ្វើដោយកុមារអាយុក្រោម ១៨ឆ្នាំ។ ពលកម្មកុមារ គឺជាបញ្ហាសេដ្ឋកិច្ច និងសង្គមមួយនៅក្នុងប្រទេសកំពុងអភិវឌ្ឍនានា ពីព្រោះកុមារត្រូវបានគេយល់ឃើញថាជាប្រភពដ៏សំខាន់នៃចំណូលគ្រួសារទាំងមូល។ ការសិក្សាដែលមានស្រាប់បង្ហាញថា ការងារស្រាលអាចមានលទ្ធផលជាវិជ្ជមានចំពោះការអភិវឌ្ឍន៍របស់កុមារ ដោយសារវាផ្តល់បទពិសោធន៍ កសាងទំនុកចិត្ត ដល់កុមារ និងផ្តល់ការគាំទ្រ ឬមធ្យោបាយ ផ្នែកហិរញ្ញវត្ថុមួយចំនួនផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ការងារកុមារ អាចទទួលយកបានតែក្នុងករណីដែលគ្មានគ្រោះថ្នាក់ដល់សុខភាព និង ការអភិវឌ្ឍន៏ផ្នែកផ្លូវចិត្តរបស់កុមារប៉ុណ្ណោះ (ILO, ឆ្នាំ១៩៩៩)[១]។ ទម្រង់មួយចំនួននៃពលកម្មកុមារ អាចបណ្តាលអោយ មានភាពទន់ខ្សោយដល់ការអភិវឌ្ឍន៏ផ្នែកសរីរាង្គកាយ និងស្មារតីរបស់កុមារ។ ជាញឹកញាប់ កុមារជាច្រើនដែលធ្វើការជា ធម្មតាមិនបានចូលរៀនទេ ។ អនុសញ្ញា ILO លេខ១៨២ ចែងថា ពលកម្មកុមារដែលរំខានដល់ការសិក្សារបស់កុមារ ត្រូវចាត់ទុកជាពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុត (ILO, ឆ្នាំ១៩៩៩)។ អនុសញ្ញា ILO លេខ១៨២ អំពាវនាវអោយការហាមប្រាម និងការលុបបំបាត់ជាបន្ទាន់ នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលរំលោភសិទ្ធិអភិវឌ្ឍរបស់កុមារ ។

យោងតាមអនុសញ្ញា ILO លេខ១៨២ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រួមមាន (ក) គ្រប់ទម្រង់ទាំងអស់នៃទាសភាព ឬការអនុវត្តន៏ស្រដៀងនឹងទាសភាព ដូចជា ការលក់ និងជួញដូរកុមារ ធ្វើការដោះបំណុល និងភាព ជាខ្ញុំកញ្ជះព្រមទាំងពលកម្មដោយបង្ខំ ឬជាកាតព្វកិច្ច ដូចជាការជ្រើសរើសដោយបង្ខំ ឬជាកាតព្វកិច្ចនូវកុមារ ដើម្បីបម្រើ ក្នុងជម្លោះប្រដាប់អាវុធ (ខ) ការប្រើប្រាស់ អូសទាញ ឬផ្តល់កុមារអោយបម្រើការនៅក្នុងពេស្យាកម្ម សម្រាប់ ផលិតរូបភាព អាសគ្រាមឬសម្រាប់សម្តែងសិល្បៈអាសគ្រាម (គ) ការប្រើប្រាស់អូសទាញ ឬផ្តល់កុមារសម្រាប់ សកម្មភាពខុសច្បាប់ ជាពិសេស សម្រាប់ផលិត និងជួញដូរ គ្រឿងញៀន ដូចបានកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិដែល ពាក់ព័ន្ធ (ឃ) ការងារ ដែលតាមលក្ខណៈ របស់ការងារនោះ ឬស្ថានភាពដែលគេអនុវត្តការងារនោះអាចមានគ្រោះថ្នាក់ ដល់សុខភាពសុវត្ថិភាព ឬសីលធម៌ របស់កុមារ (ILO, ឆ្នាំ១៩៩៩)។

ទិន្នន័យដែលអាចទុកចិត្តបានបង្ហាញថា ពលករកុមារក្នុងចំនួនដ៏ច្រើននៅកម្ពុជា ធ្វើការជាច្រើនម៉ោង និងមិនបានចូលរៀនទេ។ ជាក់ស្តែង ប្រហែលជា១៤% ក្នុងចំណោមពលករជាកុមារដែលមានអាយុ ៥-១៧ឆ្នាំ មិនបាន

[១] ILO. 1999 អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ក្រុងហ្សឺណែវ : ILO

ទៅរៀន និងចំនួនពីរភាគបីនៃពលករជាកុមារទាំងអស់ ធ្វើការយ៉ាងហោចណាស់ពី៥ ទៅ ៨ម៉ោង ជារៀងរាល់ថ្ងៃ (តារាង ៥.៦ និង ៨.១២ នៅវិទ្យាស្ថានជាតិស្ថិតិ ២០០២)[២] ។ កុមារដែលធ្វើការច្រើនម៉ោង ឬនៅក្នុងស្ថានភាពគ្រោះថ្នាក់ និងគ្មានអនាម័យ អាចទទួលរងគ្រោះថ្នាក់ផ្នែករាងកាយ និងផ្លូវចិត្តយូរអង្វែង ដែលនាំអោយងាយទទួលរងជំងឺ។ ការងារ ដែលធ្វើអោយកុមារក្លាយជាទាសករ ការជ្រើសរើសដោយបង្ខំ ការងារ ពេស្យាចារ ការជួញដូរ និងការបង្ខំអោយ កុមារធ្លាក់ទៅក្នុងសកម្មភាពខុសច្បាប់ និងការងារមានគ្រោះថ្នាក់ គឺជាឧទាហរណ៍ខ្លះៗនៃទម្រង់ធ្ងន់ធ្ងរបំផុតនៃ ពលកម្មកុមារ (ILO/ IPEC[3], ឆ្នាំ២០០២; WVC[4], ឆ្នាំ២០០៥) ។

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញា ILO លេខ១៨២ នៅខែតុលា ឆ្នាំ២០០៥ ដើម្បីចូលរួម ក្នុងសកម្មភាពអន្តរជាតិ ក្នុងគោលបំណងទប់ស្កាត់ទម្រង់គ្រោះថ្នាក់នៃពលកម្មកុមារ។ ច្បាប់ការងារកម្ពុជា កំណត់អាយុអប្បបរមា១៨ឆ្នាំ ដែលអាចអនុញ្ញាតអោយធ្វើការងារដែលមានលក្ខណៈ អាចបណ្តាលអោយមានគ្រោះថ្នាក់ចំពោះសុខភាព សុវត្ថិភាព ឬសីលធម៌។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះអនុញ្ញាតិអោយកុមារដែលមាន អាយុពី ១២ ទៅ ១៤ឆ្នាំ ធ្វើការងារស្រាលដែលគ្មានគ្រោះថ្នាក់ចំពោះសុខភាពរបស់ខ្លួន និងមិនរំខានដល់ការសិក្សារបស់ខ្លួន (UCW, ឆ្នាំ២០០៦)[៥] ។ យោងតាមប្រកាសលេខ១០៦ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០០៤)[៦] កុមារអាយុក្រោម១៨ឆ្នាំ មិនត្រូវបានអនុញ្ញាតិ អោយប្រើប្រាស់ គ្រឿងម៉ាស៊ីន ឬធ្វើការនៅជិតឡឥដ្ឋ ក្នុងសិប្បកម្មផលិតឥដ្ឋឡើយ ។

សម្រាប់យុទ្ធនាការប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អង្គការទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia-WVC) បានរៀបចំជាគោលការណ៍ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយផ្អែកទៅ តាមករណីថាតើការងារដែលធ្វើដោយកុមារនោះ រំលោភសិទ្ធិរបស់កុមារក្នុងការអភិវឌ្ឍន៍ ឬយ៉ាងណា (LICADHO[7], ឆ្នាំ២០០១; WVC[8], ឆ្នាំ២០០៦) ។ គោលការណ៍នេះចាត់ចំណាត់ថ្នាក់ពលកម្មកុមារដែលស្ថិតក្រោមការហាមប្រាម និងការលុបបំបាត់ នូវទម្រង់ពលកម្មគ្រោះថ្នាក់ស្រាល គ្រោះថ្នាក់ធ្ងន់ និងធ្ងន់ធ្ងរបំផុត ។ ពលកម្មគ្រោះថ្នាក់ស្រាល រួមមាន ការងារដែលកុមារធ្វើមិនពេញម៉ោង ឬធ្វើពេញម៉ោង ប៉ុន្តែរំខានដល់

---

[២] NIS. *ឆ្នាំ២០០២ ការអង្កេតអំពីពលកម្មកុមារនៅកម្ពុជា ឆ្នាំ២០០១ ។* វិទ្យាស្ថានជាតិស្ថិតិ ភ្នំពេញ កម្ពុជា : ក្រសួងផែនការ ។

[៣] *ILO/IPEC, ឆ្នាំ២០០២, ការសិក្សាអំពីកិច្ចការពារស្របច្បាប់ចំពោះកុមារបំរើការងារតាមផ្ទះ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ILO/ជប៉ុន/កូរ៉េ, កិច្ចប្រជុំអាស៊ីស្តីពីវិធានការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារតាមផ្ទះ នៅក្រុងឈៀងម៉ៃ ប្រទេសថៃ ពីថ្ងៃទី០២ ដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២ ។*

[4] WVC, ២០០៥។ តើហេតុអ្វីបានជាយើងធ្វើការ ហើយតើយើងធ្វើការដូចម្តេចៈ ពលករកុមារនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅភ្នំពេញនិងបាត់ដំបង។ របាយការណ៍របស់អង្គការទស្សនៈពិភពលោកនៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ, ភ្នំពេញៈ កម្មវិធីសន្តិភាពនិងយុត្តិធម៌។

[៥] *UCW, ឆ្នាំ២០០៦ ការងាររបស់កុមារនៅកម្ពុជា : បញ្ហាប្រឈមចំពោះការរីកចំរើន និងការកាត់បន្ថយភាពក្រីក្រ របាយការណ៍អន្តរទីភ្នាក់ងារជូនចំពោះរដ្ឋាភិបាល កម្ពុជា ILO/IPEC, UNICEF, និងធនាគារពិភពលោក ។ អាចស្វែងរកបានតាមបណ្តាញអ៊ីនធឺណិត* www.ucw-project.org/ucw/cambodia_rpt.pdf

[៦] *ប្រកាសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការហាមឃាត់កុមារមិនអោយកុមារធ្វើការនៅកន្លែងគ្រោះថ្នាក់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ ។*

[៧] *កញ្ចប់ឯកសារអប់រំ និងតស៊ូមតិ ឯកសារកំពុងស្ថិតក្នុងដំណើរការរៀបចំរបស់អង្គការ LICADHO ឆ្នាំ២០០១ ។*

[៨] *WVC ឆ្នាំ២០០៦។ ការវាយតម្លៃហានិភ័យសុខភាពសាធារណៈ និងទម្លាប់អនុវត្តសុខភាពវិជ្ជមានសម្រាប់កុមារធ្វើការ។* របាយការណ៍រៀបរៀងដោយលោកបណ្ឌិត ប៉ូច ប៊ុណ្ណាក់ សាស្ត្រាចារ្យនិងនាយកនៃ CPS នៅ RUPP សម្រាប់ប្រយុទ្ធប្រឆាំងនឹងទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ខែកក្កដា ឆ្នាំ២០០៦។ អង្គការទស្សនៈពិភពលោកកម្ពុជា ។

ការសិក្សារបស់កុមារ និងអាចបណ្តាលអោយមានរបួសស្រាលប៉ុណ្ណោះ។ ពលកម្មកុមារ ដែលមានគ្រោះថ្នាក់ធ្ងន់ សំដៅដល់ការងារដែលតម្រូវអោយកុមារឈប់រៀន និងធ្វើការពេញម៉ោង ដែលអាចបណ្តាលអោយមានរបួសធ្ងន់ធ្ងរ និងតម្រូវអោយមានការព្យាបាលពីគ្រូពេទ្យ។ ពលកម្មក្នុងទម្រង់ធ្ងន់ធ្ងរបំផុត រួមមាន ការងារពេញម៉ោង ដែលអាចបង្កអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬពិការរយៈពេលវែង និងរំលោភធ្ងន់ធ្ងរ ដល់សិទ្ធិទទួលបានការការពារ ការរស់រានមានជីវិត ការអភិវឌ្ឍន៍ និងការចូលរួម ដូចជា ការងារដោយបង្ខំ សកម្មភាពបម្រើផ្លូវភេទ ឬសកម្មភាពផ្សេងៗដែលខុសច្បាប់ ឬការងារដែលគ្រោះថ្នាក់ដល់អាយុជីវិត។ នៅកម្ពុជា ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុត ក៏រាប់បញ្ចូលការងារនៅតាមឡឥដ្ឋ ការងារនៅតាមចំការកៅស៊ូ ការងារនៅ កន្លែងផលិតអំបិល ការងារសិប្បកម្មកែច្នៃត្រី ការងារលីសែង ការងារបំរើតាមផ្ទះ ការងារពេស្យាចារ ការងារ អាសគ្រាម ការងារសុំទាន និងការងាររើសអេតចាយ ផងដែរ (ILO/IPEC, ឆ្នាំ២០០២ ; WVC, ឆ្នាំ២០០៥)។

### សេចក្តីសង្ខេបនៃទម្រង់ទាំង ៥យ៉ាង នៃការងារ និងពលកម្មកុមារ

| | ប្រភេទ | ម៉ោងធ្វើការ | ការសិក្សា | ហានិភ័យផ្នែកសុខភាព | ការរំលោភសិទ្ធិកុមារ |
|---|---|---|---|---|---|
| ១ | ការងារកំប៉ិកកំប៉ុក | មិនពេញម៉ោង | បាទ/ចាស៎ | ទេ | ទេ |
| ២ | ការងារស្រាល | មិនពេញម៉ោង | បាទ/ចាស៎ | ទេ | ទេ |
| ៣ | ពលកម្មគ្រោះថ្នាក់ស្រាល | មិនពេញម៉ោង/ ពេញម៉ោង | រំខានដល់ ការសិក្សា | របួសស្រាលមិនតម្រូវ អោយមានការថែទាំ ព្យាបាល | រំលោភសិទ្ធិអភិវឌ្ឍន៍ និង សិទ្ធិចូលរួម |
| ៤ | ពលកម្មគ្រោះថ្នាក់ធ្ងន់ | ពេញម៉ោង | ឈប់រៀន | របួសធ្ងន់ធ្ងរ តម្រូវ អោយ មានការព្យាបាល ពីគ្រូពេទ្យ | រំលោភធ្ងន់ធ្ងរទៅលើ សិទ្ធិ ទទួលបានការការពារ សិទ្ធិ រស់រានមានជីវិត សិទ្ធិអភិវឌ្ឍ និងសិទ្ធិ ចូលរួម ។ |
| ៥ | ទម្រង់ធ្ងន់ធ្ងរបំផុតនៃ ពលកម្មកុមារ | ការងារដោយបង្ខំ ឬដោះបំណុល | ឈប់រៀន | គ្រោះថ្នាក់ដល់អាយុជីវិត និង ឬពិការរយៈពេល វែង | |

*ប្រភព : កញ្ចប់ឯកសារអប់រំ និងតស៊ូមតិរបស់អង្គការ LICADHO ឯកសារកំពុងស្ថិតក្រោមដំណើរការរៀបចំ ឆ្នាំ២០០១ ។*

## ២. ហេតុផលនាំអោយមានពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋ

កុមារត្រូវប្រឡូកក្នុងពលកម្មកុមារដោយសារហេតុផលផ្សេងៗ ទោះជាយ៉ាងណាក៏ដោយ ពលករកុមារភាគច្រើនប្រឡូកនៅក្នុងវិស័យកសិកម្ម។ ហេតុផលមួយគឺភាពក្រីក្រ។ កុមារដែលប្រឡូកនៅក្នុងពលកម្មកុមារ អាចមកពី ក្រុមគ្រួសារដែលរងគ្រោះដោយភាពក្រីក្រ ដែលគ្មានអនាម័យ និងអាហារូបត្ថម្ភពុំគ្រប់គ្រាន់ (Woolf[៩], ឆ្នាំ២០០២; WVC ឆ្នាំ២០០៦) ។ របកគំហើញថ្មីៗនេះបង្ហាញថា ការអោយកុមារប្រឡូកនៅក្នុងពលកម្មកុមារ គឺជាការសម្រេចចិត្ត របស់ក្រុមគ្រួសារដើម្បីប្រយុទ្ធនឹងភាពក្រីក្រ (UCW, ឆ្នាំ២០០៦; WVC ឆ្នាំ២០០៦)។

[៩]. Woolf, A., ឆ្នាំ២០០២, “គ្រោះថ្នាក់ផ្នែកសុខភាពចំពោះកុមារនៅពេលធ្វើការ” ទស្សនាវដ្តីអំពីការសិក្សាជាតិពុល និងការសិក្សាជាតិពុលវេជ្ជសាស្ត្រ 40(4): 477-482 ។

យោងតាមទិន្នន័យដែល ទទួលបានពីការអង្កេតពលកម្មកុមារនៅកម្ពុជា ឆ្នាំ២០០១ (Cambodia Child Labour Survey ឆ្នាំ២០០១-CCLS) ចំនួនប្រហែលជាបីភាគបួននៃក្រុមគ្រួសារដែលអោយកុមារប្រឡូក នៅក្នុងប្រភេទខ្លះនៃពលកម្មកុមារ គឺដោយសារ បញ្ហាលំបាក ផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ ហើយប្រហែលជា ៥០% នៃគ្រួសារទាំងនោះ មានជំនឿថា កម្រិតជីវភាពរបស់ខ្លួន អាចនឹងធ្លាក់ចុះ ប្រសិនបើកុមារឈប់ធ្វើការ (UCW, ឆ្នាំ២០០៦) ។

ភាពក្រីក្រមានទំនាក់ទំនងយ៉ាងរឹងមាំ ដោយផ្ទាល់ និងទៅវិញទៅមកទៅនឹងការសិក្សារបស់កុមារ។ ជាបឋម កង្វះខាតថវិកាដើម្បីបង់ថ្លៃសាលា និងចំណាយទាក់ទងនឹងការសិក្សា អាចជាកត្តាមួយនាំអោយកុមារចូលប្រឡូកក្នុងពលកម្មកុមារ ក្នុងបំណងដើម្បីរកប្រាក់សម្រាប់បន្តការសិក្សារបស់ខ្លួន។ ការសិក្សាមួយអំពីពលកម្មកុមារដែលធ្វើឡើងសម្រាប់ WVC ដោយមជ្ឈមណ្ឌលសិក្សាអំពីប្រជាជននៅ RUPP បានអោយដឹងថា ៣១.៦%នៃ កុមាររើសសំរាមដែលមកកាន់មណ្ឌលស្នាក់នៅបណ្តោះអាសន្នរបស់ WVC ៣១% នៃពលករកុមារដែលធ្វើការនៅតាម កន្លែងកែច្នៃត្រី និងប្រហែលជា ១០%នៃកុមារដែលធ្វើការនៅតាមសិប្បកម្មឡឥដ្ឋ បានចូលប្រឡូកក្នុងពលកម្ម ដោយសារ ហេតុផល នៃភាពក្រីក្រ (WVC, ឆ្នាំ២០០៦)។ ទីពីរ កុមារដែលធ្វើការអាចនឹងឈប់រៀន នៅពេលអនាគត។ ពួកគេឈប់រៀនដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត ដើម្បីរកប្រាក់សម្រាប់គ្រួសារ ឬដើម្បីជួយធ្វើការងារគ្រួសារ។ ការសិក្សាថ្មីៗនេះ អំពីពលករកុមារនៅក្រុងភ្នំពេញ និងខេត្តបាត់ដំបង បានរកឃើញថា ៦៦% នៃពលករកុមារ ដែលមាន អាយុពី ៥ ទៅដល់ ១៧ឆ្នាំ មិនបានចូលរៀនទេ ហើយភាគច្រើននៃកុមារទាំងនោះត្រូវបានរាយការណ៍ថា បានដកខ្លួនពីការសិក្សា ដើម្បីចូលប្រឡូកក្នុងកម្លាំងពលកម្ម ដោយសារឪពុកម្តាយរបស់ខ្លួន។ សមាមាត្រនៃការបោះបង់ការសិក្សាក្នុងចំណោមពលករកុមារនៅតាមសិប្បកម្មឡឥដ្ឋ ត្រូវបានរកឃើញថាមានកម្រិតខ្ពស់ជាងកុមារ ដែលធ្វើការ ងារផ្សេងៗ ទៀត (WVC, ឆ្នាំ២០០៦)។ ដោយរំពឹងថានឹងមានការរួមចំណែកជាវិជ្ជមាននៃពលកម្មកុមារ ចំពោះសុខមាលភាពគ្រួសារនោះ ឪពុកម្តាយមួយចំនួនបង្ខំអោយកូនរបស់ខ្លួនធ្វើការ ដើម្បីអោយពួកគេជួយការងារគ្រួសារប្រចាំថ្ងៃដើម្បីជួយគ្រួសាររកប្រាក់សងបំណុល ឬដើម្បីមានទីកន្លែងស្នាក់នៅ (WVC, ឆ្នាំ២០០៥ ; WVC ឆ្នាំ២០០៦)។

ជាងនេះទៅទៀត បរិយាកាសគ្រួសារក៏អាចជាកត្តាមួយដែលលើកទឹកចិត្តអោយកុមារធ្វើការ ឬរារាំងកុមារមិនអោយធ្វើការនៅក្រៅផ្ទះរបស់ខ្លួនផងដែរ។ គ្រួសារមួយចំនួនអាចមានអំពើហិង្សា ហេតុដូច្នេះហើយពុំមានលទ្ធភាពផ្តល់បរិយាកាសមានសុវត្ថិភាព និងការការពារដល់កុមារទេ។ គ្រួសារខ្លះទៀត អាចញៀននឹងការលេងល្បែង ឬប្រើប្រាស់គ្រឿងស្រវឹង។ ក្នុងករណីបែបនេះ កុមារអាចត្រូវបង្ខំអោយធ្វើការដោយស្ម័គ្រចិត្តគ្រាន់តែដើម្បីចៀសអោយផុតពី បរិយាកាសគ្រួសារអាប់អួរ ឬបង្ខំចិត្តទៅរកប្រាក់សម្រាប់គ្រួសារ។ ហេតុផលនេះ មានចងក្រងជាឯកសារយ៉ាងល្អដោយអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយពលករកុមារ ដូចជា WVC និងអង្គការមាតុភូមិ កុមារ ជាដើម (WVC, ឆ្នាំ២០០៦)។

ហេតុផលមួយទៀតនោះ គឺពលកម្មកុមារមានតម្លៃទាប។ ពលកម្មកុមារដែលមានតម្លៃទាប នៅតាមទីផ្សារការងារ រួមចំណែកដល់ការកើនឡើងនៃចំនួនពលករកុមារ និងការជួញដូរកុមារ នៅក្នុងផ្នែកផ្សេងៗនៃសេដ្ឋកិច្ច។ យោងតាម CCLS ឆ្នាំ២០០១ ហេតុផលសំខាន់បំផុតបី ដែលគ្រឹះស្ថានអាជីវកម្មនានាយកកុមារអាយុក្រោម១៨ឆ្នាំអោយធ្វើការ រួមមាន ភាពសមស្របរបស់កុមារសម្រាប់ការងារ (៤៤%នៃហេតុផលទាំងអស់ដែលយកកុមារអោយធ្វើការ) កង្វះខាតកម្មករដទៃទៀត (១៧,៦%) និងអវត្តមាននៃសហជីពកម្មករ (១៥,៦%) (តារាង ៨.២ នៅវិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០២) ។ ហេតុផលទាំងនេះ បង្ហាញអោយឃើញ ពីស្ថានភាពដែលនិយោជកត្រូវស្វែងរកពលករដែលពុំសូវមានជំនាញ តម្លៃពលកម្មថោក និងពលករកុមារ ដែលគ្មានការការពារ ។

## ៣. ផលប៉ះពាល់នៃពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋទៅលើការអភិវឌ្ឍរបស់កុមារ

កុមារចាប់ផ្តើមធ្វើការតាំងពីវ័យក្មេង ។ យោងតាមការសិក្សាមួយអំពីពលកម្មកុមារនៅខេត្តបាត់ដំបង (WVC, ឆ្នាំ២០០៦) អាយុមធ្យមនៅពេលចាប់ផ្តើមធ្វើការ គឺ១៤ឆ្នាំ សម្រាប់ពលករកុមារ នៅតាមសិប្បកម្មឡឥដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ មានកុមារជាច្រើនបានធ្វើការនៅកន្លែងផ្សេងៗទៀត មុននឹងចាប់ ធ្វើការងារដែលបាន ឋកម្រែនៅតាម សិប្បកម្មឡឥដ្ឋ។

អាយុដែលកុមារចាប់ផ្តើមធ្វើការ ទាក់ទងនឹងផលប៉ះពាល់នៃពលកម្មកុមារដែលមាន គ្រោះថ្នាក់ធ្ងន់ទៅលើការអភិវឌ្ឍន៍របស់កុមារ។ កុមារកាន់តែឆាប់ចាប់ផ្តើមធ្វើការកាលណា កាន់តែងាយរងគ្រោះថ្នាក់ការងារ ជាបន្តបន្ទាប់យូរអង្វែង កាលណោះហើយកុមារកាន់តែងាយទទួលរងឥទ្ធិពលមិនល្អដោយសារគ្រោះថ្នាក់ការងារជាក់លាក់ណាមួយផងដែរ។ ចំណុចទីមួយ បើប្រៀបធៀប ជាមួយមនុស្សចាស់ កុមារមានលក្ខណៈ ខុសគ្នាផ្នែកចិត្តសាស្ត្រ និងភាពចាស់ទុំ។ ចំណុចទីពីរ កុមារមានភាពក្មេងខ្ចី ពុំអាចយល់ដឹងអំពីហានិភ័យ ដែលអាចកើតមានឡើងនៅកន្លែងធ្វើការទេ ។ ចំណុចទីបី កុមារអាចត្រូវបានកេងប្រវ័ញ្ច និងរំលោភបំពានកាន់តែងាយស្រួល។ ការធ្វើការនៅក្នុងឧស្សាហកម្មបែបលាក់កំបាំង និងគ្មានរបៀបរៀបរយត្រឹមត្រូវ ដូចជានៅតាមសិប្បកម្មឡឥដ្ឋជាដើម ធ្វើអោយកុមារកាន់តែងាយរងគ្រោះពីការកេងប្រវ័ញ្ច និងការរំលោភបំពាន ដូចជា ការធ្វើការងារច្រើនម៉ោង និងការងារដែលមានហានិភ័យជាដើម។

ដោយសារលក្ខណៈផ្នែករាងកាយ និងស្មារតីខុសប្លែករបស់គេ បទពិសោធន៍តិចតួចរបស់ពួកគេអំពីការងារ និង ការយល់ដឹងតិចតួចរបស់ពួកគេអំពីសក្តានុពលនៃហានិភ័យដែលអាចកើតមានឡើងទាក់ទងនឹងការងារដែលគេធ្វើនោះ កុមារងាយទទួលរងបញ្ហាសុខភាពទាក់ទងនឹងការងារផ្សេងៗ ដូចជារបួស និងជំងឺជាដើម ជាងមនុស្សចាស់នៅពេលធ្វើការងារដូចគ្នា (Ashagrie, ឆ្នាំ១៩៩៨)[១០] ។

[១០]. *Ashagrie, Kebebew, ឆ្នាំ១៩៩៨, ស្ថិតិសង្ខេបស្តីពីកុមារធ្វើការ និងពលកម្មកុមារមានគ្រោះថ្នាក់ ក្រុងហ្សឺណែវ ILO.*

ស្ថានភាពគ្រោះថ្នាក់នៃពលកម្មកុមារ គួបផ្សំនឹងភាពក្មេងខ្ចីរបស់កុមារ បង្កើនអោយមានហានិភ័យនៃរបួសការងារ និងជំងឺផ្សេងៗក្នុងចំណោមពលករកុមារ។ ទម្រង់ពីរយ៉ាងនៃគ្រោះថ្នាក់សុខភាព រួមមានគ្រោះថ្នាក់ទាក់ទងនឹងការងារ និងជំងឺ។ របួសដែលច្រើនតែកើតមាន រួមមានការមុត របួស និងមុតធ្លុះ។ របួសធ្ងន់ធ្ងរ ប៉ុន្តែមិនសូវកើតមានផ្សេងទៀត រួមមានការរលាក បាក់ឆ្អឹង ឬថ្លោះគ្រេច ការបាត់បង់អវៈយវៈ ខ្វាំ ជាំ ហូរឈាម និងដាច់រលាត់ ជាដើម ។ ការសិក្សាមួយ ដែលធ្វើឡើងដោយ Pinder (ឆ្នាំ២០០០)[១១] អំពីរបួសការងារក្នុងចំណោមពលករកុមារនៅតាមសិប្បកម្មឡឥដ្ឋ បង្ហាញអោយឃើញថា កម្រិតនៃបញ្ហានៅក្នុង ឆ្អឹងសន្លាក់នៅតាមកដៃ និងប្រអប់ដៃ និងឆ្អឹងខ្នងផ្នែកខាងក្រោមរបស់កម្មករ រៀបឥដ្ឋ មានលក្ខណៈធ្ងន់ធ្ងរជាងកម្រិតដែលបានរាយការណ៍ដោយក្រុមកុមារធ្វើការដទៃទៀតឆ្ងាយណាស់ ។

ផ្អែកតាមការសិក្សាមួយនៅបាត់ដំបង (WVC, ឆ្នាំ២០០៦) ពលករកុមារធ្វើការនៅតាមសិប្បកម្មឡឥដ្ឋត្រូវបានរកឃើញថា បានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេផ្នែកសុខភាពដោយសារពលកម្ម បើប្រៀបធៀបជាមួយកុមាររើសសំរាម កុមារធ្វើការនៅតាមសិប្បកម្មកែច្នៃត្រី និងកុមារនៅកន្លែងលាងឡាន។ ជាក់ស្តែង ៦៥%នៃកុមារដែលបានផ្តល់សម្ភាសន៍ បានរាយការណ៍ថាមានជំងឺ ឬរងរបួសយ៉ាងហោចណាស់ ៩ដង នៅអំឡុងពេលបំពេញការងាររបស់ខ្លួន ធៀបទៅនឹងកម្មករដែលធ្វើការប្រភេទដទៃទៀតដែលមានចំនួនតែ ៥០% ប៉ុណ្ណោះ។ ជាងនេះទៅទៀត ពលករកុមារចំនួន ៨៥% នៅតាមសិប្បកម្មឡឥដ្ឋដែលបានសម្ភាសន៍ ធ្លាប់មានជំងឺ វិលមុខអស់កម្លាំង មុត និងរបួស ដោយសារការងារហួសកម្លាំង លើកដាក់ឥដ្ឋ ឥដ្ឋធ្លាក់លើជើង ដែលបង្កអោយមានការមុត របួស ឬហើមប៉ោងបន្តិចបន្តួច។ បញ្ហាសុខភាពដទៃទៀតដែលកុមារទាំងនោះ តួញត្អែរជាញឹកញាប់នោះ រួមមាន ឈឺខ្លួន ឈឺខ្នង ជំងឺសើស្បែក បញ្ហាភ្នែក ឈឺក្បាល រាករូស និងបញ្ហាផ្លូវដង្ហើម (អាចបណ្តាលមកពីការធ្វើការងារធ្ងន់ នៅក្នុងលក្ខខណ្ឌការងារគ្មានអនាម័យ)។

ជាងនេះទៅទៀត មានការងារខ្លះនៅតាមសិប្បកម្មឡឥដ្ឋ ដូចជាការរៀបឥដ្ឋនៅដើម្បីសម្ងួត ការយកឥដ្ឋចេញពីឡក្តៅ និងការដុតកំដៅឥដ្ឋជាដើម សុទ្ធតែធ្វើក្នុងបរិយាកាសក្តៅ ។ ការប៉ះពាល់ខ្លាំងពេក ទៅនឹងបរិយាកាសការងារ ក្តៅអាចបង្កអោយមានបញ្ហាសុខភាពបណ្តាលមកពីកំដៅ ដូចជាការសន្លប់ដោយសារត្រូវកំដៅ ការអស់កម្លាំងដោយ សារកំដៅ ការវិលមុខដោយសារកំដៅ កន្ទួលរមាស់ដោយសារកំដៅ ឬការចុះខ្សោយកម្លាំងបណ្តោះអាសន្នដោយសារកំដៅ ជាដើម។

លើសពីនេះទៅទៀត ផលប៉ះពាល់អវិជ្ជមាននៃពលកម្មកុមារទៅលើសុខភាពកុមារ មានផលវិបាកគួរអោយព្រួយបារម្ភទៅលើការអភិវឌ្ឍផ្នែកស្មារតីរបស់កុមារ។ ផ្នែកចិត្តសាស្ត្រអវិជ្ជមាន រួមមានលទ្ធផលសិក្សាថយចុះ ការចូលរួមក្នុង សកម្មភាពក្រៅកម្មវិធីសិក្សា និងសង្គមធ្លាក់ចុះ ការប្រើប្រាស់គ្រឿងស្រវឹងកើនឡើង និងការ

---

[១១]. Pinder, Andrew D.J., ឆ្នាំ២០០០ *ឯកសារគ្រប់គ្រងនៅក្នុងឧស្សាហកម្មផលិតឥដ្ឋ : លទ្ធផលនៃការសិក្សាអំពីទំនាក់ទំនងរវាងមនុស្ស និងការងារនៃការទុកដាក់ ឥដ្ឋ* មន្ទីរពិសោធន៍សុខភាព និងសង្គម : ក្រុមកត្តាមនុស្ស ចក្រភពអង់គ្លេស ។ អាចរកមើលបាននៅតាមបណ្តាញអ៊ិនធឺណិត ខែមិថុនា ឆ្នាំ២០០៦ : http://www.hse.gov.uk/research/hsl_pdf/2000/hsl00-20.pdf.

ទទួលដំណោក មិនបាន គ្រប់គ្រាន់ជាប់ជាប្រចាំ (NIOSH, ឆ្នាំ១៩៩៧)[១២] ។ ដូចបានពោលខាងដើមរួចមកហើយ ការឈប់រៀន គឺជា ផលវិបាក ដ៏រាលដាលមួយនៃការឆាប់ប្រឡូកក្នុងពលកម្មកុមារតាំងពីវ័យក្មេងរបស់កុមារ ។

គួរកត់សម្គាល់ថា ការសិក្សាអំពីផលប៉ះពាល់នៃពលកម្មកុមារទៅលើការអភិវឌ្ឍរបស់កុមារ ពិតជាមានការលំបាក ចំណែកឯរបកគំហើញ ស្ទើរតែពុំមានលក្ខណៈប្រាកដប្រជា ដោយសារទំនាក់ទំនងនៃសុខភាពរបស់កុមារ និងអវត្តមាននៃក្រុមប្រៀបធៀប ក៏ដូចជាភាពស្មុគស្មាញនៃទំនាក់ទំនងក្នុងចំណោមបាតុភូតទាំងនេះ (O’Donnell, Van Doorslaer, និង Rosati, ឆ្នាំ២០០២)[១៣] ។ កុមារខ្លះមានភាពងាយរងគ្រោះខ្លាំងជាងកុមារដទៃទៀត ទោះបីមិនធ្វើការក៏ដោយ។ ជាងនេះទៅទៀត ការសិក្សានានា ដូចជាការសិក្សារបស់ (WVC, ឆ្នាំ២០០៦) គឺផ្អែកទៅលើទំហំសំណាកដ៏តូចដែល អាចផ្តល់លទ្ធផលមិនសូវមានភាពអាចទុកចិត្តបាន។

ការពិនិត្យមើលឡើងវិញខាងលើនេះ បង្ហាញថា កុមារប្រឡូកក្នុងពលកម្មកុមារ ដោយសារមូលហេតុផ្សេងៗ រួមមាន ចាប់តាំងពីតម្រូវការធ្វើការងារដើម្បីរស់ រហូតដល់ការជួញដូរ និងការរំលោភបំពានកុមារ ចំណែកឯផលប៉ះពាល់របស់ពលកម្ម កុមារតាំងពីវ័យក្មេង អាចមានអន្តរាយដល់គ្រប់ផ្នែកនៃការអភិវឌ្ឍរបស់កុមារ។ ដូច្នេះ ការព្យាយាមលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវធ្វើអោយស្របទៅនឹងមូលហេតុ ឫសគល់នៃការចូលប្រឡូករបស់កុមារ នៅក្នុងពលកម្មកុមារ ។ ម្យ៉ាងទៀត ការស្វែងយល់អំពីបុព្វហេតុ នៃពលកម្មកុមារ អាចជួយរៀបចំយុទ្ធសាស្ត្រដ៏មាន ប្រសិទ្ធភាពសម្រាប់យុទ្ធនាការ និងសកម្មភាពប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

---

[១២]. NIOSH, ឆ្នាំ១៩៩៧, *តម្រូវការផ្អែកស្រាវជ្រាវអំពីពលកម្មកុមារ : អនុសាសន៍ពីវិទ្យាស្ថានជាតិស្ថិតិសម្រាប់សុវត្ថិភាព និងអនាម័យការងារ* ក្រសួងសុខាភិបាលសហរដ្ឋអាមេរិក និងសកម្មភាពមនុស្សជាតិ និង CDC ។ អាចរកបានតាមបណ្តាញអ៊ីនធឺណិត http://www.cdc.gov/niosh/97-143a.html.

[១៣]. O’Donnell, Owen, Eddy Van Doorslaer, និង Furio C. Rosati, ឆ្នាំ២០០២ ។ "ពលកម្មកុមារ និងសុខភាព : ភស្តុតាង និងបញ្ហាស្រាវជ្រាវ" ។ *"ការស្វែងយល់អំពីការងារកុមារ : គម្រោងសហការស្រាវជ្រាវអន្តរទីភ្នាក់ងារ* ។ ILO, UNICEF, និង ធនាគារពិភពលោក ។

# ជំពូកទី៣ៈ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ផ្អែកលើការអង្កេតដែលរៀបចំឡើងដើម្បីប្រមូលទិន្នន័យពណ៌នាអំពីលក្ខណៈសំខាន់របស់ពលករកុមារដែលធ្វើការនៅសិប្បកម្មឡឥដ្ឋ អំពីមូលហេតុដែលពួកគេធ្វើការនៅសិប្បកម្មឡឥដ្ឋ, ប្រភេទការងារដែលពួកគេធ្វើ, ការប្រឈមនឹងលក្ខខណ្ឌការងារដែលមានគ្រោះថ្នាក់ និងអំពីចំណេះដឹង និងការដឹងអំពីការងារដែលអាចមានគ្រោះថ្នាក់ និងវិធានការណ៍សុវត្ថិភាពការងារនៅកន្លែងធ្វើការរបស់ពួកគេ។

កន្លែងស្រាវជ្រាវសំរាប់ការសិក្សានេះ គឺនៅស្រុកបាត់ដំបង និងស្រុកសង្កែ ដែលជាតំបន់នៅជុំវិញទីប្រជុំជនខេត្តបាត់ដំបង។ កន្លែងនេះត្រូវបានគេស្គាល់ថា ជាកន្លែងសិប្បកម្មឡឥដ្ឋដែលមានកុមាររស់នៅតាមភូមិជិតៗជាច្រើន មកធ្វើការ។ មានសិប្បកម្មឡឥដ្ឋចំនួន៣២ ដែលបានរកឃើញនៅកន្លែងនេះ[១៤] ។

## ១. ការជ្រើសរើសសំណាក និងសំណាក

ទិន្នន័យសំរាប់ការសិក្សានេះត្រូវបានប្រមូលចេញពីប្រភពបី : ពលករកុមារ, មាតាបិតា, និងម្ចាស់ឬមេការ សិប្បកម្មឡឥដ្ឋ។

### *១.១ សំណាកពលករកុមារ*

ចំពោះការសិក្សានេះ ពលករកុមារសំដៅលើកុមារអាយុក្រោម១៨ឆ្នាំ ហើយធ្វើការនៅសិប្បកម្មឡឥដ្ឋបានយ៉ាងតិចរយៈពេល ៣ខែ។ នៅដើមដំបូង ការសិក្សានេះមានគំរោងប្រើប្រាស់វិធីបណ្តុំដើម្បីជ្រើសរើសសិប្បកម្មឡឥដ្ឋ និងប្រើវិធីជ្រើសរើសជាប្រព័ន្ធ ដើម្បីជ្រើសរើសយកពលករកុមារចំនួន ១៥០នាក់ចេញពីសិប្បកម្មឡឥដ្ឋដែលបានជ្រើសរើសទាំងនោះ។ ក៏ប៉ុន្តែចំនួនកុមារជាក់ស្តែងនៅតាមឡឥដ្ឋនានា មានតិចជាងចំនួនដែលបានទទួល និង រំពឹងទុក។ ដូច្នេះវិធីសាស្ត្រខាងលើមិនអាចអនុវត្តបានទេ ហើយត្រូវប្តូរទៅជាវិធីសាស្ត្រជ្រើសរើសតាមគោលបំណងវិញ។

វិធីនេះតំរូវអោយចុះពិនិត្យគ្រប់សិប្បកម្ម ហើយសិប្បកម្មណាដែលមានកុមារធ្វើការត្រូវបញ្ចូលក្នុងសំណាក របស់ការសិក្សានេះ។ ជាលទ្ធផលយើងជ្រើសរើសបាន ២៦សិប្បកម្ម រីឯសិប្បកម្មចំនួន ៦ផ្សេងទៀតមិនបានបញ្ចូលក្នុងសំណាកឡើយ ដោយសារតែរកពុំឃើញមានពលករកុមារនៅពេលចុះសម្ភាសន៍ ឬម្ចាស់សិប្បកម្មមិនអនុញ្ញាតិអោយចូលសម្ភាសន៍។

---

[១៤] នៅឆ្នាំ១៩៩៩ មានសិប្បកម្មឡឥដ្ឋចំនួន២៦នៅបាត់ដំបង។ ជាប់ពីពេលនោះមក មានសិប្បកម្មខ្លះ ត្រូវបានបិទទ្វារ ហើយមានសិប្បកម្មថ្មីៗទៀតមានបង្កើត។ តាមទិន្នន័យរបស់ក្រសួងឧស្សាហកម្ម ថាមពល និងរ៉ែ មានសិប្បកម្មឡឥដ្ឋចំនួន៣៤ បានចុះបញ្ជីនៅខេត្ត បាត់ដំបងដែលភាគច្រើនមានទីតាំងនៅស្រុកបាត់ដំបង និងស្រុកសង្កែ (http://www.mime.gov.kh/khmer/businessdirectory.asp)

ការជ្រើសរើសពលករកុមារដើម្បីសម្ភាសន៍ គឺអាស្រ័យទៅលើចំនួនពលករកុមារដែលជួបប្រទះជាក់ស្តែង នៅតាមសិប្បកម្មនិមួយៗ ដោយមានលក្ខខណ្ឌថា តាមសិប្បកម្មនិមួយៗត្រូវសម្ភាសន៍ពលករកុមារយ៉ាងច្រើនបំផុត ត្រឹមចំនួន ៨នាក់។ បើសិប្បកម្មមានកុមារលើសពី ៨នាក់កំពុងធ្វើការ វិធីជ្រើសរើសជាលក្ខណៈប្រព័ន្ធត្រូវយកមក ប្រើ ក្នុងការជ្រើសរើសពលករកុមារដើម្បីធ្វើការសម្ភាសន៍។ ជាលទ្ធផល ពលករកុមារចំនួន ១៣៤នាក់មកពីសិប្ប-កម្មចំនួន២៦ ត្រូវបានសម្ភាសន៍ ដែលគិតជាមធ្យមមានពលករកុមារចំនួន៥នាក់ ក្នុងសិប្បកម្មនិមួយៗត្រូវបាន សម្ភាសន៍។ កម្រងសំណួរដែលត្រឹមត្រូវ និងបញ្ចប់គ្រប់គ្រាន់មានចំនួន១៣២ សំរាប់ការវិភាគ។

### ១.២ សំណាកមាតាបិតារបស់ពលករកុមារ

មាតាបិតាពីរក្រុមជាមុខព្រួញនៃការសិក្សា : ជាមាតាបិតារបស់ពលករកុមារដែលរស់នៅឡឥដ្ឋ ឬមនុស្ស ពេញវ័យ ដែលកំពុងធ្វើការនៅឡឥដ្ឋ។ ក្រុមនេះមិនចាំបាច់ជាមាតាបិតារបស់ពលករកុមារសម្ភាសន៍ឡើយ ព្រោះ ការជ្រើសរើសក្រុម នេះមិនអាស្រ័យទៅនឹងពលករកុមារឡើយ។ ក្រុមទីពីរ ជាមាតាបិតាពលករកុមារ ដែលរស់ នៅតាមភូមិ។ ពួកគេត្រូវបានជួបសម្ភាសន៍ តាមរយៈព័ត៌មានដែលពលករកុមារបានផ្តល់អោយ។ ជាសរុប មាតា បិតាចំនួន៤៣នាក់ ក្នុងចំនោម៥០នាក់ ត្រូវបានសម្ភាសន៍។

### ១.៣ សំណាកម្ចាស់ ឬមេការសិប្បកម្ម

ម្ចាស់ឬមេការនៃសិប្បកម្មទាំងអស់ដែលបានជ្រើសរើស ត្រូវបានសុំអនុញ្ញាតិអោយចូលរួមផ្តល់ការ សម្ភាសន៍។ ក្នុងចំណោមសិប្បកម្មទាំង ២៦ខាងលើ មានតែមេការ ឬម្ចាស់សិប្បកម្មចំនួន ១៨ប៉ុណ្ណោះ ដែល យល់ព្រមធ្វើសម្ភាសន៍ តែ ក្នុងនោះមានតែ១៥នាក់ប៉ុណ្ណោះដែលបានបញ្ចប់ការសម្ភាសន៍។

## ២. ឧបករណ៍ស្រាវជ្រាវ

ទិន្នន័យត្រូវបានប្រមូលដោយប្រើកម្រងសំណួរបីប្រភេទ បង្កើតឡើងសំរាប់ការសិក្សានេះ។ កម្រងសំណួរ ទីមួយ សំរាប់ពលករកុមារ, ទីពីរសំរាប់មាតាបិតា, និងមេការសិប្បកម្មឡឥដ្ឋ (សូមមើលឧបសម្ព័ន្ធ ១-៣)។ កម្រងសំណួរប្រភេទនីមួយៗ ត្រូវបានតាក់តែងឡើងសំរាប់ការសម្ភាសន៍ដែលបំពេញដោយអ្នកសម្ភាសន៍។ រយៈ ពេលមធ្យម សំរាប់សម្ភាសន៍កុមារគឺ ៤០នាទី, សំរាប់មាតាបិតាគឺ ២៥នាទី, និងសំរាប់ម្ចាស់ រឺមេការគឺ ២០នាទី។

## ៣. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ ធ្វើឡើងនៅក្នុងខែកក្កដា ឆ្នាំ២០០៧។ អ្នកប្រមូលទិន្នន័យ ត្រូវបានចែកជាពីរក្រុម ដឹកនាំ ផ្ទាល់ដោយបុគ្គលិករបស់គំរោងប្រយុទ្ធប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ[១៥] (CWCLP)

[១៥] គំរោងប្រយុទ្ធប្រឆាំងនឹងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ របស់ អង្គការទស្សនៈពិភពលោកកម្ពុជា។

ពីព្រោះ គេស្គាល់ច្បាស់ពីទីកន្លែងសិប្បកម្មឡឥដ្ឋនីមួយៗ។ អ្នកប្រមូលទិន្នន័យទាំងអស់ បានទទួលការហ្វឹកហាត់រយៈពេល១ថ្ងៃ អំពីកម្រងសំណួរ និងរបៀបប្រមូលទិន្នន័យ ដែលធ្វើឡើងនៅការិយាល័យ LICADHO ខេត្តបាត់ដំបង (សូមមើល ឧបសម្ព័ន្ធទី៤ អំពីក្រុមអ្នកប្រមូលទិន្នន័យ)។

## ៤. បញ្ហាក្រមសីលធម៌នៃការស្រាវជ្រាវ

ការអង្កេតបានធ្វើឡើង បន្ទាប់ពីបានទទួលការអនុញ្ញាតិពីសាលាខេត្តបាត់ដំបង។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ ត្រូវបានសួរអោយចូលរួមសម្ភាសន៍ដោយស្ម័គ្រចិត្ត។ កិច្ចព្រមព្រៀងពីការចូលរួមមួយ ត្រូវបានធ្វើ និងអានជូន គ្រប់អ្នកតបសម្ភាសន៍ម្នាក់ៗ ដែលបានជ្រើសរើស[១៦]។ អនាមិកភាព និងការថែរក្សាការសំងាត់របស់អ្នកឆ្លើយ ត្រូវបានធានារាល់គ្រប់អ្នកឆ្លើយទាំងអស់។ ដូចជា គ្មានការកត់ត្រាឈ្មោះអ្នកចូលរួមឆ្លើយឡើយ។ រីឯឈ្មោះសិប្បកម្មឡឥដ្ឋទាំងអស់ត្រូវបានចាត់ទុកជាការសំងាត់ និងមិនបញ្ចេញអោយអ្នកដទៃដឹង ក្រៅពីកុងស៊ុលតង់ឡើយ។

[16] មើលផ្នែកទីមួយនៃគ្រប់កំរងសំនួរ នៅក្នុងឧបសម្ពន្ធ័ ១-៣។

# ជំពូកទី៤: ព័ត៌មានសំខាន់ៗរបស់អ្នកឆ្លើយ

## ១. ព័ត៌មានមូលដ្ឋានរបស់ពលករកុមារ

ព័ត៌មានសំខាន់ៗរបស់ពលករកុមារធ្វើការនៅសិប្បកម្មឡឥដ្ឋ ត្រូវបានសង្ខេបដោយឡែកពីគ្នាចំពោះកុមារ ដែលរស់នៅក្នុងសិប្បកម្ម (ចំនួន៣៦នាក់) និងចំពោះកុមារ ដែលរស់នៅតាមភូមិ តែមកធ្វើការនៅសិប្បកម្មឡឥដ្ឋ (ចំនួន៩៦នាក់) (តារាងទី១) ។ ក្នុងចំណោមពលករកុមារដែលរស់នៅតាមភូមិ គេឃើញមានចំនួនកុមារីច្រើនជាងកុមារា (៧២.៩%ជាកុមារី) ក៏ប៉ុន្តែចំនួនពលករកុមារាមានចំនួនច្រើនជាងពលករកុមារី (៤៤.៤%ជាកុមារី) នៅក្នុងចំណោមពលករកុមារ ដែលរស់នៅតាមឡឥដ្ឋ។ ភាពខុសគ្នាទៅតាមភេទរបស់ពលករកុមារទាំងពីរក្រុមបង្ហាញថា វាជាលក្ខណៈទូទៅមួយសំរាប់កុមារី ដែលរស់នៅតាមភូមិក្បែរៗសិប្បកម្មឡឥដ្ឋ មកធ្វើការនៅតាមសិប្បកម្មទាំងនេះ។

**តារាងទី១ : លក្ខណៈសំខាន់ៗរបស់សំណាកកុមារទៅតាមកន្លែងរស់នៅ**

| | **នៅភូមិ** | **នៅឡឥដ្ឋ** | **សរុប** |
|---|---:|---:|---:|
| **ពលករកុមារបានសំភាសន៍** | ៩៦ | ៣៦ | ១៣២ |
| **ភាគរយកុមារី** | ៧២.៩% | ៤៤.៤% | ៦៥.២% |
| **ក្រុមអាយុ** | | | |
| ក្រោម ១២ឆ្នាំ | 0.0% | ១៣.៩% | ៣.៨% |
| ១២-១៤ឆ្នាំ | ១០.៤% | ២៧.៨% | ១៥.២% |
| ១៥-១៧ឆ្នាំ | ៨៩.៦% | ៥៨.៣% | ៨១.១% |
| **ស្ថានភាពនៃការរស់នៅ** | | | |
| ឪពុកនិងម្តាយបង្កើត | ៦២.៥% | ៦៩.៤% | ៦៤.៤% |
| ឪពុកឬម្តាយបង្កើតតែម្នាក់ | ២១.៩% | ១៣.៩% | ១៩.៧% |
| ឪពុក-ម្តាយបង្កើតនិងឪពុក-ម្តាយចិញ្ចឹម | ៥.២% | 0.0% | ៣.៨% |
| សាច់ញាតិផ្សេងទៀត | ១០.៤% | ១៦.៧% | ១២.១% |
| **ចំនួនបងប្អូនបង្កើត** | | | |
| ១-៣ | ១៣.៧% | ១១.១% | ១៣.0% |
| ៤-៥ | ៤៣.២% | ៤១.៧% | ៤២.៧% |
| លើសពី៥ | ៤៣.២% | ៤៧.២% | ៤៤.៣% |
| **ជាកូនទីមួយក្នុងគ្រួសារ** | ១៧.៧% | ៣៦.១% | ២២.៧% |

បើគិតពីអាយុវិញ ៨៩.៦%នៃពលករកុមាររស់នៅតាមភូមិមានអាយុពី ១៥-១៧ឆ្នាំ។ ចំនួននេះមានត្រឹម៥៨.៣%ប៉ុណ្ណោះក្នុងចំណោមពលករកុមារដែលរស់នៅតាមឡឥដ្ឋ។ នេះបញ្ជាក់ថាមានពលករកុមារវ័យក្មេងច្រើន ដែលកំពុងរស់នៅ និងធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ (៤១.៧%មានអាយុក្រោម ១៥ឆ្នាំ)។

លើសពីនេះទៀត ពលករកុមារជាច្រើនរស់នៅក្នុងគ្រួសារមិនបែកបាក់ គឺ៦២.៥%ក្នុងចំណោមកុមាររស់នៅតាមភូមិ និង៦៩.៤%ក្នុងចំណោមកុមាររស់នៅតាមឡឥដ្ឋ។ ពលករកុមារដែលបានសម្ភាសន៍ជាច្រើនរស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន (ជាង៤០%នៃពលករកុមារទាំងនេះមានបងប្អូនលើសពី៥នាក់)ហើយប្រហែលជាមួយភាគបីនៃពលករកុមារដែលរស់នៅតាមឡឥដ្ឋជាកូនច្បងក្នុងគ្រួសារ។

## ២. ព័ត៌មានមូលដ្ឋានរបស់មាតាបិតា ឬមនុស្សពេញវ័យ

មានមនុស្សពេញវ័យចំនួន៤៣នាក់បានសម្ភាសន៍ ក្នុងនោះមាន៣៣នាក់កំពុងរស់នៅ និងធ្វើការនៅឡឥដ្ឋ និង ១០នាក់ទៀតជាមាតាបិតារស់នៅតាមភូមិ។ ភាគច្រើននៃមនុស្សពេញវ័យដែលបានសម្ភាសន៍ជាស្ត្រីរស់នៅក្នុងគ្រួសារមិនបែកបាក់ ហើយមានអាយុជាមធ្យម ៤១ឆ្នាំចំពោះអ្នកនៅតាមឡឥដ្ឋ និង៣៧ឆ្នាំចំពោះអ្នករស់នៅតាមភូមិ។ ជាងនេះទៅទៀត ពួកគេមានកូនចៅច្រើន ដែលជាមធ្យមមានកូន ៥នាក់ចំពោះអ្នកនៅឡឥដ្ឋ និង៣នាក់ចំពោះអ្នកនៅតាមភូមិ។ កូនជាច្រើនរបស់ពួកគេ ធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ ហើយប្រហែលមួយភាគពីរនៃកុមារទាំងនេះអត់ទៅសាលារៀន។ ប្រហែលជាពីរភាគប្រាំនៃចំនួនកូនរបស់អ្នករស់នៅក្នុងឡឥដ្ឋ និងមួយភាគបីនៃកូនរបស់អ្នកនៅតាមភូមិ បាននិងកំពុងធ្វើការនៅឡឥដ្ឋអស់រយៈពេល ២ឆ្នាំតិចបំផុត។ ៥០%នៃឪពុកម្តាយរបស់ពលករកុមារទាំងនេះធ្លាប់ធ្វើការនៅឡឥដ្ឋបានយ៉ាងតិច៥ឆ្នាំមកហើយ ហើយមានប្រាក់ចំណូលជាមធ្យមត្រឹម ២០ម៉ឺនរៀល ឬលើសនេះតែបន្តិចប៉ុណ្ណោះក្នុងមួយខែ។

កំណត់សំគាល់សំខាន់មួយទៀត ផ្អែកលើលទ្ធផលនៃការស្រាវជ្រាវនេះ ដូចបានបង្ហាញក្នុងតារាងទី២ គឺថាភាគ ច្រើននៃមនុស្សពេញវ័យ ដែលរស់នៅ និងធ្វើការនៅឡឥដ្ឋជាជនចំណូលស្រុក ដែលមកពីតំបន់ផ្សេងៗក្នុងខេត្ត បាត់ដំបង ឬមកពីខេត្តដទៃទៀត មានខេត្តស្វាយរៀង ព្រៃវែង ពោធិ៍សាត់ តាកែវ កំពង់ធំ ឬខេត្តកំពង់ស្ពឺ។ ក្រៅពី នេះមានគ្រួសារខ្លះមកពីកម្ពុជាក្រោម និងមកពីជំរុំតាមទល់ដែនកម្ពុជា-ថៃ។

## តារាងទី២ ៖លក្ខណៈសំខាន់ៗរបស់សំណាកឪពុកម្ដាយទៅតាមកន្លែងរស់នៅ

| | នៅឡូតដ្ឋ | នៅភូមិ | សរុប |
|---|---|---|---|
| **ចំនួនឪពុកម្ដាយដែលបានសម្ភាសន៍** | ៣៣ | ១០ | ៤៣ |
| **ភេទ (%ស្ត្រី)** | ៨៧.៩% | ៨០.០% | ៨៨.៤% |
| **អាយុ (មធ្យម)** | ៤១ | ៣៧ | ៤០ |
| **ស្ថានភាពអាពាហ៍ពិពាហ៍ (%គ្រួសារបែកបាក់)** | ៨១.៨% | ៨០.០% | ៨១.៤% |
| **ចំនួនកូន** | | | |
| កូននៅរស់ | ១៥០ | ២៩ | ១៧៩ |
| កូនអាយុ៧-១៧ឆ្នាំ | ៧០ | ២៣ | ៩៣ |
| កូនអាយុ៧-១៧ឆ្នាំធ្វើការនៅឡូតដ្ឋ | ៥១ | ១៣ | ៦៤ |
| %កូនអាយុ៧-១៧ឆ្នាំធ្វើការនៅឡូតដ្ឋ | ៧២.៩% | ៥៦.៥% | ៦៨.៨% |
| %កូនអាយុ៧-១៧ឆ្នាំមិនបានចូលសាលារៀន | ៥០.០% | ៤៣.៥% | ៤៨.៤% |
| **ស្ថានភាពបំលាស់ទី** | | | |
| មិនមែនជាជនបំលាស់ទី | ៣.០% | ៤០.០% | ១១.៦% |
| បំលាស់ទីពីតំបន់ផ្សេងក្នុងខេត្តបាត់ដំបង | ៥១.៥% | ២០.០% | ៤៤.២% |
| បំលាស់ទីមកពីខេត្តផ្សេង | ៤៥.៥% | ៤០.០% | ៤៤.២% |
| **ចំណូល (មធ្យម, គិតជា១០០០រៀល)** | ២១២ | ២៦១ | ២២៣ |
| **ចំនួនឆ្នាំធ្វើការនៅឡូតដ្ឋ** | | | |
| < ៥ឆ្នាំ | ៣៦.៤% | ១០.០% | ៣០.២% |
| ៥-៩ឆ្នាំ | ២៧.៣% | ៣០.០% | ២៧.៩% |
| ១០ឆ្នាំ និងលើស | ២៤.២% | ២០.០% | ២៣.៣% |
| មិនឆ្លើយ/មិនបានធ្វើការនៅឡូតដ្ឋ | ១២.១% | ៤០.០% | ១៨.៦% |

# ជំពូកទី៥: របកគំហើញ

## ១. ចំនួនពលករកុមារនៅសិប្បកម្មឡឥដ្ឋ





គេមិនអាចប្រកែកបានទេថា មានកុមារកំពុងរស់នៅ និងធ្វើការនៅតាមសិប្បកម្មឡឥដ្ឋ។ ប៉ុន្តែការប៉ាន់ស្មានពីចំនួន នៃពលករកុមារនៅឡឥដ្ឋជាការងារមួយ ក្នុងចំណោមការងារប្រឈមមុខទាំងឡាយព្រោះតែមូលហេតុធំៗពីរ។ ទីមួយ ពលកម្មកុមារ បានក្លាយជាចំណុចរសើបមួយនៅកម្ពុជាចាប់តាំងពីការធ្វើសច្ចាប័នរបស់រដ្ឋាភិបាល លើអនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិនៅក្នុងខែតុលា ឆ្នាំ២០០៥ ដែលអំពាវនាវអោយមានការហាមឃាត់ និងលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ភាពងាយភ្ញាក់ផ្អើលរបស់បញ្ហានេះ ស្ថិតនៅត្រង់ទំនាស់ផលប្រយោជន៍រវាងនិយោជក និងអ្នកតស៊ូមតិ ដែលគាំទ្រអនុសញ្ញានេះ។ ដូច្នេះការប៉ុនប៉ងចុះពិនិត្យ ឬសួរដោយត្រង់ៗពីចំនួនពលករកុមារ នឹងត្រូវប្រឈមនឹងប្រតិកម្មជាអវិជ្ជមាន ពីសំណាក់និ--យោជកទាំងឡាយណា ដែលគាំទ្រពលកម្មកុមារ។ ចំនួនកុមារ ដែលគេបានឃើញពេលចុះពិនិត្យតែងតែតិចជាងចំនួនពិត ពីព្រោះពលករកុមារអាចត្រូវគេហាមជាមុន មិនអោយមកធ្វើការនៅពេលគេចុះពិនិត្យ។ ការរាយការណ៍នានា ពីចំនួនពលករកុមារក៏ដូច្នោះដែរ។

ស្ថានភាពទីមួយនេះ ក៏មិនមែនជាករណីលើកលែងនៅក្នុងការសិក្សានេះដែរ។ ក្នុងចំណោមម្ចាស់ ឬមេការទាំង១៥នាក់ ដែលយល់ព្រមផ្តល់ការសម្ភាសន៍ មានតែ៦នាក់ប៉ុណ្ណោះ ដែលឆ្លើយនឹងសំនួរអំពីចំនួនពលករ

កុមារ[១៧] ។ បន្ថែមលើនេះទៀត ចំលើយរបស់ពួកគេច្រើនតែបង្ហាញពីចំនួនពលករកុមារ ដែលតិចជាងឆ្ងាយពីចំនួនពលករកុមារ ដែលផ្តល់ដោយមនុស្សពេញវ័យ ដែលកំពុងធ្វើការនៅក្នុងសិប្បកម្មនោះ[១៨] ។ ជាឧទាហរណ៍ តាមចំលើយរបស់មេការ ឬម្ចាស់ឡទាំង៦ ជាមធ្យមមានកុមារចំនួន១២នាក់ធ្វើការនៅក្នុងឡឥដ្ឋ ដោយមានចំនួនពលករកុមារ ៥នាក់ជាអប្បបរមា និង៤៥នាក់ជាអតិបរមា។ ផ្អែកតាមចំលើយរបស់កម្មករពេញវ័យ ជាមធ្យមមានពលករកុមារ ធ្វើការ១៦នាក់ក្នុងសិប្បកម្មនិមួយៗក្នុងមួយថ្ងៃ ដោយមានចំនួនអប្បបរមា៥នាក់ និងចំនួនអតិបរមា៥នាក់។

ទីពីរ ចំនួនកុមារធ្វើការប្រែប្រួលយ៉ាងខ្លាំងទៅតាមដំណាក់កាលផលិតកម្មឥដ្ឋ (ពេលជញ្ជូន, ដុតឡ, ទុកឡ អោយត្រជាក់, និងពេលរើឥដ្ឋចេញពីឡជាដើម)។ ពេលដែលពលកម្មកុមារត្រូវការច្រើនបំផុត គឺពេលជញ្ជូនឥដ្ឋ ចូលនិងចេញពីឡ។ ផ្អែកលើលទ្ធផលនៃការសម្ភាសន៍ជាមួយម្ចាស់សិប្បកម្ម វដ្តនៃផលិតកម្មឥដ្ឋរបស់ឡឥដ្ឋធុន មធ្យមមួយត្រូវការរយៈពេលប្រហែល៤០-៤៥ថ្ងៃជាមធ្យម (៧-១០ថ្ងៃសំរាប់រៀបឥដ្ឋចំនួន ៥-៦ម៉ឺនដុំ ដោយ ប្រើពលករចំនួន ១០នាក់, ២អាទិត្យសំរាប់ដុតឥដ្ឋ, ៥-៧ថ្ងៃសំរាប់ទុកពេលអោយឡត្រជាក់)[១៩] ។ ម្ចាស់សិប្បកម្ម ក៏បានអោយដឹងថែមទៀតថា មានកុមារីច្រើនជាងកុមារាធ្វើការនៅឡឥដ្ឋ (៦៦%ជាកុមារី)។

ចំនួនមធ្យមនៃពលករកុមារ ដែលទទួលបានខាងលើអាចប្រើដើម្បីប៉ាន់ស្មានពីចំនួនកុមារធ្វើការនៅឡឥដ្ឋ។ ដោយគុណចំនួនមធ្យមនៃពលករកុមារ (គឺ១២នាក់) និងចំនួនសិប្បកម្ម (គឺ ៣២ឡ) យើងបានចំនួនកុមារជិត ៤០០នាក់ ជាមធ្យម ដែលធ្វើការនៅសិប្បកម្មឡឥដ្ឋនៅជុំវិញទីក្រុងបាត់ដំបង[២០] ។ បើគុណចំនួនឡឥដ្ឋនឹងចំនួន កុមារ ១៦នាក់វិញ យើងបានកុមារចំនួន ៥១២នាក់ជាមធ្យមធ្វើការនៅឡឥដ្ឋទាំងនេះ។ ដូច្នេះមានពលករ កុមារពី ៤០០នាក់ ទៅ៥០០នាក់ធ្វើការរៀងរាល់ថ្ងៃនៅសិប្បកម្មឡឥដ្ឋនារដូវដែលត្រូវការពលកម្មខ្ពស់។

## ២. លក្ខណៈសំខាន់ៗអំពីការសិក្សារបស់ពលករកុមារ

### *២.១ ស្ថានភាពនៃការរៀនសូត្រ*

ពលករកុមារជាច្រើន ដែលធ្វើការនៅឡឥដ្ឋអត់ទៅរៀន (តារាងទី៣)។ ឧទាហរណ៍ ៧៤%នៃកុមារតាមភូមិ ដែលមកធ្វើការនៅឡឥដ្ឋបានបោះបង់សាលា។ ក្នុងចំណោមកុមារទាំងនេះ ៨៥.៩%បានបោះបង់សាលា

---

[១៧] ក្នុងចំណោមម្ចាស់ឬមេការសិប្បកម្មទាំង១៥ មានតែ៦នាក់ប៉ុណ្ណោះ ដែលបានឆ្លើយនឹងសំនួរថា តើមានកុមារប៉ុន្មាននាក់អាយុ ក្រោម ១៨ឆ្នាំ ដែលធ្វើការក្នុងដំណាក់កាលរើនិងជញ្ជូនឥដ្ឋ។

[១៨] អ្នកគ្រប់គ្រងការងារប្រមូលទិន្នន័យ បានចំណាយពេលជជែកលេង ជាមួយកម្មករនៅឡឥដ្ឋជាច្រើន ដើម្បីទទួលបានព័តមានបន្ថែម។ គួរកត់សំគាល់ថា តួលេខដែលទទួលបាន គ្រាន់តែជាការប៉ាន់ស្មានរបស់អ្នកឆ្លើយប៉ុណ្ណោះ។

[១៩] លទ្ធផលនេះ ស៊ីគ្នានឹងការសិក្សាមុនៗ ដែលនិយាយថា រយៈពេលសរុបនៃផលិតកម្មមានប្រហែល៤៤-៤៥ថ្ងៃចំពោះឡធុនតូច និង ៥០-៦០ថ្ងៃចំពោះឡធុនធំ (Rozemuller, 1999)។

[២០] តួលេខនេះ គួរផ្ទៀងផ្ទាត់ដើម្បីរកភាពអាចជឿជាក់បាន ពីព្រោះម្ចាស់ឬមេការសិប្បកម្មជាច្រើនបដិសេធសំនួរនេះ។

យ៉ាងតិចមួយឆ្នាំមកហើយ រីឯ១៤.១%ផ្សេងទៀតទើបនឹងបោះបង់សាលា។ លើសពីនេះទៀត ជាង៣ភាគ៤នៃពលករកុមារ ដែលរស់នៅតាមឡូតដ្ឋ បានឈប់ទៅរៀន (៥៥.៦%) ឬមិនដែលបានទៅរៀនសោះ (២២.២%)។ ភាគច្រើននៃ អ្នកដែលឈប់ទៅរៀន បានបោះបង់សាលាយ៉ាងតិច ២ឆ្នាំមកហើយ (ចំនួន ៧៥.០%)។

**តារាងទី៣ : ប្រវត្តិនៃការសិក្សាទៅតាមកន្លែងរស់នៅ**

| | នៅភូមិ | នៅឡូតដ្ឋ | សរុប |
|---|---|---|---|
| ស្ថានភាពនៃការសិក្សា | | | |
| កំពុងរៀន | ២៦.០% | ២២.២% | ២៥.០% |
| បោះបង់ការសិក្សា | ៧៤.០% | ៥៥.៦% | ៦៨.៩% |
| មិនដែលទៅរៀនសោះ | 0.0% | ២២.២% | ៦.១% |
| រយៈពេលបានបោះបង់ការសិក្សា | | | |
| តិចជាង១ឆ្នាំ | ១៤.១% | 0.0% | ១០.១% |
| ១២-២៣ខែ | ១៦.៩% | ១០.៧% | ១៥.២% |
| ២៤-២៥ខែ | ១៩.៧% | ១៤.៣% | ១៨.២% |
| ៣៦ខែឡើងទៅ | ៤៩.៣% | ៧៥.០% | ៥៦.៦% |
| | ៧១នាក់ | ២៨នាក់ | ៩៩នាក់ |

## ២.២ ហេតុអ្វីពលករកុមារបោះបង់សាលា

នៅពេលសួរថា តើហេតុអ្វីពួកគេឈប់ទៅរៀន? ពលករកុមារបានឆ្លើយពីមូលហេតុជាច្រើនពាក់ព័ន្ធទៅនឹង បញ្ហាគ្រួសារ, សាលារៀន, និងផ្ទាល់ខ្លួន (តារាងទី៤)។ សំរាប់កុមារដែលរស់នៅតាមភូមិ កង្វះខាតសេដ្ឋកិច្ចគ្រួសារ គឺជាមូលហេតុចំបង ដែលនាំអោយគេបោះបង់ចោលការសិក្សា (៤២.០%)។ សំរាប់កុមារ ដែលរស់នៅតាមឡូតដ្ឋ ការជួយធ្វើការងារឪពុកម្តាយ គឺជាមូលហេតុចំបង (៣១.៦%)។ មូលហេតុផ្សេងទៀត ដែលពាក់ព័ន្ធនឹងបញ្ហាគ្រួសារមានឪពុកម្តាយឈឺ ដែលតំរូវអោយកូនធ្វើការរកលុយទិញថ្នាំព្យាបាល ម្តាយមិនអោយកូនទៅរៀនព្រោះត្រូវការកូនជួយធ្វើការងារ និងគ្រួសារជំពាក់បំណុលគេ។ មូលហេតុទាំងនេះបានពីពលករកុមារចំនួនតិចប៉ុណ្ណោះ។

ខាងក្រោមនេះជាស្ថានភាពរបស់កុមារម្នាក់ ដែលឈប់រៀន :

"កុមារីអាយុ ១៦ឆ្នាំម្នាក់ ដែលរស់នៅជាមួយម្តាយបង្កើត និងឪពុកចុងបានបោះបង់ការសិក្សា ពីព្រោះ នាងត្រូវធ្វើការដើម្បីអោយគ្រួសាររស់បាន។ "ម្តាយរបស់ខ្ញុំអត់មានការងារធ្វើទេ ហើយគាត់បង្ខំខ្ញុំ អោយឈប់រៀនដោយនិយាយថាខ្ញុំត្រូវតែរកការធ្វើដើម្បីរកលុយចិញ្ចឹមគ្រួសារ"។ ឪពុកចុងរបស់នាងជា អ្នករត់ម៉ូតូឌុប តែគាត់មិនអាចរកប្រាក់បានគ្រប់គ្រាន់ដើម្បីចិញ្ចឹមមនុស្សចំនួន ៧នាក់ក្នុងគ្រួសារបានទេ។ នាងជាកូនច្បងនៅក្នុងគ្រួសារ។ ប្អូនប្រុសរបស់នាងអាយុ ១៤ឆ្នាំក៏កំពុងធ្វើការនៅឡូតដ្ឋដែរ។ នាងរៀន ត្រឹមថ្នាក់ទី៦ នៅពេលដែលនាងបោះបង់សាលាកាលពីបីឆ្នាំមុន ដើម្បីមកធ្វើការពេញម៉ោងនៅសិប្បកម្ម នេះ។"

បញ្ហាដែលពាក់ព័ន្ធនឹងការរៀនសូត្រជាមូលហេតុមួយទៀត ដែលធ្វើអោយកុមារបោះបង់ចោលការសិក្សា។ បញ្ហាទាំងនេះរួមមាន កង្វះលុយទិញសម្ភារៈសិក្សា កង្វះមធ្យោបាយធ្វើដំណើរ ព្រោះសាលារៀននៅឆ្ងាយ និងការរងទណ្ឌកម្មផ្សេងៗនៅសាលារៀន។ ឧទាហរណ៍ ជាង១២%នៃពលករកុមារ ដែលឈប់រៀននិយាយថា គ្រួសាររបស់ពួកគេក្រីក្រណាស់មិនអាចទ្រទ្រង់ការរៀនសូត្រពួកគេបានទេ រីឯកុមារចំនួន១០%ផ្សេងទៀត និយាយថា ពួកគេគ្មានមធ្យោបាយធ្វើដំណើរទៅរៀនទេ ព្រោះផ្ទះគេនៅឆ្ងាយពីសាលារៀន។ មានកុមារតែបីនាក់ប៉ុណ្ណោះ ដែលនិយាយថាពួកគេបានបោះបង់ចោលការសិក្សា ពីព្រោះគ្រូវាយពួកគេច្រើន។ មានភាពខុសគ្នាគួរអោយកត់សំគាល់រវាងពលករកុមារនៅឡូតដ្ឋ និងពលករកុមារនៅតាមភូមិ អំពីមូលហេតុ ដែលពាក់ព័ន្ធនឹងការទៅរៀននេះ (តារាងទី៤)។

## តារាងទី៤ ៖មូលហេតុនៃការបោះបង់ការសិក្សា

| | នៅភូមិ | នៅឡូតដ្ឋ | សរុប |
|---|---|---|---|
| **មូលហេតុពាក់ពន្ធ័នឹងគ្រួសារ** | | | |
| គ្រួសារខ្វះស្បៀងប្រចាំថ្ងៃ | ៤២.0% | ២៦.៣% | ៣៨.៦% |
| ជួយការងារគ្រួសារដើម្បីប្រាក់ | ១៨.៨% | ៣១.៦% | ២១.៦% |
| ម្ដាយឈឺ ត្រូវការប្រាក់ទិញថ្នាំ | ៥.៨% | ៥.៣% | ៥.៧% |
| ម្ដាយបង្ខំ | ២.៩% | ៥.៣% | ៣.៤% |
| គ្រួសារបម្លាស់ទីញឹកញាប់ | ១.៤% | ៥.៣% | ២.៣% |
| ឈ្លោះជាមួយឪពុកម្ដាយ | ១.៤% | 0.0% | ១.១% |
| គ្រួសារជំពាក់បំណុលគេ | ១.៤% | 0.0% | ១.១% |
| **មូលហេតុពាក់ពន្ធ័នឹងការរៀន** | | | |
| គ្មានលុយទិញសំភារៈសិក្សា | ១៣.0% | ១0.៥% | ១២.៥% |
| សាលារៀននៅឆ្ងាយ គ្មានមធ្យោបាយធ្វើដំណើរ | ១១.៦% | ១0.៥% | ១១.៤% |
| រៀនមិនពូកែ | ១១.៦% | ៥.៣% | ១0.២% |
| ត្រូវគ្រូវាយ | ២.៩% | ៥.៣% | ៣.៤% |
| **មូលហេតុផ្ទាល់ខ្លួន** | | | |
| ខ្ជិល មិនចង់រៀន | ៤.៣% | 0.0% | ៣.៤% |
| ចង់រកលុយ | ១.៤% | ៥.៣% | ២.៣% |
| ចង់នៅជាមួយមិត្តភក្ដិ | ១.៤% | 0.0% | ១.១% |
| **ចំនួនអ្នកឆ្លើយ** | ៦៩ | ១៩ | ៨៨ |

បញ្ហាផ្ទាល់ខ្លួនមួយចំនួនក៏មិនត្រូវមើលរំលងដែរ។ ការរៀនមិនពូកែជាមូលហេតុមួយ ដែលគេដឹងជាទូទៅអំពី ការបោះបង់ចោលការសិក្សា។ ក៏ប៉ុន្តែមានកុមារតែ ៩នាក់ប៉ុណ្ណោះ (ម្នាក់នៅឡូតដ្ឋ និង ៨នាក់ទៀតនៅតាមភូមិ) ដែលលើកឡើងពីមូលហេតុនេះ។ លើសពីនេះទៀត មានពលករកុមារ២-៣នាក់និយាយថា គេមិនចង់

ទៅរៀនទេ គេចង់រកលុយ គេចង់នៅជិតមិត្តភក្តិគេ ដែលធ្វើការ ឬចង់នៅឆ្ងាយពីឪពុកម្តាយ ដែលចេះតែឈ្លោះគ្នាជាញឹក ញាប់។

ការរកឃើញខាងលើនេះ បង្ហាញថាកង្វះខាតសេដ្ឋកិច្ចគ្រួសារជាមូលហេតុនាំមុខគេ សំរាប់កុមារធ្វើការដោយបោះបង់ចោលសាលារៀន។

## ៣. លក្ខណៈសំខាន់ៗនៃការងាររបស់កុមារ

### *៣.១ បទពិសោធន៍ការងារកន្លងមក*

ពលករកុមារដែលយើងជួប កំពុងធ្វើការនៅសិប្បកម្មឡឥដ្ឋនាពេលធ្វើអង្កេត ត្រូវបានយើងសួរថា តើគេធ្លាប់ ធ្វើការដើម្បីប្រាក់នៅកន្លែងណាផ្សេងទៀតទេពីមុនមក។ តាមរយៈចម្លើយនេះ ពលករកុមារត្រូវបានចែកជាបីក្រុមធំៗ និងដាច់ពីគ្នា អំពីបទពិសោធន៍ការងារ : កុមារដែលធ្លាប់ធ្វើការនៅឡឥដ្ឋផ្សេង កុមារដែលធ្លាប់ធ្វើការងារផ្សេង (ដូចជាស៊ីឈ្នួលគេប្រចាំថ្ងៃ, អ្នកបំរើតាមហាង, អ្នកបំរើតាមផ្ទះ, កម្មករសំណង់។ល។) និងកុមារដែលមិនធ្លាប់ធ្វើការអ្វីសោះពីមុនមក (កុមារដែលធ្លាប់ធ្វើស្រែ ឃ្វាលគោក្របីមិនចាត់ទុកថាមានបទពិសោធន៍ការងាររកលុយទេ)។

**ក្រាហ្វិកទី១ : បទពិសោធន៍ការងារពីមុនរបស់ពលករកុមារ**




ក្រាហ្វិកទីមួយខាងលើបង្ហាញថា ២២%នៃពលករកុមារមានបទពិសោធន៍ការងារនៅឡឥដ្ឋ ២០.៥%ធ្លាប់ធ្វើការផ្សេង, និង៥៧.៦%ពុំមានបទពិសោធន៍ការងាររកលុយណាមួយទេ។ តាមការប្រៀបធៀបទៅតាមទីកន្លែងរស់នៅរបស់ពលករកុមារ ភាគរយនៃកុមារដែលធ្លាប់ធ្វើការផ្សេង មានចំនួនតិចក្នុងចំណោមអ្នករស់នៅតាមឡឥដ្ឋ

ជាងក្នុងចំណោមអ្នករស់នៅតាមភូមិ (១៣.៩%ទល់នឹង ២៥%រៀងគ្នា)។ នេះចង្អុលអោយឃើញថាកុមារ ដែលរស់ នៅតាមឡូតដ្ឋ ទំនងជាចាប់ផ្ដើមធ្វើការងារដំបូង ជាកម្មករនៅឡូតដ្ឋច្រើនជាងកុមារ ដែលរស់នៅតាម ភូមិ ប្រហែលជាដោយសារការជួយការងារឪពុកម្ដាយ ដែលធ្វើការនៅឡូតដ្ឋស្រាប់ (សូមមើលពីមូលហេតុ ដែល កុមារធ្វើការនៅឡូតដ្ឋខាងក្រោម)។

## ៣.២ អាយុនៅពេលចាប់ធ្វើការដំបូង

លើសពីនេះទៀត ពលករកុមារដែលរស់នៅតាមសិប្បកម្មឡូតដ្ឋ មានទំនោរចាប់ផ្ដើមធ្វើការងារតាំងពីនៅ អាយុតិចមកម្ល៉េះ។ ប្រហែលជា ៥៧%នៃពួកគេចាប់ផ្ដើមធ្វើការងារតាំងពីមិនទាន់គ្រប់អាយុ ១២ឆ្នាំម្ល៉េះ ក្នុងនោះ មាន២៥.៧% ដែលចាប់ផ្ដើមធ្វើការនៅអាយុ៦-៨ឆ្នាំ (ក្រាហ្វិកទី២)។ ផ្ទុយទៅវិញ ពលករកុមារដែលរស់នៅតាម ភូមិចាប់ផ្ដើមធ្វើការនៅអាយុច្រើនជាងបន្តិច។ ឧទាហរណ៍មានតែ ២១.៨%នៃពួកគេតែប៉ុណ្ណោះ ដែលចាប់ធ្វើការ នៅអាយុ ១២-១៤ឆ្នាំ និង៣៣.៧%ចាប់ធ្វើការដំបូងនៅអាយុ ១៥ឆ្នាំឡើងទៅ។

ការរកឃើញនេះ បញ្ជាក់ថាកុមារដែលរស់នៅជាមួយឪពុកនៅសិប្បកម្មឡូតដ្ឋ ងាយប្រឈមនឹងការងារ ដែលមានគ្រោះថ្នាក់ជាងកុមារដែលរស់នៅតាមភូមិ។ ពលករកុមារនៅតាមសិប្បកម្មឡូតដ្ឋ ឆាប់ប្រឡូកក្នុង ពលកម្មកុមារតាំងពីវ័យក្មេង ពីព្រោះតែឪពុកម្ដាយ។ ដោយមិនគិតពីបញ្ហាសេដ្ឋកិច្ចគ្រួសារ ការរស់នៅក្នុងឡូតដ្ឋ ជាមួយឪពុកម្ដាយ ដែលធ្វើការនៅឡូតដ្ឋ បង្កើតបានជាឱកាសមួយ សំរាប់ឪពុកម្ដាយប្រើប្រាស់កំលាំងពលកម្ម កុមារ ក្រោមរូបភាពជាការអោយជួយការងារម្ដងម្កាលដោយគ្មានផែនការជាមុន ដូចជាការអោយជួយហុចឥដ្ឋ ឬជួយរុញ រទេះឥដ្ឋជាដើម។ ការជួយដូច្នេះ រួមផ្សំនឹងការប្រឈមនឹងការងារនៅឡូតដ្ឋរយៈពេលយូរ អាចបណ្ដុះ ផ្នត់គំនិត របស់ឪពុកម្ដាយ និងកុមារអំពីលទ្ធភាពធ្វើការនៅឡូតដ្ឋ និងតំលៃសេដ្ឋកិច្ចរបស់កុមារ។

**ក្រាហ្វិកទី២ : អាយុនៅពេលចាប់ផ្ដើមធ្វើការដើម្បីលុយ**



## ៣.៣ ការងារកុមារ

រូបភាពខាងក្រោម ជាឧទាហរណ៍អំពីការងារ ដែលកុមារភាគច្រើនធ្វើនៅឡឥដ្ឋ នោះគឺការជញ្ជូនឥដ្ឋចេញចូល។ បន្ទាប់ពីការដុតឡត្រូវបានបញ្ចប់ ហើយឡចុះត្រជាក់ល្មមនឹងរើឥដ្ឋបាន កុមារដែលភាគច្រើនជាកុមារីមកពីភូមិជិតខាង បានមកធ្វើការជាអ្នកជញ្ជូនឥដ្ឋចេញពីឡ និងរើដាក់ឡានដើម្បីចែកចាយ។

 

ពលករកុមារនៅសិប្បកម្មឡឥដ្ឋ ភាគច្រើនធ្វើការងារច្រើនប្រភេទ ដែលមានការងារ៤ប្រភេទច្រើនធ្វើដោយ កុមារ ដែលរស់នៅឡឥដ្ឋ និងការងារ៣ប្រភេទច្រើនធ្វើអោយកុមារ ដែលរស់នៅតាមភូមិ។ ការងារដែលភាគច្រើនធ្វើទាំងកុមារនៅឡឥដ្ឋ និងកុមារនៅតាមភូមិ គឺការងាររូសរទេះដឹកឥដ្ឋ រើឥដ្ឋចេញ និងចូលក្នុងឡ រើឥដ្ឋដាក់ ចូល និង ចេញពីរទេះ ជញ្ជូនឥដ្ឋដាក់ឡាន និងហាលឥដ្ឋ ( ក្រាហ្វិកទី៣) ។

ការងារផ្សេងទៀត មានការបញ្ជាម៉ាស៊ីនធ្វើពុម្ពឥដ្ឋ ការធ្វើដីឥដ្ឋ (គិតតាំងពីជីកដីឥដ្ឋ មកដល់ការបញ្ជាន់ និងរើឥដ្ឋដាក់កន្លែងម៉ាស៊ីនពុម្ពឥដ្ឋ) និងការងារដុត និងរក្សាភ្លើងឡ។ ការសំខាន់ដែលគួរកត់សំគាល់ គឺថាមានកុមារ ដែលបានសម្ភាសន៍មួយចំនួន (២៩នាក់ក្នុងចំណោម ១៣២ពលករកុមារ) ធ្លាប់ធ្វើការនៅនឹងម៉ាស៊ីនធ្វើឥដ្ឋ (គឺជាអ្នកបោះដីឥដ្ឋចូលម៉ាស៊ីន) ។ តួលេខនេះបង្ហាញពីការប្រឈមនឹងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមាររបស់ពលករកុមារនៅឡឥដ្ឋទោះបីជាពួកគេទៅធ្វើការងារនោះជាមួយឪពុកម្តាយពួកគេ ដែលជាអ្នកបញ្ជាម៉ាស៊ីនធ្វើឥដ្ឋ ឬក៏នៅធ្វើការតាមកុងត្រាបន្តជាមួយអ្នកបញ្ជាម៉ាស៊ីនណាម្នាក់ផ្សេងទៀតក៏ដោយ។ លើសពីនេះទៀត កុមារដែលរស់នៅតាមឡឥដ្ឋទំនងជាមានចំនួនច្រើនជាងកុមារដែលរស់នៅតាមភូមិ ដែលជាអ្នកធ្វើការនៅម៉ាស៊ីនធ្វើឥដ្ឋ។ ឧទាហរណ៍ ពលករកុមារ ១០នាក់ក្នុងចំណោមពលករកុមារ ៣៦នាក់ ដែលរស់នៅតាមឡឥដ្ឋ (២៧.៨%) រាយការណ៍ថាពួកគេធ្លាប់បញ្ជាម៉ាស៊ីនធ្វើឥដ្ឋ បើប្រៀបធៀបនឹងពលករកុមារដែលរស់នៅតាមភូមិ ដែលមានចំនួនត្រឹមម្នាក់ក្នុងចំនោម ៥នាក់ប៉ុណ្ណោះ ( ១៩.៨%) ។

ការងារធ្ងន់ធ្ងរមួយចំនួនទៀត សំរាប់ពលករកុមារគឺការធ្វើដីឥដ្ឋ ដោយគិតចាប់ពីជីកដី បំបែក បញ្ជាន់ និងលី ទៅដាក់កន្លែងម៉ាស៊ីនធ្វើឥដ្ឋ។ ការងារទាំងនេះភាគច្រើនធ្វើដោយកុមារា ដោយសារវាត្រូវការកំលាំងកាយច្រើនជាងការងារផ្សេងទៀត។ ការរកឃើញក្នុងការសិក្សានេះបង្ហាញថា ២២%នៃពលករកុមារ ដែលបានសម្ភាសន៍ធ្លាប់ធ្វើការងារនេះ (ក្រាហ្វិកទី៣)។

ការងារធ្ងន់ និងប្រកបដោយគ្រោះថ្នាក់មួយទៀត ដែលពលករកុមារខ្លះបានធ្វើគឺការងារដុតឡឥដ្ឋ ដែលការដុត ម្តងៗមានរយៈពេលប្រហែល៣អាទិត្យ ទាំងថ្ងៃទាំងយប់ក្នុងឡនិមួយៗ។ នៅសិប្បកម្មឡឥដ្ឋមួយមានគ្រួសារ មួយ ដែលមានចៅកើត និងរស់នៅឡឥដ្ឋនោះតែម្តង។ ចៅបីនាក់ (កុមារាអាយុ ១២, ១៣, និង១៥ឆ្នាំ) ជាអ្នកដុតឡឥដ្ឋ។ នេះអាចជាឧទាហរណ៍មួយនៃការងារប្រចាំគ្រួសារនៅឡឥដ្ឋ ដែលបន្តពីជំនាន់មួយទៅជំនាន់ មួយទៀត[២១]។



ពលករកុមារ ដែលទទួលធ្វើការងារនេះ ត្រូវចូកផេះដែលកំពុងឆេះចេញពីឡ និងអូសយកទៅចោល។ ការរលាក គឺជាការរងរបួសទូទៅ មួយ ដោយសារពលករកុមារគ្មាន ស្បែកជើងការពារ ក្រៅពីស្បែកជើងផ្ទាត់។ ជាបន្ថែមទៀត កុមារ មិនត្រឹមតែធ្វើការច្រើនម៉ោង ដោយសារតែឡឥដ្ឋត្រូវដុតទាំងថ្ងៃ ទាំងយប់នោះទេ ពួកគេថែមទាំង ប្រឈមនឹងកំដៅដ៏មហិមា ដែលភាយចេញមកពីឡឥដ្ឋ។ ខ្យល់គដោយសារក្តៅអាចកើតមាន ទោះបីជាគ្មានពលករកុមារណា ម្នាក់ធ្លាប់ជួប ជំងឺនេះក៏ដោយ។

[២១] គួរកត់សំគាល់ថា សិប្បកម្មឡឥដ្ឋនៅបាត់ដំបង ប្រើអង្កាមសំរាប់ដុតឡ។

## ក្រាហ្វិកទី៣ : ប្រភេទការងាររបស់ពលករកុមារ




## ៣.៤ ថ្ងៃធ្វើការ និងម៉ោងធ្វើការ

ពលករកុមារនៅសិប្បកម្មឡឥដ្ឋ អាចធ្វើការតាមកុងត្រា, (ជាទូទៅគឺអាស្រ័យលើបរិមាណការងារដែលបានធ្វើ) ធ្វើការពេញម៉ោងរៀងរាល់ថ្ងៃ, ឬធ្វើការក្រៅម៉ោងនៅពេលកុមារទំនេរ (ដូចជាធ្វើការពេលព្រឹក ឬពេល ល្ងាចនៅពេលចេញពីសាលា)។ ពួកគេច្រើនធ្វើការពីបីម៉ោងទៅដល់ ១០ម៉ោងក្នុងមួយថ្ងៃៗ។ ក្រាហ្វិក ទី៤ សង្ខេប ពីរបាយភាគរយនៃចំនួនម៉ោងធ្វើការ ទៅតាមប្រភេទការងារ និងទីលំនៅរបស់ពលករកុមារធ្វើការនៅឡឥដ្ឋ។

ពលករកុមារ ដែលធ្វើការងារតាមកុងត្រា ច្រើនធ្វើការយូរម៉ោងជាងកុមារ ដែលធ្វើការពេញម៉ោងរៀងរាល់ថ្ងៃ និងយូរម៉ោងជាងកុមារ ដែលធ្វើការម្តងម្កាល។ រវាងពី ៤០%ទៅ ៤៥%នៃពលករកុមារ ដែលធ្វើការងារតាមកុងត្រា ធ្វើការលើសពី៨ម៉ោងក្នុងមួយថ្ងៃៗ ក្នុងខណៈដែលមានត្រឹមពី៤.៣%ទៅ១៥.៧% នៃពលករកុមារដែលធ្វើការពេញម៉ោង ធ្វើការលើសពី ៨ម៉ោងក្នុងមួយថ្ងៃ។ ក៏ប៉ុន្តែ កុមារដែលធ្វើការតិចជាង ៦ម៉ោងមួយថ្ងៃ មានតែកុមារដែលធ្វើការម្តងម្កាលនៅចុងសប្តាហ៍ ឬនៅពេលពួកគេទំនេរ។

ចំពោះកុមារដែលធ្វើការម្តងម្កាល សមាមាត្រនៃចំនួនអ្នកធ្វើការតិចជាង៦ម៉ោងក្នុងមួយថ្ងៃ នៅក្នុងចំណោម កុមាររស់នៅតាមឡឥដ្ឋមានទំហំធំជាងសមាមាត្រនៃកុមារដែលរស់នៅតាមភូមិ (គឺ៨៧.៥%ទល់នឹង ២០.០% រៀងគ្នា)។ មានការបកស្រាយមួយអាចជឿជាក់បាន។ ដោយហេតុថា ពលករកុមារទាំងពីរក្រុមនៅកំពុងសិក្សា កុមារដែលនៅតាមឡឥដ្ឋ ទំនងជាធ្វើការក្រៅម៉ោងនៅពេលពួកគេអត់ទៅសាលា ឬមួយដើម្បីបានលុយបន្ថែម ឬមួយដើម្បីជួយឪពុកម្តាយ ក្នុងខណៈដែលគេរស់នៅនឹងកន្លែងធ្វើការតែម្តង។ ផ្ទុយទៅវិញ កុមារនៅតាមភូមិ ច្រើនមកធ្វើការពេញម៉ោងនៅចុងសប្តាហ៍ជាជាងមកធ្វើការ ២-៣ម៉ោងមួយថ្ងៃ។

**ក្រាហ្វិកទី៤ : របាយភាគរយនៃចំនួនម៉ោងធ្វើការទៅតាមទីកន្លែងរស់នៅ និងប្រភេទការងារ**




## ៣.៥ ប្រាក់ចំណូល

តាមការសម្ភាសន៍ជាមួយ ម្ចាស់សិប្បកម្ម ឬមេការ ពលករកុមារដែលមិនធ្វើការតាមកុងត្រារកប្រាក់បាន ៥ពាន់រៀលសំរាប់ការងាររយៈពេល ៨ម៉ោងក្នុងមួយថ្ងៃ[២២]។ ចំនួននេះកើនលើសពីប្រាក់ចំណូលមធ្យមនៅឆ្នាំ២០០៥ ចំនួន ១ពាន់រៀល (WVC, 2006)។ តាមទស្សនៈរបស់មេការសិប្បកម្មមួយចំនួន ប្រាក់ឈ្នួលនេះវាខ្ពស់ហើយសំរាប់កុមារ ព្រោះពលករកុមារ ដែលមកធ្វើការជាប់ជាអចិន្ត្រៃយ៍ ត្រូវបានអនុញ្ញាត្តិអោយឈប់

[២២] ចំនួននេះ សមមូលនឹងប្រាក់ចំណូលចំនួន ១.២ ដុល្លារអាមេរិចក្នុង ១ថ្ងៃ ដោយគិតតាមអត្រាប្តូរប្រាក់ នៅខែកក្កដា២០០៧ ដែល ១ដុល្លារអាមេរិច ស្មើនឹង ៤០៩០រៀលកម្ពុជា។

សំរាកនាពេលឈប់សំរាកជាតិ ដោយមិនកាត់ប្រាក់ឡើយ, គឺ ១៥០,០០០រៀលក្នុងមួយខែ។ មានមេការសិប្បកម្មឡឥដ្ឋម្នាក់និយាយថាកុមារ ដែលរស់នៅក្នុងសិប្បកម្មរបស់គាត់ប្រាក់ឈ្នួលពលកម្មចំនួន ៦ពាន់រៀលក្នុងមួយថ្ងៃ។

បើទោះជាប្រាក់ឈ្នួល ៥ពាន់រៀលក្នុងមួយថ្ងៃគិតជាមធ្យម ជាការពិតក៏ដោយ ក៏មានពលករកុមារ ដែលមិនបានប្រាក់ឈ្នួលស្មើនឹងចំនួននេះឡើយ។ ការសម្ភាសន៍ជាមួយពលករកុមារ បង្ហាញអោយឃើញថា ១ភាគ៣នៃពួកគេរកប្រាក់បានមិនលើសពី៤ពាន់រៀលឡើយក្នុងមួយថ្ងៃ។ កុមារខ្លះ ដែលធ្វើការក្រៅម៉ោងរកបានត្រឹម ១ពាន់ រៀលក្នុងមួយថ្ងៃ ឯកុមារខ្លះទៀតធ្វើការដល់ទៅ ៦ម៉ោងក្នុងមួយថ្ងៃ តែទទួលប្រាក់ចំណូលរកបានត្រឹម ២ពាន់ រៀលប៉ុណ្ណោះ។

ប្រាក់ចំណូលរបស់ពលករកុមារ ដែលធ្វើការតាមកុងត្រា អាស្រ័យទៅតាមប្រភេទនៃការងារដែលគេធ្វើ។ ចំពោះអ្នកដុត ឬថៃភ្លើងឡ ពលករកុមារម្នាក់រកបានជាមធ្យម ៨០០០រៀលមួយថ្ងៃ។ ចំពោះអ្នកធ្វើដីឥដ្ឋ ឬកាត់មុខពុម្ព ឬបញ្ជាម៉ាស៊ីនឥដ្ឋ ប្រាក់ចំណូលជាមធ្យមមានពី ៦០០០ទៅ ៧០០០រៀលក្នុងមួយថ្ងៃ។

## ៤. ការយល់ឃើញពីពលកម្មកុមារនៅឡឥដ្ឋ

ទោះជាយ៉ាងណាក៏ដោយ របកគំហើញខាងលើចង្អុលបង្ហាញថាពលករកុមារនៅសិប្បកម្មឡឥដ្ឋបានពាក់ព័ន្ធនឹងការងារធ្ងន់ និងប្រកបដោយគ្រោះថ្នាក់ ដោយមានចំនួនម៉ោងធ្វើការយូរ និងប្រាក់ឈ្នួលទាប។ គួរកត់សំគាល់ថា លទ្ធផលអំពីការយល់ឃើញរបស់កុមារ ទៅលើការងាររបស់ពួកគេមានលក្ខណៈដូចគ្នាទៅនឹងការយល់ឃើញរបស់ ឪពុកម្តាយរបស់ពួកគេ។ ផ្នែកបន្តខាងក្រោមនេះនឹងបង្ហាញពីការយល់ឃើញរបស់ពលករកុមារ និងឪពុកម្តាយអំពី ការងារដែលធ្វើដោយកុមារនៅសិប្បកម្មឡឥដ្ឋ។

### *៤.១ ការយល់ឃើញរបស់ពលករកុមារ*

តាមការវាយតំលៃពីចំនួនភាគរយនៃពលករកុមារ ដែលនិយាយថាការងារពួកគេជាការងារធ្ងន់ធ្ងរណាស់សំរាប់ពួកគេ ការងារធ្ងន់ធ្ងរនេះមានពាក់ព័ន្ធនឹងប្រភេទការងារ គឺការងារតាមកុងត្រាជាការងារធ្ងន់ធ្ងរបំផុតសំរាប់កុមារ បន្ទាប់មកគឺការងារពេញម៉ោង និងរាល់ថ្ងៃ និងការងារនៅពេលទំនេរ (ក្រាហ្វិក៥)។ ឧទាហរណ៍ ពលករកុមារសឹងតែទាំងអស់ ដែលធ្វើការតាមកុងត្រាត្អូញត្អែរថា ការងារដែលគេធ្វើធ្ងន់ធ្ងរណាស់សំរាប់ពួកគេ (៩០.៩%ក្នុង ចំណោមពលករកុមារដែលរស់នៅតាមភូមិ និង១០០%ក្នុងចំណោមពលករកុមារដែលរស់នៅតាមឡឥដ្ឋ) ក្នុងខណៈដែលមានប្រហែល ៧០% នៃពលករកុមារធ្វើការប្រចាំថ្ងៃបានត្អូញត្អែរដូច្នេះ (៨៧%ក្នុងចំណោមពលករកុមាររស់នៅតាមសិប្បកម្ម និង ៦២.៩%ក្នុងចំណោមពលករកុមាររស់នៅតាមភូមិ)។

ជាបន្ថែមទៀត កុមារភាគច្រើនយល់ឃើញថាចំនួនម៉ោងធ្វើការគឺច្រើនពេកហើយសំរាប់ពួកគេ ដោយមិនអាស្រ័យពីប្រភេទការងារដែលពួកគេធ្វើ (៨១.៩%ក្នុងចំណោមអ្នកធ្វើការតាមកុងត្រា និង ៨៣.៩%ក្នុងចំណោមអ្នកធ្វើការប្រចាំថ្ងៃ)។ ក៏ប៉ុន្តែក្រាហ្វិកទី៦ បង្ហាញថាសមាមាត្រនៃពលករកុមារដែលត្អូញត្អែរពីម៉ោងធ្វើការតាម

កុងត្រា មានរយៈពេលយូរពេក មានចំនួនខ្ពស់ក្នុងចំណោមកុមាររស់នៅតាមសិប្បកម្មជាងក្នុងចំណោមកុមាររស់នៅតាមភូមិ (គឺ ១០០%ទល់នឹង ៧២.៧%រៀងគ្នា) ។

ការរកឃើញ បង្ហើបអោយឃើញថាការអោយកុមារធ្វើការតាមកុងត្រាមិនល្អសំរាប់កុមារឡើយ ពីព្រោះវាជាប្រភេទការងារដែលធ្ងន់ធ្ងរ និងមានម៉ោងធ្វើការយូរ ។

## ក្រាហ្វិកទី៥ : ភាគរយកុមារ និយាយថាគេធ្វើការធ្ងន់ហួសសមត្ថភាពគេ




## ក្រាហ្វិកទី៦ : ភាគរយកុមារ និយាយថាគេធ្វើការយូរម៉ោងហួសសមត្ថភាពគេ



## ៤.២ ការយល់ឃើញរបស់ឪពុកម្តាយ

ឪពុកម្តាយរបស់កុមារ ដែលធ្វើការនៅសិប្បកម្មឡឥដ្ឋ ត្រូវបានសួរផងដែរ អោយសំដែងការយល់ឃើញរបស់ខ្លួន អំពីការងារដែលកុមារធ្វើដោយសំដៅលើភាពធ្ងន់ធ្ងរ និងរយៈពេលនៃម៉ោងធ្វើការ។ ការរកឃើញបង្ហាញថា សមាមាត្រនៃឪពុកម្តាយដែលនិយាយថាការងារកុមារធ្ងន់ធ្ងរពេក ឬថារយៈពេលធ្វើការយូរពេក សំរាប់កុមារ មានចំនួនទាបច្រើនជាងសមាមាត្រនៃចំនួនពលករកុមារ ដែលនិយាយដូចគ្នា។ ឧទាហរណ៍ ៣០.២% នៃឪពុកម្តាយចំនួន ៤១នាក់និយាយថា កិច្ចការរបស់កូនគាត់មិនធ្ងន់ធ្ងរសំរាប់ពួកវាទេ ហើយ ៤៤.២%នៃ ឪពុកម្តាយចំនួន៤១នាក់ និយាយថាចំនួនម៉ោងធ្វើការ ដែលកូនគាត់ធ្វើគឺសមរម្យសំរាប់ពួកគេ។ នេះសរអោយឃើញថាមួយចំនួនធំនៃឪពុកម្តាយ ប្រហែលជាជឿថាកិច្ចការ ដែលកូនគាត់ធ្វើនៅសិប្បកម្មឡឥដ្ឋ គឺសមរម្យ សំរាប់ពួកគេ។

ការដែលរកឃើញថា ឪពុកម្តាយជាច្រើនយល់ឃើញថាការងារ ដែលកូនគាត់ធ្វើសមរម្យសំរាប់ពួកគេ អាចបកស្រាយពីមូលហេតុ ដែលពួកគាត់អោយកូនរបស់គាត់ចូលប្រឡូកក្នុងពលកម្មកុមារ។ ក្នុងខណៈដែលពិតជាមានការងារ ដែលមិនធ្ងន់ធ្ងរក្នុងន័យការប្រើប្រាស់កំលាំងរូបកាយ និងការងារដែលមិនធ្វើយូរម៉ោងក្នុងន័យការមាន ពេលធ្វើការ ភាពធ្ងន់ធ្ងរនៃពលកម្មកុមារអាចសិក្សាដោយរួមផ្សំជាមួយការរៀនសូត្ររបស់កុមារដូចមានចែងក្នុង អនុសញ្ញា ១៨២របស់អង្គការពលកម្មអន្តរជាតិ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

# ៥. ការពាក់ព័ន្ធរបស់កុមារក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ





កិច្ចការជាច្រើន ដែលកុមារធ្វើការនៅសិប្បកម្មឡឥដ្ឋ គឺជាកិច្ចការ ដែលអាចបណ្តាលអោយមានរបួស។ កិច្ចការមួយគឺការបញ្ជាម៉ាស៊ីនធ្វើឥដ្ឋ ដែលគេដឹងជាទូទៅថា បណ្តាលអោយមានការរងរបួសធ្ងន់ធ្ងរ ដល់កុមារ។ ម៉ាស៊ីនធ្វើឥដ្ឋនៅគ្រប់សិប្បកម្មឡឥដ្ឋ ដែលបានចុះធ្វើសម្ភាសន៍ គ្មានបំពាក់ឧបករណ៍ ការពារសុវត្ថិភាពភ្ជាប់ជាមួយឡើយ។ អ្នកបញ្ជាម៉ាស៊ីន អាចប៉ះនឹងផ្នែកផ្សេងៗនៃម៉ាស៊ីន ដែលមានគ្រោះថ្នាក់ ដូចជានៅពេលបោះដីឥដ្ឋចូលម៉ាស៊ីន និងប៉ះខ្សែពាន ម៉ាស៊ីន។ គ្រោះថ្នាក់ដែលបានគេរាយការណ៍ មកទាក់ទងនឹងការបញ្ជាម៉ាស៊ីន គឺច្រើនបង្កឡើង ដោយម៉ាស៊ីនទាញដៃអារចូល នៅពេលបោះដីចូលម៉ាស៊ីន។ ជាផលវិបាកកុមារខ្លះត្រូវរបួសដៃ។ កុមារខ្លះបាត់បង់

ដែដោយសារ គ្រោះថ្នាក់ប្រភេទនេះ។

ដើម្បីយល់ពីទំហំនៃការពាក់ព័ន្ធកុមារ ទៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋ សន្ទស្សន៍នៃពលកម្មកុមារមួយត្រូវបានបង្កើតសំរាប់ការសិក្សានេះ ដោយផ្អែកលើចំណោតថ្នាក់នៃរង្វាស់បីរួមគ្នា គឺ ចំនួនម៉ោង ធ្វើការ ការទៅរៀន និងភាពធ្ងន់ធ្ងរនៃការរងរបួស។ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ គឺជាការងារ ដែល ជ្រៀតជ្រែកដល់ការទៅរៀនរបស់កុមារ ដែលគំរាមកំហែងដល់សុខភាព និងការលូតលាស់របស់កុមារ។ តាមសន្ទស្សន៍ខាងលើ ពលករកុមារនៅសិប្បកម្មឡឥដ្ឋត្រូវបានបែងចែកជាបីប្រភេទ : (១)កុមារដែលមិនពាក់ព័ន្ធ នឹងការងារធ្ងន់ធ្ងរ (ប្រសិនបើកុមារទៅរៀនទៀងទាត់ និងធ្វើការក្រៅម៉ោងមិនលើសពី ៥ម៉ោងក្នុងមួយថ្ងៃ ឬធ្វើការតែថ្ងៃចុងសប្តាហ៍), (២)កុមារដែលពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (ប្រសិនបើកុមារធ្វើការ ពេញម៉ោងដោយមិនបានទៅរៀន), (៣)និងកុមារដែលពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (ប្រសិនបើ កុមារធ្វើការនៅម៉ាស៊ីនធ្វើឥដ្ឋ ហើយមិនទៅរៀនអ្វីទាំងអស់)។ ករណីដែលពលករកុមារឆ្លើយមិនស៊ីសង្វាក់គ្នា អំពីរង្វាស់ទាំងបីខាងលើ ឬករណីគ្មានចម្លើយ ត្រូវបានដកចេញពីការវិភាគ ដែលជាលទ្ធផលយើងបាន ករណីចំនួន ១០៧ពលករកុមារសំរាប់វិភាគ (ក្រាហ្វិកទី៧)។

**ក្រាហ្វិកទី៧ : ភាគរយកុមារ ដែលចូលរួមក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**




ក្រាហ្វិកទី៧ បង្ហាញពីលទ្ធផលគួរអោយខ្វាយខ្វល់មួយ គឺជិត ៨៥%នៃកុមារធ្វើការនៅសិប្បកម្មឡឥដ្ឋ បានពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរណាមួយនៃពលកម្មកុមារ (៣២.១%នៃពលករកុមារពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរបំផុត និង ៥២.៣% ពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ)។ ការប្រែប្រួលពីទំហំនេះត្រូវបានរកឃើញមានរវាងកុមារ

ដែលរស់នៅ តាមសិប្បកម្ម និងកុមារដែលរស់នៅតាមភូមិ ដោយកុមារ ដែលរស់នៅតាមសិប្បកម្មមានពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ច្រើនជាងពលករកុមារដែលរស់នៅតាមភូមិ។ ទោះបីជាមានបំរែបំរួលទៅតាមទីកន្លែង រស់នៅដូចខាងលើក៏ដោយ ការរកឃើញពិតជាបង្ហាញអោយឃើញពីចំណងទាក់ទងរវាងការងារនៅឡឥដ្ឋ និងការរៀនសូត្ររបស់កុមារ គឺភាគច្រើនការងារទាំងនោះទាមទារអោយកុមារធ្វើការពេញម៉ោង ដែលធ្វើអោយកុមារ បោះបង់ចោលការសិក្សា។

## ៦. មូលហេតុដែលធ្វើការនៅសិប្បកម្មឡឥដ្ឋ

ផ្នែកខាងក្រោមពិភាក្សាអំពីមូលហេតុ ដែលនាំអោយកុមារចូលប្រឡូកក្នុងពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋ ដោយផ្អែកលើទិន្នន័យ ដែលបានពីការសម្ភាសន៍ ជាមួយពលករកុមារ មាតាបិតា និងថៅកែ ឬមេការសិប្បកម្ម។

### *៦.១ មូលហេតុដែលចូលរួមក្នុងពលកម្មកុមារ : ចម្លើយរបស់កុមារ*

ពលករកុមារនៅសិប្បកម្មឡឥដ្ឋ ត្រូវបានសួរសំណួរបើកចំនួនពីរ ដើម្បីចាប់យកព័ត៌មានអំពីមូលហេតុដែលកុមារធ្វើការរកប្រាក់ និងមូលហេតុដែលកុមារធ្វើការនៅឡឥដ្ឋ។ សំណួរទីមួយ សំដៅប្រមូលយកមូលហេតុទាំងអស់ដែលស្ថិតនៅពីក្រោយការចូលរួមក្នុងពលកម្មកុមាររបស់កុមារ ឯសំណួរទីពីរសំដៅស្វែងយល់ថាតើហេតុអ្វីបានជាកុមារជ្រើសរើសការងារនៅសិប្បកម្មឡឥដ្ឋ។

ក្រាហ្វិកទី៨ បង្ហាញពីមូលហេតុដែលកុមារធ្វើការ ដែលផ្តល់អោយដោយពលករកុមារ ដែលបានសម្ភាសន៍។ ស្រដៀងគ្នាទៅនឹងមូលហេតុ ដែលកុមារបោះបង់ចោលការសិក្សា ការលំបាកខាងជីវភាពគ្រួសារជាកត្តាចំបងទី១ ដែលនាំអោយកុមារចូលធ្វើការ ដោយមិនអាស្រ័យថាតើគេរស់នៅតាមសិប្បកម្ម ឬអត់។ ឧទាហរណ៍ ៧៧.១%នៃ កុមារ ដែលរស់នៅតាមភូមិ និង ៧២.២%នៃកុមារដែលរស់នៅតាមសិប្បកម្ម ឆ្លើយថាពួកគេធ្វើការព្រោះគ្រួសារ គេត្រូវការប្រាក់ដើម្បីទិញបាយហូប។

កត្តាចំបងទីពីរ អាស្រ័យទៅតាមកុមារដែលរស់នៅតាមសិប្បកម្ម ឬនៅតាមភូមិ។ ចំពោះកុមារ ដែលរស់នៅតាមភូមិ តំរូវការប្រាក់ដើម្បីបំពេញតំរូវការផ្ទាល់ខ្លួន (ដូចជាសំលៀកបំពាក់ ស្បែកជើង និងចំណីជាដើម) ជាមូលហេតុចំបងទីពីរ ដែលជំរុញអោយពួកគេធ្វើការ។ ចំពោះកុមារដែលរស់នៅតាមសិប្បកម្ម មូលហេតុចំបងទីពីរដែលពួកគេធ្វើការ គឺដោយសារតែការបង្ខិតបង្ខំរបស់ឪពុកម្តាយ ឬអាណាព្យាបាលពួកគេ (២៥.០%) ឬដោយសារតែដើម្បីជួយការងារឪពុកម្តាយ ដែលកំពុងធ្វើការនៅឡឥដ្ឋ (២៥.០%)។ មូលហេតុចំបងទីបីចំពោះកុមារដែលរស់នៅតាមសិប្បកម្ម គឺធ្វើការដើម្បីជួយដោះបំណុលគ្រួសារ (២២.២%)។ មូលហេតុទាំងបីរួមគ្នាចង្អុលបង្ហាញថាកុមារដែលរស់នៅតាមសិប្បកម្ម ត្រូវបានទាញចូលក្នុងពលកម្មកុមារដោយសារតែស្ថានភាពគ្រួសារ ដែលគួរអោយកត់សំគាល់ គឺបញ្ហាក្រព័ះ និងបំណុល ជាជាងឆន្ទៈផ្ទាល់ខ្លួន ឬសំរាប់ការរីករាយរបស់ខ្លួន។

### ក្រាហ្វិកទី៨ : មូលហេតុដែលធ្វើការ :ចម្លើយរបស់កុមារ




## ៦.២ មូលហេតុដែលកុមារធ្វើការនៅសិប្បកម្មឡូតដ្ឋ : ចម្លើយរបស់កុមារ

បន្ទាប់ពីបានដឹងពីមូលហេតុ ដែលនាំអោយកុមារធ្វើការមក វាជារឿងសំខាន់មួយទៀតដែលត្រូវដឹងថា ហេតុអ្វីបានជា កុមារធ្វើការនៅឡូតដ្ឋ។ គួរកត់សំគាល់ថា កុមារចំនួន១៨នាក់មិនបានឆ្លើយត្រឹមត្រូវនឹងសំណួរនេះ ពីព្រោះពួកគេ ឆ្លើយថាពួកគេធ្វើការនៅឡូតដ្ឋពីព្រោះគ្រួសារគេត្រូវការប្រាក់។ ចម្លើយនេះមិនទាក់ទងនឹងសំណួរទេ ហើយត្រូវ បានដកចេញពីលទ្ធផល ដែលបានបង្ហាញក្នុងក្រាហ្វិកទី៩ខាងក្រោម។

ក្នុងចំណោមពលករកុមារ ដែលរស់នៅតាមភូមិ ចំងាយពីផ្ទះមកកន្លែងធ្វើការជាបញ្ហា។ ឧទាហរណ៏ ៥0%នៃពួកគេបាននិយាយថា គេធ្វើការនៅសិប្បកម្មឡូតដ្ឋ ពីព្រោះវានៅជិតផ្ទះ។ នេះជាការពិត បើគិតដល់ការ ខ្វល់ខ្វាយ របស់ឪពុកម្តាយអំពីសុវត្ថិភាពរបស់កូនស្រី ពីព្រោះពួកគេភាគច្រើនជាកុមារីអាយុ ១៥-១៧ឆ្នាំ។ មូលហេតុផ្សេង ទៀតរួមមាន ការងាយស្រួលរកការងារធ្វើនៅសិប្បកម្មឡូតដ្ឋ (១៩%), ការមានស្គាល់អ្នក កំពុងធ្វើការនៅឡូតដ្ឋ (១៧.៩%), ការងារឡូតដ្ឋមិនចាំបាច់មានជំនាញ ឬបទពិសោធន៏ (៩.៥%), ការងារងាយ រកប្រាក់ (៧.១%), និង មេការចិត្តល្អ (៨.៣%)។

ក្នុងចំណោមពលករកុមារ ដែលរស់នៅតាមសិប្បកម្មឡូតដ្ឋ មូលហេតុចំបងទាំងពីររបស់ពួកគេផ្ទុយគ្នា នឹងមូលហេតុចំបងៗរបស់កុមារ ដែលរស់នៅតាមភូមិ។ តែនេះជាការរកឃើញ ដែលបានរំពឹងទុកជាមុន។ ភាគច្រើននៃកុមារនៅឡូតដ្ឋ (៥៣.៣%) និយាយថាពួកគេធ្វើការនៅសិប្បកម្មឡូតដ្ឋ ពីព្រោះគ្រួសារ ឬញាតិមិត្ត

ពួកគេ ក៏ជាអ្នកធ្វើការ ឬរស់នៅតាមឡឥដ្ឋដែរ។ ក៏ប៉ុន្តែមានតែ ១០%នៃពលករកុមារ ដែលរស់នៅតាមឡឥដ្ឋ បង្ហាញថាឪពុកម្តាយពួកគេមិនអនុញ្ញាតិអោយពួកគេទៅធ្វើការកន្លែងផ្សេងឆ្ងាយពីកន្លែងរស់នៅ។ ការរកឃើញនេះបញ្ជាក់ថា ដោយសារតែរស់នៅតាមសិប្បកម្មឡឥដ្ឋយូរៗទៅ កុមារទំនងជាត្រូវបានគេទាញចូលក្នុងពលកម្មនៅឡឥដ្ឋតែម្តង។

**ក្រាហ្វិកទី៩ : ហេតុអ្វីបានជាកុមារធ្វើការនៅសិប្បកម្មឡឥដ្ឋ?**




## ៦.៣ មូលហេតុនៃការចូលប្រឡូកក្នុងពលកម្មកុមារ : ចម្លើយរបស់ឪពុកម្តាយ

ដើម្បីអោយយល់កាន់តែច្បាស់ពីមូលហេតុនៃការពាក់ព័ន្ធកុមារទៅក្នុងពលកម្មកុមារ ឪពុកម្តាយ និងអ្នកធ្វើការពេញវ័យ ដែលមានកូនធ្វើការនៅឡឥដ្ឋ ត្រូវបានសាកសួរអោយផ្តល់មូលហេតុសំខាន់ជាងគេចំនួនបី អំពីការអនុញ្ញាត្តិអោយកូនពួកគេធ្វើការនៅសិប្បកម្មឡឥដ្ឋ។

យើងគួរតែដឹងពីចំណាត់ថ្នាក់នៃចម្លើយទាំងនេះសិន ពីព្រោះឪពុកម្តាយទាំងនេះបានផ្តល់ចម្លើយផ្សេងៗគ្នាជាច្រើន។ ចម្លើយខ្លះមានន័យស្រដៀងគ្នា ដូចជាគ្រួសារត្រូវការស្បៀងអាហារ គ្រួសារក្រ គ្រួសារមានកូនច្រើនត្រូវចិញ្ចឹម និងគ្រួសារគ្មានប្រាក់គ្រប់គ្រាន់។ ដើម្បីអោយងាយស្រួល ចំលើយទាំងនេះត្រូវបានបញ្ចូលក្នុងចំណាត់ថ្នាក់ប្រភេទតែមួយ គឺគ្រួសារត្រូវការប្រាក់ដើម្បីរស់រានមានជីវិត។ ប្រភេទមួយទៀត ទាក់ទងទៅនឹងការបង្ខិតបង្ខំ

កុមារអោយ ធ្វើការពីសំណាក់ឪពុកម្តាយ។ ចំណាត់ថ្នាក់ប្រភេទនេះរួមបញ្ចូលមូលហេតុ៤ គឺកុមារត្រូវតែធ្វើការដើម្បីជួយឪពុកម្តាយ កុមារត្រូវតែធ្វើការពីព្រោះការងារនៅឡូតដ្ឋបានក្លាយជាមុខរបររបស់គ្រួសារ កុមារត្រូវតែធ្វើការងារនេះ ពីព្រោះគ្រួសារកំពុងរស់នៅក្នុងសិប្បកម្មឡូតដ្ឋ និងកុមារត្រូវតែធ្វើការដើម្បីជំនួសឪពុកម្តាយដែលចាស់ជរា ឬឈឺថ្កាត់។ ដោយដកចេញនូវឪពុកម្តាយម្នាក់ពីការវិភាគ ព្រោះតែគាត់មិនបានផ្តល់ចម្លើយ មូលហេតុទាំងអស់បានមក ពីឪពុកម្តាយចំនួន៤២នាក់ ហើយត្រូវបានផ្តុំជា៥ក្រុម មានគ្រួសារត្រូវការប្រាក់ដើម្បីរស់រានមានជីវិតគ្រួសារត្រូវការប្រាក់ដើម្បីដោះបំណុលឪពុកម្តាយ គ្រួសារត្រូវការកូនជួយការងារនៅឡូតដ្ឋ កុមារចង់ធ្វើការពីព្រោះពួកគេត្រូវការ ប្រាក់សំរាប់ចំណាយលើការរៀនសូត្រ និងកុមារចង់ធ្វើការពីព្រោះពួកគេមានពេលទំនេរ (ក្រាហ្វិកទី១០)។ ជាទូទៅ ឪពុកម្តាយម្នាក់បានផ្តល់មូលហេតុចំនួនពីរគិតជាមធ្យម។

**ក្រាហ្វិកទី១០ : មូលហេតុដែលចូលប្រឡូកក្នុងពលកម្មកុមារ :ចម្លើយរបស់ឪពុកម្តាយ**




លទ្ធផលបានបង្ហាញពីមូលហេតុមួយចំនួន ដែលដូចគ្នារវាងចម្លើយ ដែលផ្តល់ដោយពលករកុមារ (ក្រាហ្វិកទី៨) និងចម្លើយដែលផ្តល់ដោយឪពុកម្តាយ (ក្រាហ្វិកទី១០)។ ការរកឃើញដែលដូចគ្នាមួយ គឺការខ្វះខាតសេដ្ឋកិច្ចគ្រួសារ។ ប្រហែលជា ៩០%នៃឪពុកម្តាយនិយាយថា កូនគាត់ ត្រូវតែធ្វើការព្រោះគ្រួសារត្រូវការប្រាក់ទិញស្បៀង និងតំរូវការចាំបាច់ផ្សេងៗ បើប្រៀបធៀបនឹងចំនួនជិត៨០% ក្នុងចំនោមកុមារដែលនិយាយដូចគ្នានេះ។

មូលហេតុនាំមុខមួយទៀត គឺថាកុមារត្រូវបានឪពុកម្តាយទាញអោយចូលប្រឡូកក្នុងពលកម្មកុមារពីព្រោះតែ គ្រួសារគេរស់នៅទីនោះ ឬឪពុកម្តាយត្រូវការអោយជួយធ្វើការងារ ឬឪពុកត្រូវការអ្នកធ្វើបន្តព្រោះគាត់ចាស់ ឬឈឺ ឬការងារនៅឡូតដ្ឋបានក្លាយជាប្រពៃណីរបស់គ្រួសារ (៥៤.៨%នៃឪពុកម្តាយបានផ្តល់

ចម្លើយទាំងនេះ)។ តួលេខ នេះមានចំនួនខ្ពស់ក្នុងចំណោមឪពុកម្តាយដែលរស់នៅក្នុងសិប្បកម្ម ជាងក្នុងចំណោមឪពុកម្តាយដែលរស់នៅតាមភូមិ (៥៩.៤%ទល់នឹង ៤០%រៀងគ្នា)។ ក្នុងខណៈដែលមូលហេតុជាក់លាក់មួយក្នុងចំណោមឪពុកម្តាយនៅតាម ភូមិ មានទាក់ទងនឹងឪពុកម្តាយចាស់ ឬឈឺ ការរកឃើញខាងលើផ្ទៀងផ្ទាត់អំណះអំណាងថា កុមារដែលរស់នៅ តាមសិប្បកម្ម យូរៗទៅនឹងត្រូវបានទាញបញ្ចូលក្នុងពលកម្មកុមារ ដោយសារតែ ឪពុកម្តាយពួកគេ ដោយមិនអាស្រ័យនឹងស្ថានភាពសេដ្ឋកិច្ចគ្រួសារ។

ការធ្វើការដើម្បីរកលុយទៅរៀន និងការធ្វើការព្រោះកុមារចង់ធ្វើក៏ជាមូលហេតុដែរ តែមូលហេតុនេះពាក់ព័ន្ធនឹងកុមារដែលរស់នៅតាមភូមិច្រើនជាងកុមារ ដែលរស់នៅតាមឡឥដ្ឋ បើគិតតាមសមាមាត្រនៃចំនួនចម្លើយ។ ឧទាហរណ៍ មានឪពុកម្តាយ ដែលរស់នៅតាមឡឥដ្ឋតិចណាស់ដែលឆ្លើយថាគាត់អនុញ្ញាតិអោយកុមារធ្វើការ ព្រោះគេត្រូវ ការប្រាក់ទៅរៀន (១ ក្នុង ៣២ នាក់) ឬព្រោះតែកូនគាត់ចង់ធ្វើការ (៣ ក្នុង ៣២នាក់)។ ក៏ប៉ុន្តែ សមាមាត្រនៃឪពុកម្តាយ ដែលឆ្លើយដូចខាងលើមានចំនួនច្រើនគួរសមក្នុងចំណោមឪពុកម្តាយដែលរស់នៅតាមភូមិ គឺ៣នាក់ក្នុងចំនោម ១០នាក់អនុញ្ញាតិអោយកូនធ្វើការ ព្រោះត្រូវការប្រាក់ទៅរៀន និង៤នាក់ក្នុង១០នាក់អោយ កូនទៅធ្វើការ ព្រោះកូនចង់ធ្វើការ។ ទោះបីជាចំនួនសរុប នៃឪពុកម្តាយនៅតាមភូមិដែលបានសម្ភាសន៏ មានចំនួនតិច (តែ១០នាក់ប៉ុណ្ណោះ) ការរកឃើញនេះទំនងជាគួរអោយជឿជាក់បាន និងដូចគ្នានឹងចម្លើយដែលផ្តល់ដោយ កុមារផ្ទាល់ ដូចបានបង្ហាញក្នុងក្រាហ្វិកទី៨ខាងលើ។

មូលហេតុជាក់លាក់មួយទៀត ចំពោះអ្នកដែលរស់នៅតាមសិប្បកម្មឡឥដ្ឋ គឺថាឪពុកម្តាយទាញកូនអោយចូលប្រឡូកក្នុងពលកម្មកុមារដោយសារជំពាក់បំណុលគេ។ ទោះបីជាភាគរយមានចំនួនតិច (តែឪពុកម្តាយ ៣នាក់ប៉ុណ្ណោះ) បើប្រៀបធៀបនឹងមូលហេតុផ្សេងទៀត ការរកឃើញនេះបានឆ្លុះបញ្ចាំងពីស្ថានភាពមួយ ដែលគ្រួសារមួយចំនួនត្រូវបានយកមករស់នៅ និងធ្វើការនៅឡឥដ្ឋដើម្បីដោះបំណុល។ និយាយអោយខ្លី កុមារដែលរស់នៅតាមឡឥដ្ឋ ចូលប្រឡូកក្នុងពលកម្មកុមារភាគច្រើនដោយសារតែកង្វះខាតសេដ្ឋកិច្ចគ្រួសារ និងតំរូវការពលកម្មកុមារ របស់ឪពុកម្តាយ។

## ៦.៤ មូលហេតុដែលជួលកុមារអោយធ្វើការ : ចម្លើយរបស់ម្ចាស់សិប្បកម្ម ឬមេការ

ម្ចាស់សិប្បកម្ម ឬមេការ ត្រូវបានសួរថា តើហេតុអ្វីបានជាមានកុមារមកធ្វើការនៅសិប្បកម្ម ហើយហេតុអ្វីបានជាពួកគាត់ជួលកុមារអោយធ្វើការ។ ដោយអាស្រ័យលើចំណុចរសើបនៃសំនួរនេះ ម្ចាស់សិប្បកម្ម ឬមេការមិនបានឆ្លើយនឹងសំណួរទាំងនេះគ្រប់ៗគ្នាទេ។ ជាពិសេសម្ចាស់សិប្បកម្ម ឬមេការចំនួន៥នាក់បានបដិសេធន៏មិនឆ្លើយនឹង សំណួរនេះ។ ការបដិសេធន៏នេះមិនមែនមិនបានរំពឹងទុកជាមុនទេ ពីព្រោះការសិក្សានេះ ក៏បានរៀបចំដើម្បីប្រមូល ទិន្នន័យប្រភេទនេះតាមវិធីប្រយោលមួយផ្សេងទៀត គឺតាមសំណួរបីផ្សេងទៀត រួមមានការពេញចិត្តនឹងមានកុមារ ធ្វើការនៅឡឥដ្ឋ ចំនុចវិជ្ជមានអំពីពលករកុមារ និងចំនុចអវិជ្ជមានអំពីពលករកុមារ។

បើតាមម្ចាស់សិប្បកម្ម ឬមេការ កុមារដែលមកធ្វើការនៅឡូតដ្ឋ ក៏ព្រោះតែមូលហេតុបីយ៉ាង។ មូលហេតុទីមួយពាក់ព័ន្ធនឹងការងារនៅឡូតដ្ឋ ដូចជាការងារមិនត្រូវការជំនាញ ការងារងាយស្រួលសំរាប់កុមារធ្វើ និងការងារមិនទាមទារបទបញ្ជាតឹងតែង (ដូចជាកុមារអាចមកធ្វើថ្ងៃណាដែលគេចង់ធ្វើក៏បាន)។ មូលហេតុទីពីរគឺថាមានកុមារនៅតាមភូមិជិតសិប្បកម្មនាំគ្នាមកធ្វើការ។ មូលហេតុទីបី កុមារបានបោះបង់ចោលការសិក្សា ហើយស្វែងរកការងារធ្វើដើម្បីរកលុយ។

ទាក់ទងទៅនឹងមូលហេតុ ដែលនាំអោយម្ចាស់ ឬមេការសិប្បកម្មជួលកុមារអោយធ្វើការ មានមូលហេតុសំខាន់៧បី។ ទីមួយគឺទាក់ទិនទៅនឹងកង្វះខាតសេដ្ឋកិច្ចគ្រួសាររបស់កុមារ (៩នាក់ក្នុចំនោមមេការទាំង១០នាក់)។ ជាពិសេសម្ចាស់សិប្បកម្ម ឬមេការមើលឃើញថា កុមារក្រហើយត្រូវការជំនួយ ដូចនេះពួកគាត់ក៏អោយការងារកុមារធ្វើតែម្តងទៅ។

ដូចមេការពីរនាក់បាននិយាយ :

| |
|---|
| "កុមារត្រូវតែធ្វើការ ទោះជាយ៉ាងណាក៏ដោយ ដើម្បីរកប្រាក់សំរាប់គ្រួសាររបស់គេ បើគិតដល់ស្ថានភាពគ្រួសារពួកគេ។ ដូច្នេះវាជាការល្អប្រសើរជាង បើផ្តល់ការងារអោយពួកគេធ្វើនៅទីនេះ ដែលយើងទាំងអស់ ដឹងច្បាស់ថា វាអាចជួយដល់គ្រួសារគេផង និងទប់ស្កាត់មិនអោយពួកគេ ទៅប្រព្រឹត្តអំពើណាមួយ ដែលប្រឆាំងនឹង សង្គមផង។" |

មេការម្នាក់ទៀតបាននិយាយប្រហាក់ប្រហែលគ្នានេះដែរ :

| |
|---|
| "យើងដឹងពីច្បាប់ពីពលកម្មកុមារ។ ក៏ប៉ុន្តែបើយើងមិនអោយពួកគេធ្វើការទេ តើនរណានឹងជួយពួកគេ? ពួកគេ មកពីគ្រួសារដែលក្រីក្រ។ ដូច្នេះផ្តល់ការងារខ្លះអោយគេធ្វើ មានន័យថាជួយពួកគេ។ ហើយយើងមិនចង់ឃើញពួក គេក្លាយជាពលករកុមារនៅតាមព្រំដែនខ្មែរ-ថៃ ដែលការងារនៅទីនោះឃោរឃៅ កេងប្រវ័ញ្ច និងបោកប្រាស់ សំរាប់ពួកគេឡើយ។" |

មូលហេតុទីពីរ គឺថាម្ចាស់ ឬមេការសិប្បកម្មមិនអាចទ្រាំនឹងការអង្វរសុំរកការងារធ្វើរបស់កុមារបាន (ម្ចាស់ ឬមេការ៤នាក់បាននិយាយដូច្នេះ)។ ដូចគាត់បានិយាយថា "វាពិបាកនឹងទ្រាំនឹងកុមារមកអង្វរសុំរកការងារធ្វើនៅ ទីនេះណាស់ ជាពិសេសនៅពេលដែលពួកគេមកគ្នាយ៉ាងច្រើន ហើយនៅតែទទូចសួររកការងារធ្វើ។" មូលហេតុទីបី គឺថាគ្រួសាររបស់កុមារខ្លះធ្វើការនៅសិប្បកម្មឡូតដ្ឋតែម្តង ហើយឪពុកម្តាយទាំងនេះទាមទារអោយកូនគាត់បានធ្វើការដែរ ទើបគាត់ព្រមធ្វើការ (តាមចម្លើយរបស់មេការ ឬម្ចាស់សិប្បកម្ម៤នាក់)។ ជាសរុបចម្លើយដែលបានមកពី សំនួរដែលផ្ទាល់អំពីការជួលកុមារអោយធ្វើការ បង្ហាញពីបំណងល្អរបស់ថៅកែ។

ការប្រើសំនួរជាប្រយោលសន្មតថា និយោជកនឹងចូលចិត្តពលកម្មកុមារ ប្រសិនបើពួកគាត់ពេញចិត្តនឹងពលករកុមារ ឬមានចំណុចវិជ្ជមានជាច្រើន ដែលត្រូវនិយាយអំពីពលករកុមារដែលពួកគាត់មាន។ គួរកត់សំគាល់ថា មិនគ្រប់និយោជកដែលបានសម្ភាសន៏ទេ ដែលបានឆ្លើយនឹងសំនួរអំពីការពេញចិត្ត ហើយអ្នកដែលពេញចិត្តនឹងពលករកុមារមានចំនុចល្អជាច្រើនត្រូវនិយាយអំពីកុមារ។ ឯអ្នកផ្សេងទៀត ច្រើននិយាយពីចំនុចអវិជ្ជមានរបស់ពលករកុមារជាងចំនុចវិជ្ជមាន (តារាងទី៥)។

៦នាក់ក្នុងចំណោមម្ចាស់ ឬមេការសិប្បកម្ម ១៥នាក់និយាយថាគាត់ពេញចិត្តនឹងមានកុមារមកធ្វើការនៅក្នុងសិប្បកម្មរបស់គាត់ ឯ៤នាក់ផ្សេងទៀតគាត់និយាយថាមិនពេញចិត្ត និង៥នាក់ទៀតមិនបានសំដែងការពេញចិត្ត ឬមិនពេញចិត្តអ្វីទាំងអស់ (តារាងទី៥)។ លើសពីនេះទៅទៀត ម្ចាស់ ឬមេការសិប្បកម្មខ្លះយល់ឃើញពីចំនុចវិជ្ជមានមួយចំនួន របស់ពលករកុមាររបស់គាត់។ តាមចម្លើយរបស់គាត់ កុមារងាយស្រួលនឹងគ្រប់គ្រងកុមារមកធ្វើការទាន់ពេល កុមារអាចធ្វើការដោយម្ចាស់ការបានទៅតាមទៅតាមកុងត្រា កុមារធ្វើការលឿន ហើយប្រឹងប្រែង និងកុមារងាយស្រួលជញ្ជូនឥដ្ឋ។

ក៏ប៉ុន្តែ ចំនុចទាំងនេះ ត្រូវបានមើលឃើញផ្ទុយមកវិញដោយម្ចាស់ ឬមេការសិប្បកម្មផ្សេងទៀត។ ឧទាហរណ៏ ម្ចាស់ឬមេការសិប្បកម្ម៤នាក់និយាយថា ពួកគាត់មានការលំបាកក្នុងការគ្រប់គ្រងកុមារ។ ថែមលើនេះទៀត ពួកគាត់មានចំនុចអវិជ្ជមានមួយចំនួនអំពីពលករកុមារដូចជា កុមារធ្វើការមិនសូវប្រុងប្រយ័ត្ន និងមិនប្រាកដប្រជា មិនប្រឹងប្រែងធ្វើការ លេងសើចច្រើន បង្កការខូចខាតដល់សិប្បកម្ម មិនមកធ្វើការទៀងទាត់ ឈឺថ្កាត់ ឬរងរបួស ដោយឥដ្ឋធ្លាក់លើ និងត្អូញត្អែរច្រើនណាស់។

គួរកត់សំគាល់ផងដែរថា ការអង្កេតនៅកន្លែងស្រាវជ្រាវបង្ហាញថាម្ចាស់ ឬមេការសិប្បកម្មខ្លះមានការអល់អែកនឹងឆ្លើយសំនួរនេះ។ វាគ្មានការសង្ស័យទេថា ពួកគេដឹងពីបញ្ហាពលកម្មកុមារ ហើយអាចមានបំណងលាក់ពីបំណងពិតរបស់ខ្លួនទាក់ទងនឹងការជួលកុមារអោយធ្វើការនៅឡឥដ្ឋ។ ទោះជាដូច្នេះក្តី ការរកឃើញនៅផ្នែកនេះ លាតត្រដាង ពីមូលហេតុមួយចំនួនដ៏វិញការជួលកុមារអោយធ្វើការ ដែលមានចាប់ពីការមានសមានចិត្តល្អ ដោយសារតែគ្រួសារកុមារជាគ្រួសារក្រីក្រ រហូតដល់កុមារជាកំលាំងពលកម្មដ៏ល្អ នៅសិប្បកម្មឡឥដ្ឋ។

## តារាងទី៥ ៖ការពេញចិត្តចំពោះពលករកុមាររបស់ម្ចាស់ និងមេការសិប្បកម្មឡឥដ្ឋ

| | | |
|---|---|---|
| **ក.** | **ការពេញចិត្តរបស់ថៅកែឬមេការចំពោះពលករកុមារ** | |
| | ពេញចិត្ត | ៥ |
| | មិនពេញចិត្ត | ៤ |
| | មិនសំរេច | ៤ |
| | មិនឆ្លើយ | ២ |
| | **ចំនួនអ្នកឆ្លើយ** | **១៥** |
| **ខ.** | **ចំណុចល្អរបស់ពលករកុមារ** | |
| | ងាយស្រួលប្រើធ្វើការ មិនបាច់បង្ខំ | ៤ |
| | គោរពពេលវេលា | ២ |
| | ងាយស្រួលធ្វើការតាមកុងត្រា | ២ |
| | ធ្វើការរហ័សនិងពូកែធ្វើការ | ១ |
| | ងាយស្រួលជញ្ជូនឥដ្ឋ | ១ |
| | **ចំនួនអ្នកឆ្លើយ** | **៥** |
| **គ.** | **ចំណុចខ្វះខាតរបស់ពលករកុមារ** | |
| | ពិបាកគ្រប់គ្រង | ៤ |
| | មិនប្រយ័ត្ន លេងសើចច្រើន | ៤ |
| | អាចនាំអោយមានការខូចខាតផ្សេងៗ | ៣ |
| | ផលិតភាពទាប | ២ |
| | មិនមកធ្វើការទៀងទាត់ | ២ |
| | ឈឺ ឬអាចរងរបួសដោយសារឥដ្ឋ | ១ |
| | ត្អូញត្អែរច្រើន | ១ |
| | **ចំនួនអ្នកឆ្លើយ** | **១០** |

## ៧. លក្ខខណ្ឌការងារនៅសិប្បកម្មឡឥដ្ឋ

ការយល់ដឹងពីលក្ខខណ្ឌការងារនៃពលកម្មកុមារ ជួយអោយយើងយល់ដឹងអំពីគ្រោះថ្នាក់នៃការងារ ការប្រឈមរបស់កុមារនឹងការងារមានគ្រោះថ្នាក់ និងផលវិបាកនៃផលប៉ះពាល់នៃការងារមកលើការលូតលាស់របស់កុមារ។ លើសពីនេះទៀត ផលប៉ះពាល់នៃលក្ខខណ្ឌការងារដែលមានគ្រោះថ្នាក់អាចការពារ និង កាត់បន្ថយបាន តាមរយៈការដឹងដោយខ្លួនឯង និងការអនុវត្តន៍ល្អនៃការថែទាំសុខភាព។ លក្ខខណ្ឌការងារ នៅសិប្បកម្មឡឥដ្ឋត្រូវបានពិនិត្យសិក្សាដោយប្រើប្រាស់ទិន្នន័យរួមរបស់សិប្បកម្មឡឥដ្ឋ ដែលបានពីកុមារ ដែលជាអ្នកឆ្លើយនឹងសំណួរ។ បន្ទាប់មកការយល់ឃើញរបស់ឪពុកម្តាយ អំពីកន្លែងធ្វើការរបស់កុមារត្រូវបានបង្ហាញ។ ជាចុងក្រោយ ទិន្នន័យ

អំពីសុវត្ថិភាព និងបទបញ្ហាការងារ ដែលទទួលបានពីកុមារ ឪពុកម្តាយ និងម្ចាស់-មេការនឹងសង្ខេបបង្ហាញនៅផ្នែកខាងក្រោមនេះដែរ។

ការសង្កេត ដែលបានមកពីការចុះប្រមូលទិន្នន័យបង្ហាញថាបរិយាកាសសំរាប់ធ្វើការងារនៅសិប្បកម្មឡឥដ្ឋអាចបង្កគ្រោះថ្នាក់ដល់សុខភាពកុមារ ដោយសារតែបរិយាកាសការងារគ្មានសុវត្ថិភាពដូចជា កំដៅ ផ្សែង ផេះក្តៅ ផេះហុយ កំទេចឥដ្ឋបាក់បែកគ្រប់ទីកន្លែង រយៈពេលធ្វើការយូរ និងការងារកុមារធ្វើជាការងារធ្ងន់ធ្ងរ និងអាចមានគ្រោះថ្នាក់។ លើសពីនេះទៀត សិប្បកម្មឡឥដ្ឋមួយពោរពេញដោយក្លិនលាមកសត្វមិនអាចទ្រាំបាន រីឯសិប្បកម្មមួយចំនួនទៀតគ្មានអនាម័យ ដោយសារកន្លែងមិនស្អាត ហើយកម្មករបរិភោគទឹកភ្លៀង រឺទឹកស្រះដោយផ្ទាល់តែម្តង។

## ៧.១ ការវាយតំលៃរបស់ពលករកុមារអំពីកន្លែងធ្វើការរបស់ពួកគេ

សំណួរទ្វេចម្លើយចំនួន៧ត្រូវបានប្រើប្រាស់ ដើម្បីចាប់យកលក្ខខណ្ឌការងារទូទៅនៅសិប្បកម្មឡឥដ្ឋដោយផ្អែកលើចំនេះដឹងរបស់ពលករកុមារ[២៣]។ សំណួរទាំងនេះរួមមាន តើអ្នកឆ្លើយគិតថាកន្លែងធ្វើការរបស់គាត់ ១) មានសំភារៈសង្គ្រោះបឋមរឺទេ? ២) ក្តៅខ្លាំងពេករឺទេ? ៣) មានកំទេចផេះហុយរឺទេ? ៤) អសុវត្ថិភាពដោយសារតែមានឥដ្ឋធ្លាក់លើរឺទេ? ៥) មានអនាម័យរឺទេ? ៦) ជាកន្លែងសុវត្ថិភាពសំរាប់កុមាររស់នៅទីនោះរឺទេ? និង ៧) អាចមានគ្រោះថ្នាក់ដល់សុខភាពពួកគេរឺទេ? សំណួរនីមួយៗត្រូវបានបំលែងទៅជាសន្ទស្សន៍នៃលក្ខខណ្ឌការងាររបស់សិប្បកម្មនិមួយៗ ដោយសិប្បកម្មនិមួយៗត្រូវបានចាត់ទុកថាមានលក្ខខណ្ឌធ្វើការងារមិនល្អប្រសើរប្រសិនបើមានយ៉ាងតិច៥០%នៃពលករកុមារផ្តល់ចំលើយយ៉ាងដូច្នេះ[២៤]។

លក្ខណៈវិនិច្ឆ័យខាងលើនេះបង្កអោយមានការដកចេញនូវសិប្បកម្មចំនួន៩ ក្នុងចំណោមសិប្បកម្មទាំង២៥ ព្រោះ សិប្បកម្មទាំងនេះមានពលករកុមារសម្ភាសន៏តែម្នាក់ ឬពីរនាក់ដែលជាចំនួនមិនគ្រប់គ្រាន់សំរាប់ធ្វើការវិភាគ។ សន្ទស្សន៍ទាំង៧ត្រូវបានបង្ហាញនៅក្នុងក្រាហ្វិកទី១១ ខាងក្រោម។ ស្របទៅតាមការអង្កេត ការរកឃើញខាងលើ បង្ហាញថា ពលករកុមារនៅសិប្បកម្មឡឥដ្ឋដឹង ច្បាស់ពីកន្លែងធ្វើការងារមានការយល់ ដែលមានគ្រោះថ្នាក់។ ពាក់ព័ន្ធនឹងសិប្បកម្មឡឥដ្ឋ៤កន្លែង ដែលពលករកុមារចាត់ទុកថាជា កន្លែងល្អសំរាប់ កុមាររស់នៅ និងជាកន្លែងធ្វើការល្អដែលគ្មានគ្រោះថ្នាក់។ ការផ្ទៀងផ្ទាត់បន្តទៀតទៅលើទិន្នន័យ និងទីកន្លែងធ្វើអង្កេត បានបង្ហាញដូចតទៅ : ទី១ សិប្បកម្មឡឥដ្ឋមួយ អាចជាកន្លែងដ៏ល្អសំរាប់រស់នៅ និងធ្វើការ ពីព្រោះវាស្ថិតនៅក្នុងទីតាំងសាលារៀនមួយ។ ទី២ ការពន្យល់មួយបែបទៀតអាចពន្យល់ពីសិប្បកម្មផ្សេងទៀតបាន នោះគឺ

---

[២៣] ទិន្នន័យបានពីការសង្កេតផ្ទាល់ ក៏ជាប្រភពទិន្នន័យមួយល្អដែរ សំរាប់ការងារនេះ។ ក៏ប៉ុន្តែ វិធីអង្កេតត្រូវបានប្រើប្រាស់ក្នុង ការសិក្សានេះដើម្បីជាការបំពេញបន្ថែម ដើម្បីចាប់យក ចំណេះនិងការដឹងរបស់អ្នកឆ្លើយ អំពីល័ក្ខខ័ណ្ឌការងារនៅឡឥដ្ឋ។

[២៤] និយមន័យអំពីលក្ខខណ្ឌការងារល្អ ដែលមានភាពច្បាស់លាស់ជាងនេះ អាចយកមកប្រើបាន ដូចជាការកំណត់ថា យ៉ាងហោចណាស់ ក៏ត្រូវមានអ្នកផ្តល់សំភាសន៏ចំនួន៧៥% ដែលយល់ស្របតាមអំណះអំណាងនិមួយៗ។

ពលករកុមារជាច្រើន ដែលធ្វើការក្នុងសិប្បកម្មឡឥដ្ឋអាចសុំាទៅនឹង កន្លែងធ្វើការដែលមានបញ្ហាអនាម័យ ដូចជា ផេះ ដែលក្តៅ ហើយហុយ, កំទេចឥដ្ឋ ដែលបែកបាក់ និងការធ្លាក់ឥដ្ឋ វាអាចលែងក្លាយ ជាបញ្ហាទៀតហើយ សំរាប់ពួកគេ។ បន្ថែមពីនេះទៀត ពួកគេអាចមិនដឹង ពីផលប៉ះពាល់ជាអវិជ្ជមានវែងឆ្ងាយ នៃលក្ខខណ្ឌការងារ ដែលមានគ្រោះថ្នាក់ ពីព្រោះផលប៉ះពាល់នោះ ជាទូទៅមិនអាចដឹងបាន។ ជាក់ស្តែង សិប្បកម្មឡឥដ្ឋ ទាំងនោះ ត្រូវបានយល់ឃើញ ដោយយ៉ាងតិច ៥០%នៃពលករកុមារថា មានលក្ខខណ្ឌការងារ មិនល្អ ទៅតាម សន្ទស្សន៍បីះ កំដៅដែលមិនអាច ទ្រាំបាន (១០០%), ការហុយផេះ (១០០%), ការធ្លាក់ឥដ្ឋទៅលើពលករ (១០០%)។





**ក្រាហ្វិកទី១១ : ស្ថានភាពការងារនៅសិប្បកម្មឡឥដ្ឋ**



លើសពីនេះទៅទៀត សិប្បកម្មទាំងអស់លើក លែងតែ១ប៉ុណ្ណោះ ត្រូវបានគេមើលឃើញថាមានលក្ខខណ្ឌការងារមិនល្អ កង្វះអនាម័យ (១៥ក្នុង១៦សិប្បកម្ម) ហើយគ្មានសំភារៈសង្គ្រោះបឋម (១៥ក្នុងចំណោម១៦សិប្បកម្ម) ។ ចុងបញ្ចប់មាន ១២ក្នុងចំនោម១៦សិប្បកម្មឡឥដ្ឋ ដែលត្រូវបានគេចាត់ទុកថា ជាកន្លែងដែលគ្មានសុវត្ថិភាពសំរាប់កុមារក្នុងការរស់នៅ និងជាកន្លែងធ្វើការ ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់សុខភាព។

### *៧.២ សិប្បកម្មឡឥដ្ឋជាកន្លែងមានសុវត្ថិភាពសំរាប់កុមារ : ចម្លើយរបស់ឪពុកម្តាយ*

ឪពុកម្តាយទាំងអស់ត្រូវបានសួរថា តើពួកគាត់គិតថាសិប្បកម្មឡឥដ្ឋជាកន្លែងសុវត្ថិភាពសំរាប់កុមារក្នុងការរស់នៅ និងធ្វើការដែររឺទេ។ ការដែលគួរអោយចាប់អារម្មណ៍ គឺថា៣០%នៃឪពុកម្តាយ (១១ក្នុងចំណោម៣៣នាក់ ដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ និង២នាក់ក្នុងចំណោម១០នាក់នៃអ្នកដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ) បានឆ្លើយថា "បាទ/ចាស" នៅគ្រប់សំនួរទាំងពីរនេះ។ នេះមានន័យថា ឪពុកម្តាយមួយចំនួនធំចាត់ទុក ថាសិប្បកម្មឡឥដ្ឋជាកន្លែងសុវត្ថិភាពក្នុងការរស់នៅផង និងក្នុងការធ្វើការងារផងសំរាប់កូនៗរបស់គាត់។ ទោះជាមិនមែនគ្រប់ក្មេងដែលរស់នៅ និងធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋសុទ្ធតែរងគ្រោះទាំងអស់នោះក៏ដោយ។ ទស្សនៈរបស់ឪពុកម្តាយខាងលើ អាចបណ្តាលអោយមានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើសុខមាលភាពកុមារ។ ឪពុកម្តាយផ្សេងទៀតចំនួន៦៦.៧%យល់ថា សិប្បកម្មឡឥដ្ឋមិនសមជាកន្លែងសំរាប់កុមារក្នុងការរស់នៅ និងធ្វើការងារឡើយ។ ពួកគេបានលើកឡើង៤ចំនុចដែលគួរអោយបារម្ភ អំពីសិប្បកម្មឡឥដ្ឋមិនមែនជាកន្លែង សំរាប់កុមាររស់នៅ: ផេះហុយ, ការដើរជាន់លើផេះក្តៅ, ការដែលអាចមានឥដ្ឋធ្លាក់លើ, និងការមុត ឬរបួសដោយ សារតែកំទេចឥដ្ឋ។ ពាក់ព័ន្ធនឹងសិប្បកម្មឡឥដ្ឋជាកន្លែង ដែលមិនមានសុវត្ថិភាពសំរាប់កុមារធ្វើការងារ ការពន្យល់ជាច្រើនត្រូវបាន ផ្តល់ដោយឪពុកម្តាយទាំងនោះ។ បន្ថែមលើការព្រួយបារម្ភទាំង៤ខាងលើ ពួកគេរាប់បញ្ចូលអំពីគ្រោះថ្នាក់ដែល ទាក់ទងទៅនឹងការធ្វើការជាមួយម៉ាស៊ីនធ្វើឥដ្ឋ, បញ្ហាអនាម័យ ឬគ្រោះថ្នាក់ដោយ ឡានដឹកទំនិញអាចកិនទៅលើ ក្មេងៗ។

## ៨. សុវត្ថិភាពការងារ និងបទបញ្ជាការងារ

ការងារខ្លះៈដូចជា ការបញ្ជាម៉ាស៊ីនធ្វើឥដ្ឋ ការជីក និងលីសែងដីឥដ្ឋ ការដុតភ្លើងឡ និងការសំអាតផេះសុទ្ធតែ មានគ្រោះថ្នាក់ដល់កុមារ ដែលធ្វើការងារនេះ។ ការងារផ្សេងទៀត ដូចជាការលើកឥដ្ឋ និងរុញរទេះដឹកឥដ្ឋវាមិនសូវជាមានគ្រោះថ្នាក់ទេ ប្រសិនបើមានការចាត់ចែងបានត្រឹមត្រូវ។ ផ្នែកនេះ នឹងសរុបពីចំណេះដឹង និងការអនុវត្តន៏ពីមានសុវត្ថិភាពការងារ និងបទបញ្ជា ដោយផ្អែកលើការសម្ភាសន៏ជាមួយកុមារ, ឪពុកម្តាយ, ហើយនិងម្ចាស់ ឬមេការសិប្បកម្ម។ ជាក់ស្តែង អ្នកឆ្លើយសម្ភាសន៏ទាំងអស់ត្រូវបានសួរថាតើមានការងារណាខ្លះដែលកុមារត្រូវបានហាមឃាត់មិនអោយធ្វើនៅក្នុងសិប្បកម្មឡឥដ្ឋ។ តើពួកគេប្រតិបត្តិតាមយ៉ាងដូចម្តេច និងតើពលករកុមារបានទទួលការណែនាំអំពីសុវត្ថិភាពការងារមុនពេលចាប់ផ្តើមធ្វើការដែររឺទេ។

## ៨.១ ការងារហាមឃាត់សំរាប់ពលករកុមារ

លទ្ធផលនៃការសម្ភាសន៍ជាមួយពលករកុមារ បង្ហាញអោយឃើញថាភាគច្រើននៃកុមារត្រូវបានអនុញ្ញាតិអោយធ្វើគ្រប់កិច្ចការ។ យោងទៅលើពលករកុមារ៧១នាក់ (៥៤%នៃកុមារដែលទទួលការសម្ភាសន៍) គ្មាននរណាម្នាក់ត្រូវបានគេហាមឃាត់មិនអោយធ្វើការងារដែលហាមឃាត់សំរាប់កុមារទេ ចាប់តាំងពីពួកគេចូលធ្វើការមក។ គួរកត់សំគាល់ថា កុមារដែលរស់នៅក្នុងសិប្បកម្មឡតដ្ឋដែលនិយាយថាគ្មានការហាមឃាត់ មានចំនួនច្រើនជាងកុមារដែលមកពីភូមិ (៦៤% និង៥០%រៀងគ្នា)។ កុមារផ្សេងទៀត (៦១នាក់) បាននិយាយថាពួកគេត្រូវបានហាមឃាត់មិនអោយធ្វើ ការដែលទាក់ទងនឹង : ម៉ាស៊ីនធ្វើឥដ្ឋ, កាត់ឥដ្ឋ, ដឹកឥដ្ឋ, កិនឥដ្ឋ និងលាយឥដ្ឋ, លីសែងដីឥដ្ឋ, ដុតភ្លើងឡឥដ្ឋ, ហើយនិងសំអាតផេះក្តៅ (ក្រាហ្វិកទី១២)។ តែទោះជាយ៉ាងណាក៏ដោយសមាមាត្រនៃពលករកុមារដែលបាននិយាយថា បានទទួលការហាមឃាត់ធ្វើការងារទាំងនោះ នៅមានចំនួនតិចតួចណាស់។ លើកលែងតែករណីបញ្ហាម៉ាស៊ីនធ្វើឥដ្ឋ ព្រោះមាន ៥៧%នៃកុមារដែលឆ្លើយថាពួកគេត្រូវបានហាមឃាត់មិនអោយធ្វើការជាមួយគ្រឿងម៉ាស៊ីន។

**ក្រាហ្វិកទី១២ : ការងារដែលហាមឃាត់មិនអោយកុមាធ្វើ :របាយការណ៍របស់កុមារ**




លទ្ធផលដែលបង្ហាញថា ប្រហែលជា ៥៧%នៃពលករកុមារដែលបានសម្ភាសន៍ ត្រូវបានហាមឃាត់មិនអោយធ្វើការ ទាក់ទងនឹងម៉ាស៊ីនធ្វើឥដ្ឋ វាស្របគ្នាទៅនឹងចម្លើយដែលផ្តល់ដោយឪពុកម្តាយ និងម្ចាស់ ឬមេការសិប្បកម្ម។ ម្យ៉ាងទៀត ២ភាគ៣នៃឪពុកម្តាយ (២៨នាក់ក្នុងចំណោមឪពុកម្តាយ៤៣នាក់) និយាយថា ពួកគេដឹង

ថា ធ្វើការជាមួយម៉ាស៊ីនធ្វើឥដ្ឋត្រូវបានហាមឃាត់ចំពោះកុមារអាយុក្រោម១៨ឆ្នាំ ក្នុងខណៈដែលម្ចាស់និងមេការសិប្បកម្មចំនួន១០នាក់ក្នុងចំណោម១៥នាក់ក៏និយាយដូចគ្នានេះដែរ។ ម្យ៉ាងទៀត មានភស្តុតាងមួយចំនួន ដែលបង្ហាញថា សិប្បកម្មឡឥដ្ឋខ្លះមិនមានច្បាប់ណាមួយក្នុងការហាមឃាត់កុមារមិនអោយធ្វើការជាមួយម៉ាស៊ីន ធ្វើឥដ្ឋនោះទេ (ឪពុកម្តាយ១១នាក់ និងម្ចាស់ ឬមេការសិប្បកម្មចំនួន៣នាក់ក្នុងចំណោម១៥នាក់បាននិយាយ ដូច្នេះ)។

## ៨.២ ការទទួលបាននូវព័ត៌មានអំពីសុវត្ថិភាពការងារ

ដើម្បីធានាសុវត្ថិភាពការងារ ក្នុងលក្ខខណ្ឌការងារដែលងាយរងគ្រោះ ពលករកុមារគួរតែទទួលបាននូវព័ត៌មាន អំពីគ្រោះថ្នាក់ទាំងនេះ ហើយនិងវិធានការដើម្បីទប់ស្កាត់វា។ ពលករកុមារត្រូវបានសួរថាតើពួកគេបានទទួល ព័ត៌មានអំពីសុវត្ថិភាពការងារដែររឺទេ, តើបានទទួលញឹកញាប់ក៏រិតណា, ហើយផ្តល់ដោយអ្នកណា។

ម្ចាស់សិប្បកម្ម ឬមេការទាំងអស់លើកលែងតែ ២នាក់ប៉ុណ្ណោះបានរាយការណ៍ថា ពលករកុមាររបស់ពួកគេបានទទួលការណែនាំអំពីសុវត្ថិភាពការងារមុននឹងចាប់ផ្តើមធ្វើការ។ តាមរយៈពលករកុមារ ដែលបានសម្ភាសន៏ ប្រហែលជា ៥២%ប៉ុណ្ណោះដែលបានទទួលពត៌មាននេះ (៥៦.៣%នៃកុមារមិនរស់នៅតាមសិប្បកម្ម និង៣៨.៩% នៃកុមាររស់នៅតាមសិប្បកម្មឡឥដ្ឋ)។ ក្នុងចំណោមកុមារដែលធ្លាប់ទទួលបានព័ត៌មានអំពីសុវត្ថិភាពការងារ ភាគ ច្រើនរាយការណ៍ថាពួកគេធ្លាប់បានទទួលចំនួន ១-៣ដង (តារាងទី៦)។

ទោះជាយ៉ាងណាក៏ដោយ មានកុមារជាច្រើនមិនមែនបានទទួលព័ត៌មាននេះពីម្ចាស់សិប្បកម្ម ឬមេការនោះទេ គឺមានត្រឹមតែ ៤០.៤%នៃកុមារដែលមិនរស់នៅតាមសិប្បកម្ម និង២៨.៦%នៃកុមារដែលរស់នៅតាមសិប្បកម្មដែល បានទទួលព័ត៌មាននេះពីម្ចាស់សិប្បកម្ម ឬមេការ។ និយាយម្យ៉ាងវិញទៀត កុមារទាំងនេះដឹងពីសុវត្ថិភាពការងារពីប្រភពផ្សេង មានឪពុកម្តាយ ឬសាច់ញាតិ និងអង្គការក្រៅរដ្ឋាភិបាលជាដើម។ តាមរយៈឪពុកម្តាយដែលបានសម្ភាសន៏ មានឪពុកម្តាយដែលរស់នៅតាមសិប្បកម្មចំនួន៧នាក់ប៉ុណ្ណោះដែលបានរាយការណ៍ថា មានការត្រួតពិនិត្យអំពីសុវត្ថិភាពការងារនៅក្នុងសិប្បកម្មឡឥដ្ឋម្តងម្កាលពីសំណាក់ម្ចាស់សិប្បកម្ម ឬមេការ រីឯឪពុកម្តាយផ្សេងទៀតអះអាងថា កូនរបស់គាត់ដែលធ្វើការដឹងអំពីសុវត្ថិភាពការងារតាមរយៈឪពុកម្តាយ ឬតាមរយៈអ្នកដទៃ។

គួរអោយចាប់អារម្មណ៏ថា ជិត៥០% នៃពលករកុមារទាំងអស់ដែលធ្លាប់ទទួលបាននូវព័ត៌មានអំពីសុវត្ថិភាពការងារនិយាយថា លើកចុងក្រោយបង្អស់ដែលពួកគេទទួលបានព័ត៌មានគឺ២ ឬ៣ថ្ងៃមុនការអង្កេតចាប់ផ្តើមប៉ុណ្ណោះ (តារាងទី៦)។ នេះគឺជាការអនុវត្តន៏ដ៏ល្អមួយ ដែលរំលឹកដល់កុមារអំពីសុវត្ថិភាពការងារក្នុងពេលបច្ចុប្បន្ន និងបន្តទៅមុខទៀត ប្រសិនបើការរាយការណ៏របស់ពួកគេអាចទុកចិត្តបាន។ ក៏ប៉ុន្តែ បើយោងទៅតាមបញ្ហារសើបនៃពលកម្មកុមារ ហើយម្ចាស់សិប្បកម្ម និងមេការត្រូវបានទទួលព័ត៌មានជាមុន អំពីការអង្កេតនេះ លទ្ធផលនេះបានបង្ហាញថា ម្ចាស់សិប្បកម្ម ឬមេការមួយចំនួនប្រហែលជាគ្រាន់តែរំលឹកដល់ ពលករកុមាររបស់ពួកគេ អំពីសុវត្ថិភាព ការងារដោយសារតែមានការអង្កេតនេះតែប៉ុណ្ណោះ។

## តារាងទី៦ ៖ការទទួលបានព័ត៌មានអំពីសុវត្ថិភាពការងារ

| | នៅភូមិ | នៅឡូឥដ្ឋ | សរុប |
|---|---|---|---|
| **ធ្លាប់បានគេប្រាប់ពីសុវត្ថិភាពការងារដែរឬទេ?** | | | |
| មិនធ្លាប់ | ៤៣.៨% | ៦១.១% | ៤៨.៥% |
| ធ្លាប់ | ៥៦.៣% | ៣៨.៩% | ៥១.៥% |
| **សរុប** | **៩៦** | **៣៦** | **១៣២** |
| **តើញឹកញាប់ប៉ុណ្ណា?** | | | |
| ១-៣ដង | ៧២.០% | ៣៥.៧% | ៦៤.១% |
| លើសពី៣ដង | ២៨.០% | ៦៤.៣% | ៣៥.៩% |
| **សរុប** | **៥០** | **១៤** | **៦៤** |
| **នរណាជាអ្នកប្រាប់?** | | | |
| ថៅកែ ឬមេការ | ៤០.៤% | ២៨.៦% | ៣៧.៩% |
| អ្នកធ្វើការជាមួយគ្នា | ១៥.៤% | ៧.១% | ១៣.៦% |
| គ្រួសារ ឬបងប្អូន | ២៨.៨% | ៥៧.១% | ៣៤.៨% |
| អង្គការ | ២១.២% | ៧.១% | ១៨.២% |
| **សរុប** | **៥២** | **១៤** | **៦៦** |
| **លើកចុងក្រោយដែលគេប្រាប់** | | | |
| ព្រឹកមិញ | ២៣.៤% | ១៤.៣% | ២១.៣% |
| ម្សិលមិញ | ៨.៥% | ២៨.៦% | ១៣.១% |
| ២-៣ថ្ងៃមុន | ១២.៨% | ២១.៤% | ១៤.៨% |
| ១អាទិត្យមុន | ១៧.០% | ១៤.៣% | ១៦.៤% |
| ១ខែមុន | ២១.៣% | ៧.១% | ១៨.០% |
| ជាងមួយខែហើយ | ១៧.០% | ១៤.៣% | ១៦.៤% |
| **សរុប** | **៤៧** | **១៤** | **៦១** |

# ៩. ផលប៉ះពាល់នៃពលកម្មកុមារ

ផលប៉ះពាល់នៃពលកម្មកុមារនៅឡូឥដ្ឋទៅលើការអភិវឌ្ឍន៏កុមារ គឺជាគោលបំណងចំបងមួយនៅក្នុងការសិក្សានេះ។ ផលប៉ះពាល់ជាអវិជ្ជមានរបស់ពលករកុមារទៅលើសុខភាព និងការសិក្សារបស់ពួកគេអាចធ្វើអោយអន្តរាយ ដល់ការអភិវឌ្ឍន៏របស់កុមារ ពីព្រោះតែឥទ្ធិពលដ៏យូរអង្វែងរបស់វា ហើយឥទ្ធិពលដែលមានរយៈពេលវែងនេះ គឺពិបាកនឹងចាប់បានណាស់។ ជាងនេះទៅទៀត ចំណងទាក់ទងរវាងពលករកុមារ និងការអភិវឌ្ឍន៏គឺស្មុគស្មាញ ពីព្រោះទំនាក់ទំនងនេះមានទ្រង់ទ្រាយច្រើន, ប្រែប្រួល, អាចជាវិជ្ជមាន ឬអវិជ្ជមាន, ឬអាចជាចំណងទាក់ទងមានហេតុផល ឬគ្មាន។ និយាយម្យ៉ាងទៀត ផលប៉ះពាល់នៃពលកម្មកុមារទៅលើការអភិវឌ្ឍន៏កុមារ មិន

មែនមានតែមួយ តែមានច្រើន ដែលវាប្រែប្រួលទៅតាមលក្ខណៈធម្មជាតិនៃការងារដែលកុមារ ធ្វើទៅតាមរយៈពេលនៃការធ្វើការងារ ដែលចង្អុលបង្ហាញពីរយៈពេលនៃការប្រឈម និងទៅតាមស្ថានភាពរស់នៅរបស់គ្រួសារកុមារ ។

ដូច្នេះ រយៈពេលដែលកុមារបានធ្វើការងារបច្ចុប្បន្នរបស់គេត្រូវបានយកមកប្រើ ដើម្បីប្រៀបធៀបពីផលប៉ះពាល់នៃការចូលប្រឡូកក្នុងពលកម្មកុមារទៅលើការរៀនសូត្រ, ការថែទាំសុខភាព និងអាកប្បកិរិយាផ្សេងទៀត ទាក់ទិននឹងការអភិវឌ្ឍន៍របស់កុមារ ។ ពលករកុមារទាំងអស់ត្រូវបានបែងចែកជា ក្រុមអ្នកដែលបានធ្វើការតិចជាង២ឆ្នាំ និងអ្នកដែលបានធ្វើការយ៉ាងតិច២ឆ្នាំនៅសិប្បកម្មឡឥដ្ឋ ។ ការកំណត់យករយៈពេល២ឆ្នាំជាចំណុចចែកនេះ មានលក្ខណៈចៃដន្យសុទ្ធសាធ ក៏ប៉ុន្តែវាអាចចាប់បាននូវរាល់តទ្ធិពលរបស់ពលកកម្មកុមារ ដែលមិនងាយកើតមានភ្លាមៗ ។

## ៩.១ ផលប៉ះពាល់របស់ពលកម្មកុមារទៅលើការអប់រំ

ផលប៉ះពាល់នៃការធ្វើការងារនៅសិប្បកម្មឡឥដ្ឋទៅលើការចូលរៀន អាចត្រូវបានវាយតំលៃដោយប្រៀបធៀបបញ្ហានានាទាក់ទងនឹងការសិក្សាទៅតាមរយៈពេលនៃការធ្វើការ ដោយសន្មតថា បើកុមារធ្វើការកាន់តែយូរនៅឡឥដ្ឋ កុមារនោះនឹងមានទំនោរបោះបង់ការសិក្សា ឬមានបញ្ហានៅសាលាកាន់តែខ្លាំង ។ សំរាប់កុមារដែលបានបោះបង់ការសិក្សា ពេលវេលានៃការបោះបង់ការសិក្សា និងពេលវេលាដែលពួកគេចាប់ផ្តើមធ្វើការត្រូវបានប្រើ សំរាប់សំគាល់ពលករកុមារ ដែលបោះបង់ការសិក្សាបន្ទាប់ពីពួកគេចាប់ផ្តើមធ្វើការ ។ ក្នុងចំណោមកុមារ៩១នាក់ មាន៧នាក់ មិនមានព័ត៌មានអំពី ពេលវេលាដែលពួកគេបោះបង់ការសិក្សាឡើយ ហើយត្រូវបានដកចេញពីការវិភាគ ។ សំរាប់កុមារដែលកំពុងតែសិក្សានៅឡើយ (ចំនួន៣៣នាក់) សំនួរជាច្រើនអំពីអាកប្បកិរិយាទាក់ទង នឹងការរៀនសូត្រត្រូវបានសួរ ។ លទ្ធផលត្រូវ បានបង្ហាញនៅតារាងទី៧ ។

ភាគរយនៃការបោះបង់ការសិក្សាជាក់ស្តែង គឺខ្ពស់ក្នុងចំណោមកុមារដែលធ្វើការរយៈពេលយូរជាងក្នុងចំណោម អ្នកដែលធ្វើការរយៈពេលខ្លីជាង (៣៧.៨% និង ៧.៧%រៀងគ្នា) ។ ជាងនេះទៅទៀត កុមារធ្វើការទាំងអស់សុទ្ធ តែមានបញ្ហាទាក់ទងនឹងការរៀនសូត្រ ប៉ុន្តែកុមារដែលធ្វើការយ៉ាងតិច២ឆ្នាំហាក់ដូចជាមានបញ្ហានៅសាលាច្រើន ជាងកុមារដែលធ្វើការរយៈតិចជាង២ឆ្នាំ ។ ឧទាហរណ៍ ៥២.៦%នៃកុមារដែលកំពុងធ្វើការរយៈពេលយ៉ាងតិច២ឆ្នាំនិយាយថា ការសិក្សារបស់ពួកគេចុះខ្សោយជាងមុន បើប្រៀបធៀបជាមួយនឹង ២២.៤% នៃកុមារដែលបានធ្វើការរយៈពេលតិចជាង២ឆ្នាំ ។ ភាគរយនៃការទៅសាលាយឺត និងការមិនចូលថ្នាក់ក៏ខ្ពស់ផងដែរ ក្នុងចំណោមពលករកុមារដែលធ្វើការយូរមកហើយ (៤៧.៤% និង៤២.១%រៀងគ្នា) ជាងក្នុងចំណោមពលករកុមារដែលទើបនឹងធ្វើការថ្មីៗ (២៨.៦% និង៧.១% រៀងគ្នា) ។

ឪពុកម្តាយដែលបានសម្ភាសន៍ ក៏បានរាយការណ៍ផងដែរថាឥរិយាបថ និងអាកប្បកិរិយារបស់កូនៗ ពួកគេចំពោះសាលារៀនបាន ផ្លាស់ប្តូរបន្ទាប់ពីពួកគេចាប់ផ្តើមធ្វើការនៅសិប្បកម្មឡឥដ្ឋ ។ ឧទាហរណ៍ប្រហែលជា

មួយភាគបីនៃកូនគាត់ត្រូវបានរាយការណ៍ថា (២០នាក់ក្នុងចំណោម៥៥នាក់នៃក្មេងដែល បានរាយការណ៍) បានវិវត្តន៍ទៅរកឥរិយាបថអវិជ្ជមានចំពោះការសិក្សារបស់ពួកគេ (មិនចូលចិត្តទៅសាលារៀន) វត្តមាននៅសាលារៀនធ្លាក់ចុះ (មិនចូលសាលាកាន់តែញឹកញាប់) និងទទួលបានចំណាត់ថ្នាក់ខ្សោយជាងមុន។

**តារាងទី៧ :ឥទ្ធិពលការងារទៅលើការសិក្សា**

| | នៅភូមិ | នៅឡូតជ្ជ | សរុប |
|---|---|---|---|
| **ចំពោះពលករកុមារដែលឈប់រៀន** | | | - |
| ចំនួនអ្នកដែលឈប់រៀប (មិនរាប់អ្នកមិនបានឆ្លើយពីពេលឈប់រៀន) | ៣៩ | ៤៥ | ៨៤ |
| ចំនួនអ្នកឈប់រៀនក្រោយបានចូលធ្វើការនៅឡូតជ្ជ | ៣ | ១៧ | ២០ |
| ភាគរយអ្នកឈប់រៀនក្រោយបានចូលធ្វើការនៅឡូតជ្ជ | ៧.៧% | ៣៧.៨% | ២៣.៨% |
| **ចំពោះពលករកុមារដែលកំពុងរៀន** | | | |
| ចាប់តាំងពីធ្វើការមក: | | | |
| ការរៀនសូត្ររបស់ខ្ញុំចុះខ្សោយជាងមុន | ២១.៤% | ៥២.៦% | ៣៩.៤% |
| ខ្ញុំទៅរៀនមិនទាន់ម៉ោង ញឹកញាប់ជាងមុន | ២៨.៦% | ៤៧.៤% | ៣៩.៤% |
| ខ្ញុំអត់ទៅរៀន ញឹកញាប់ជាងមុន | ៧.១% | ៤២.១% | ២៧.៣% |
| ទំនាក់ទំនងជាមួយមិត្តភក្តិ មិនសូវល្អដូចមុន | ២១.៤% | ៣១.៦% | ២៧.៣% |
| ខ្ញុំធ្វើខុសវិន័យសាលាញឹកញាប់ជាងមុន | ៦៤.៣% | ៧៣.៧% | ៦៩.៧% |
| ចំនួនកុមារ | ១៤ | ១៩ | ៣៣ |

## *៩.២ ផលប៉ះពាល់នៃពលកម្មកុមារទៅលើសុខភាព*

### *៩.២.១ ការស្ទង់ពីបញ្ហាសុខភាពដោយខ្លួនឯង*

ពលករកុមារត្រូវបានសួរអោយប៉ាន់ប្រមាណនូវស្ថានភាពសុខភាពរបស់ខ្លួន ដោយចម្លើយពិត រឺមិនពិត ចំពោះសំណួរចំនួន៩ (សំណួរទី៣៩-១ ដល់៣៩-៩, ក្នុងឧបសម្ព័ន្ធទី១)។ សំណួរទាំងនេះត្រូវបានបញ្ចូលគ្នា ដើម្បីបង្កើតនូវ សន្ទស្សន៍សុខភាពជាទូទៅមួយ ដោយការបែងចែកអ្នកតបសម្ភាសន៍ជា អ្នកដែលមិនមានបញ្ហាសុខភាព ប្រសិនបើ កុមាររាយការណ៍ថាមានបញ្ហាសុខភាពតិចជាង៣បញ្ហា, អ្នកមានបញ្ហាសុខភាពកំរិតមធ្យម ប្រសិនបើកុមារ រាយការណ៍ថាមានបញ្ហាសុខភាពពី៣ ទៅ ៥បញ្ហា, និងមានបញ្ហាសុខភាពធ្ងន់ធ្ងរ ប្រសិនបើកុមាររាយការណ៍ថា មានបញ្ហាសុខភាពពី៦ ទៅ ៩បញ្ហា។

លទ្ធផលនៅក្នុងក្រាហ្វិកទី១៣ បង្ហាញថា ប្រហែលជា៤ភាគ៥នៃពលករកុមារដែលរស់នៅ តាមសិប្បកម្មឡូតជ្ជ បានសន្មតស្ថានភាពសុខភាពរបស់ខ្លួនថាមានបញ្ហាកំរិតមធ្យម និងកំរិតធ្ងន់ធ្ងរ ដោយយោងទៅលើសន្ទស្សន៍សុខភាពជាទូទៅខាងលើនេះ។ ភាពខុសគ្នាតិចតួចត្រូវបានរកឃើញរវាងកុមារដែលធ្វើការតិចជាង២ឆ្នាំ និងអ្នកដែលធ្វើការយ៉ាងតិច២ឆ្នាំ លើកលែងតែបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលសមាមាត្រនៃពលករកុមារដែលទើបនឹងធ្វើការ

ថ្មី គឺខ្ពស់ជាងពលករកុមារដែលធ្វើការយូរមកហើយ (៤០% និង៣៣.៣% រៀងគ្នា)។ ការខុសគ្នានេះអាច អាស្រ័យដោយសារតែទំហំតូចនៃសំណាក ដែលធ្វើអោយលទ្ធផលប្រែប្រួលច្រើនខ្លះ ឬក៏ដោយសារតែពលករកុមារ ថ្មីៗទទួលរងនូវការផ្លាស់ប្តូរសុខភាពរហ័សពេក បន្ទាប់ពីចាប់ធ្វើការមក។

ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានៃការវាយតំលៃស្ថានភាពសុខភាពផ្ទាល់ខ្លួន ទៅតាមរយៈពេលធ្វើ ការងារ មានភាពលេចធ្លោជាងនៅក្នុងចំណោមកុមារដែលមកពីតាមភូមិជិតកន្លែងសិប្បកម្ម ដោយរយៈពេលយូរ មានទាក់ទងនឹងបញ្ហាសុខភាពកំរិតមធ្យម ឬកំរិតធ្ងន់ធ្ងរច្រើនជាងរយៈពេលធ្វើការខ្លី។ ឧទាហរណ៍ ៩១.៥%នៃ កុមារដែលបានធ្វើការរយៈពេលយូររាយការណ៍ថាធ្លាប់មានបញ្ហាផ្នែកសុខភាព (៣៦.២%មានបញ្ហា សុខភាពកំរិត មធ្យម ហើយ៥៥.៣%មានបញ្ហាសុខភាពកំរិតធ្ងន់ធ្ងរ) បើប្រៀបធៀបទៅនឹង ៧៤.៥%នៃកុមារដែល ទើបធ្វើការ បានរយៈពេលខ្លីជាង (២៧.៧%មានបញ្ហាសុខភាពកំរិតមធ្យម ហើយ៤៦.៨%មានបញ្ហាសុខភាពកំរិតធ្ងន់ធ្ងរ)។ ក្រាហ្វិកទាំងនេះ មិនគ្រាន់តែបង្ហាញពីបញ្ហាសុខភាពគួរអោយភ្ញាក់ផ្អើលរបស់ពលករកុមារនៅតាមឡឥដ្ឋប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញពីស្ថានភាពសុខភាពដ៏យ៉ាប់យឺនរបស់កុមារដែលធ្វើការបាន២ឆ្នាំ ឬលើសពីនេះ។

**ក្រាហ្វិកទី១៣ : របាយភាគរយកុមារទៅតាមការវាយតម្លៃដោយខ្លួនឯង**




### *៩.២.២ ការកើតមានជំងឺញឹកញាប់ដោយសារតែការងារ*

បន្ថែមលើការវាយតំលៃពីសុខភាពជាទូទៅ បទពិសោធន៍អំពីបញ្ហាសុខភាពជាក់លាក់ តាមរយៈការ ឈឺថ្កាត់ ឬការរងរបួសដោយសារការងារ ក៏បានសាកសួរពីពលករកុមារទាំងអស់។ បញ្ជីឈ្មោះជំងឺត្រូវបានផ្តល់

អោយអ្នកឆ្លើយសម្ភាសន៍ ដែលត្រូវឆ្លើយថា តើមានជំងឺអ្វីខ្លះដែលធ្លាប់កើតមានលើពួកគេដោយសារការងារហើយញឹកញាប់ប៉ុណ្ណា (មិនធ្លាប់, កំរ, ម្តងម្កាល, ឬញឹកញាប់)។ ក្រាហ្វិកទី១៤ បង្ហាញពីលទ្ធផលនៃជំងឺដែលពលករកុមារធ្លាប់មានញឹកញាប់ ចំពោះកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ និងកុមារដែលមិនរស់ នៅក្នុងសិប្បកម្មឡឥដ្ឋដោយឡែកពីគ្នា។

**ក្រាហ្វិកទី១៤ : ឧប្បត្តិហេតុនៃជំងឺដែលកើតមានជាញឹកញាប់**




ពលករកុមារ ទាំងអ្នករស់នៅក្នុងនិងមិននៅក្នុងសិប្បកម្មឡឥដ្ឋ ទំនងទទួលរងផលប៉ះពាល់សុខភាពដោយសារលក្ខខណ្ឌការងារ និងទីកន្លែងធ្វើការងាររបស់ពួកគេ។ បញ្ហាសុខភាពជាទូទៅ គឺជំងឺហៀរទឹកភ្នែកឬរមាស់ភ្នែក ដែលកើតឡើងដោយសារផ្សែង និងកំទេចផេះហុយ (៨៣%ជាពលករកុមាររស់នៅក្នុងភូមិ និង ៧៥.៨%ជាពលករកុមាររស់នៅតាមសិប្បកម្ម)។ បញ្ហាសុខភាពដទៃទៀត ដែលកើតឡើងញឹកញាប់ ដល់កុមារ

ដែលមិនរស់នៅក្នុង សិប្បកម្មរួមមាន ៤០.៤% ឈឺខ្នង, ៤០.៤%កន្ទួលលើស្បែក, ៣៧.២%រមាស់ស្បែក, ៣៦.២%ឈឺខ្លួន និងឈឺ សាច់ដុំ, ៣១.៩%ឈឺទ្រូង និង ជំងឺបន្ទាប់បន្សំខ្លះទៀត។

ពលករកុមារ ដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋក៏ធ្លាប់ឈឺជំងឺទាំងនេះញឹកញាប់ដែរ ប៉ុន្តែសមាមាត្រនៃអ្នកធ្លាប់មានបញ្ហានិមួយៗខុសគ្នាខ្លះៗពីពលករកុមារដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ។ ឧទាហរណ៍ ពលករកុមារដែលរស់នៅតាមសិប្បកម្មឡឥដ្ឋ មិនសូវធ្លាប់ឈឺខ្នង (១៨.២% និង៤.០៤%), ឈឺទ្រូង (១៥.២% និង៣១.៩%), ឈឺក្បាល (២១.១% និង៣៣.០%), រមាស់ស្បែក (២៤.២% និង៣៧.២%), ពិបាកដកដង្ហើម (១៨.២% និង២៥.៥%) និងឈឺក្រពះ (៩.១% និង១៦.០%) ដូចកុមារមកពីភូមិ។ ការពន្យល់ដ៏ទំនងមួយ គឺថា ប្រហែលជាក្មេងរស់នៅតាមសិប្បកម្មទាំងនេះអាចសំរបខ្លួននឹងបរិស្ថានការងារក្នុងសិប្បកម្មឡឥដ្ឋបានល្អជាងកុមារដែលរស់នៅតាមភូមិដោយសារតែពួកគេរស់នៅ និងធ្វើការក្នុងមជ្ឈដ្ឋានតែមួយ។

## *៩.២.៣ ការកើតមានគ្រោះថ្នាក់ និងរបួសញឹកញាប់*

ពលករកុមារទាំងអស់ត្រូវបានសួរថា តើពួកគេធ្លាប់ទទួលរងគ្រោះថ្នាក់ ឬរបួសអ្វីដែររឺទេ ហើយបើធ្លាប់តើញឹកញាប់ក៏រិតណា។ ខាងក្រោមនេះគឺជាលទ្ធផលដែលបង្ហាញពីឧប្បត្តិហេតុនៃគ្រោះថ្នាក់ និងរបួសទៅតាមចំនួនពលករ កុមារដែលបានផ្តល់ចម្លើយថាធ្លាប់បានទទួលរងរបួសញឹកញាប់ (ក្រាហ្វិកទី១៥)។

ជាក់ស្តែងការមុតតិចតួចគឺជាប្រភេទរបួសទូទៅជាងគេមួយ ដែលកើតឡើងញឹកញាប់ ទៅលើពលករកុមារ ដែលបានសម្ភាសន៍ចំនួនជិតពាក់កណ្តាល ដោយមិនអាស្រ័យពីកន្លែងរស់នៅ និងរយៈពេលធ្វើការ។ មូលហេតុរួមនៃគ្រោះថ្នាក់នេះគឺបណ្តាលមកពីការធ្លាក់ឥដ្ឋលើ (៤៥%បាន រាយការណ៍ថាបានទទួល គ្រោះថ្នាក់ធ្ងន់ធ្ងរ) ហើយមុតដោយសារការរើដញ្ជូនឥដ្ឋ (២៧.៥%រាយការណ៍ថាបាន ទទួលគ្រោះថ្នាក់ធ្ងន់ធ្ងរ) និងនៅពេលដែលជំពប់ជើង ពីព្រោះតែមិនបានពាក់ស្បែកជើងសំរាប់ធ្វើការបានត្រឹមត្រូវ (១៧.៥%)។

ប្រភេទរបួសទូទៅមួយទៀតគឺ ការរលាកស្រាល ដែលកើតឡើងជាញឹកញាប់ចំពោះ២៤.៥%នៃពលករកុមារ ដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ ហើយ១៥.២%នៃពលករកុមារដែលរស់នៅក្នុងសិប្បកម្ម។ មូលហេតុចំបងដែលនាំអោយមានគ្រោះថ្នាក់នេះគឺដោយសារកុមាររើឥដ្ឋពីឡនៅពេលដែលឥដ្ឋនៅក្តៅនៅឡើយ។ ការមុតធ្ងន់ធ្ងរ និងរលាកធ្ងន់ធ្ងរក៏បានកើតឡើងញឹកញាប់ចំពោះពលករកុមារ ១០-១៥%ផងដែរ។

គួរអោយកត់សំគាល់ផងដែរថា ភាគរយនៃកុមារដែលធ្លាប់ទទួលរងរបួសធ្ងន់ធ្ងរ ជាក់ស្តែងមានចំនួនទាបជាងការពិត ដោយសារតែការសួរតែទៅលើរបួសដែលកើតឡើងញឹកញាប់ ពីព្រោះរបួសធ្ងន់ធ្ងរកំរនឹងកើតឡើងញឹកញាប់ដូចជារបួសស្រាលណាស់។ យ៉ាងណាក៏ដោយ គំហើញបង្ហាញថាទាំងរបួសស្រាល និងធ្ងន់សុទ្ធមានកើតឡើងចំពោះអ្នកធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ។

## ក្រាហ្វិកទី១៥ : ឧប្បត្តិហេតុនៃការរងរបួសដែលកើតមានជាញឹកញាប់




ខាងក្រោមនេះនឹងបង្ហាញពីការសិក្សាមួយករណីទៅលើសិប្បកម្មឡឥដ្ឋមួយអាស្រ័យដោយការអង្កេត និងការ ពិភាក្សាមិនផ្លូវការមួយជាមួយនឹងមនុស្សពេញវ័យចំនួន៤-៥នាក់។ ករណីសិក្សានេះបង្ហាញពីកុមារដែលរស់នៅ និងធ្វើការនៅក្នុងសិប្បកម្ម ត្រូវរងគ្រោះដោយសារតែលក្ខខណ្ឌអសុវត្ថិភាពក្នុងការរស់នៅ និងធ្វើការងារ, អំពីការ ដែលពួកគេត្រូវទាញអោយចូលទៅក្នុងពលកម្មកុមារ, ហើយនិងបង្ហាញពីការមិនយកចិត្តទុកដាក់របស់ម្ចាស់ សិប្បកម្ម និងមេការទៅលើពួកគេ។

| |
|---|
| សិប្បកម្មមួយនោះមានឡចំនួន១០ និងម៉ាស៊ីនធ្វើឥដ្ឋចំនួន៥។ មានគ្រួសារកម្មករចំនួន១៤គ្រួសារ ដោយក្នុងនោះមានកុមារតូចៗចំនួន២០-២៥នាក់កំពុងរស់នៅលាយឡំគ្នាក្នុងបរិវេណសិប្បកម្មនោះ។ ក្រុមគ្រួសារទាំងនេះបានផ្លាស់ទីមកពីខេត្តតាកែវ, កំពត, ឬកំពង់ស្ពឺ។ ការងារជាទូទៅសំរាប់គ្រួសារទាំងនេះ គឺការដុតភ្លើងឡ, រៀបចំដីឥដ្ឋ, និង កាន់ម៉ាស៊ីនធ្វើឥដ្ឋ។ គ្រួសារមួយបានរស់នៅ និងធ្វើការនៅក្នុងសិប្បកម្មបានបីជំនាន់មកហើយ ដោយធ្វើជាអ្នកដុត និងមើលភ្លើងឡ។ កុមារខ្លះរស់នៅក្នុងគ្រួសារដែលបែកបាក់ដោយសារតែឪពុកម្តាយរបស់គេលែងលះ ឬរស់នៅបែកគ្នា ហើយមានក្មេងខ្លះទៀតត្រូវរស់នៅជាមួយជីដូនជីតារបស់ខ្លួន។ |
| កុមារត្រូវរស់នៅក្នុងភាពទុគ៌ត។ កុមារទាំងអស់ បន្ទាប់ពីមានអាយុ៨ឆ្នាំហើយគឺអាចមានលទ្ធភាពជួយដល់ឪពុកម្តាយរបស់ពួកគេ ឬមនុស្សពេញវ័យផ្សេងទៀតក្នុងការរៀបឥដ្ឋ, រុញរទេះដឹកឥដ្ឋ, និងលើកឥដ្ឋ |

ដាក់លើឡាន។ ពួកគេធ្វើការដោយមិនមានប្រាក់ឈ្នួលឡើយ ប៉ុន្តែជានិច្ចកាលពួកគេទទួលបាន២០០ ទៅ ៣០០រៀលសំរាប់ការងារជារៀងរាល់ថ្ងៃរបស់ពួកគេ។

ការគ្រោះថ្នាក់២ករណី ដែលទាក់ទងនឹងម៉ាស៊ីនធ្វើឥដ្ឋបានកើតឡើងនៅក្នុងរោងចក្រនេះប្រហែល៩ ទៅ ១២ ខែមុនការអង្កេត។ ប្រហែលជា១២ខែមុន ក្មេងម្នាក់ត្រូវម៉ាស៊ីនធ្វើឥដ្ឋទាញដៃចូលទៅក្នុងម៉ាស៊ីន។ បន្ទាប់ពីសំរាកក្នុងមន្ទីរពេទ្យរយៈពេល៣ខែ ដោយសារមានការឧបត្ថម្ភពីសំណាក់អង្គការក្រៅរដ្ឋាភិបាលមក ជីវិតរបស់កុមារត្រូវបានសង្គ្រោះ ហើយដៃរបស់វាក៏អាចរក្សាបានដែរ។ ក្មេងម្នាក់ទៀតក៏ត្រូវបានម៉ាស៊ីន ទាញដៃដែរបន្ទាប់ពី៣ខែនៃឧប្បត្តិហេតុលើកទីមួយមក។ គ្រោះថ្នាក់លើកក្រោយមានលក្ខណៈស្រាលជាង គ្រោះថ្នាក់លើកដំបូង ដោយដៃរបស់ក្មេងគ្រាន់តែត្រូវម៉ាស៊ីនគៀប ហើយត្រូវដេរប៉ុន្មានថ្នេរប៉ុណ្ណោះ។ កុមារដែលរស់នៅក្នុងសិប្បកម្មនេះគឺមានបញ្ហាសុខភាពច្រើន។ កុមារជាច្រើនស្គម ខ្លះស្លេកស្លាំង គ្មាន កំលាំងកំហែង ហើយខ្វះអាហាររូបត្ថម្ភ។ ពួកគេឈឺជាញឹកញាប់។ កុមារខ្លះរងគ្រោះដោយឈឺទ្រូងរ៉ាំរ៉ៃ និងឈឺក្បាលពីព្រោះតែពួកគេចាប់ផ្តើមធ្វើការនៅអាយុក្មេងពេក។

កុមារទាំងនេះខ្វះខាតនូវការអប់រំជាមូលដ្ឋាន។ កុមារ២នាក់មិនធ្លាប់បានចូលរៀន ក្នុងខណៈពេលដែល កុមារដទៃទៀតជាច្រើនបោះបង់ការសិក្សានៅត្រឹមថ្នាក់ទី៤ ឬទី៥។ ពួកគេបោះបង់ការសិក្សាដើម្បីជួយដល់ ការងារឪពុកម្តាយរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ កុមារដែលកំពុងនៅរៀន ក៏មិនបានចូលរៀន ទៀងទាត់ទេ ព្រោះជួនកាលឪពុកម្តាយរបស់ពួកគេ ត្រូវការកំលាំងពួកគេភ្លាមៗដើម្បីបញ្ចប់កុងត្រា។

## ១០. ការអនុវត្តន៍ដ៏ល្អបំផុតដើម្បីកាត់បន្ថយគ្រោះថ្នាក់ការងារ

ការអនុវត្តន៍ដ៏ល្អបំផុតសំរាប់សុខភាពគឺ ការពាក់នូវបរិក្ខារការពារសុវត្ថិភាពពេលប្រតិបត្តិការងារ វាអាច ជួយកាត់បន្ថយនូវការប៉ះពាល់របស់ការងារដែលមានគ្រោះថ្នាក់ទៅលើសុខភាព និងការលូតលាស់។ ទោះជាយ៉ាង ណាក៏ដោយ ពលករកុមារនៅឡឥដ្ឋដ៏ច្រើនលើសលុបមិនបានប្រើប្រាស់បរិក្ខារការពារណាមួយពេលកំពុងធ្វើការ ទេ។ ក្រាហ្វិកទី១៦ បានបង្ហាញពីសមាមាត្រនៃកុមារដែលមិនធ្លាប់ពាក់បរិក្ខារការពារទាល់តែសោះនៅក្នុងពេល បំពេញការងារ។

គួរអោយកត់សំគាល់ដែរថា ពលករកុមារទាំងអស់មិនដែល ពាក់វ៉ែនតា និង ពាក់មួកឡើយ។ កុមារតិចណាស់ ដែលបានរាយការណ៍ថាបានពាក់ស្បែកជើងសំរាប់ធ្វើការ (១២.១%នៃកុមារដែលរស់ នៅតាម សិប្បកម្ម និង ២៧.៧%នៃកុមារដែលមិនរស់នៅតាមសិប្បកម្ម)។ ទោះជាយ៉ាងណាក៏ដោយ ការពាក់មួក ការពារកំដៅថ្ងៃ, ពាក់របាំងមុខ ឬក្រមា, និងការពាក់ស្រោមដៃអាចអនុវត្តន៍បានច្រើនក្នុងចំណោមក្រុមកុមារខ្លះ ដោយ ក្មេងដែលរស់នៅតាមភូមិមានសមាមាត្រខ្ពស់ជាងក្មេងដែលរស់នៅតាមសិប្បកម្ម ទោះជាសមាមាត្រនេះ មានកំរិតទាបក៏ដោយ (ក្រាហ្វិកទី១៦)។

មូលហេតុចំបង ដែលពលករកុមារមិនបានពាក់គ្រឿងការពារទាំងនេះ គឺដោយសារតែពួកគេគ្មានវា ហើយមិនមានលទ្ធភាពដើម្បីទិញវាបាន។ ចំនុចសំខាន់ដែលគួរកត់សំគាល់ គឺពលករកុមារខ្លះបានរាយការណ៍ថា ពួកគេបាន ទទួលស្បែកជើងសំរាប់ធ្វើការ, ស្រោមដៃសំរាប់ធ្វើការ, និងរបាំងមុខពី អង្គការទស្សនៈ ពិភពលោក កម្ពុជា។

## ១១. ការយល់ដឹងអំពីសេចក្តីប្រកាសអំពីពលកម្មកុមារ

ដូចដែលបានរៀបរាប់រួចមកហើយ មិនមែនគ្រប់សិប្បកម្មឡឥដ្ឋបានផ្តល់ការណែនាំអំពីសុវត្ថិភាពការងារ ដល់កុមារ មុននឹងអោយពួកគេចាប់ផ្តើមការងារឡើយ (ក្នុងចំណោមម្ចាស់សិប្បកម្ម ឬមេការ ១៥នាក់ មាន ត្រឹមតែ ១១នាក់ប៉ុណ្ណោះដែលរាយការណ៍ថាបានផ្តល់នូវការណែនាំនេះដល់កុមារ) ហើយក៏មិនមែនគ្រប់សិប្បកម្ម បានហាមឃាត់កុមារមិនអោយធ្វើជាអ្នកបញ្ជាម៉ាស៊ីនធ្វើឥដ្ឋឡើយ (ក្នុងចំណោមម្ចាស់សិប្បកម្ម ឬមេការទាំង ១៥នាក់ មានតែ១០នាក់ប៉ុណ្ណោះ ដែលអះអាងថាបានហាមឃាត់កុមារមិនអោយកាន់ម៉ាស៊ីនធ្វើឥដ្ឋនៅក្នុង សិប្បកម្ម)។ ជាងនេះទៅទៀត ម្ចាស់សិប្បកម្ម ឬមេការជាច្រើន (៩នាក់ក្នុងចំណោម ១៥នាក់ដែលបានសម្ភាសន៍) មិនបានដឹងអំពី សេចក្តីប្រកាសអំពីពលកម្មកុមារនៅក្នុងប្រទេសកម្ពុជាឡើយ។ សិប្បកម្មទាំងអស់នេះ ខ្លះមាន ទីតាំងនៅឃុំអន្លង់វិល ស្រុកសង្កែ ហើយខ្លះទៀតមានទីតាំងនៅឃុំឳម៉ាល់ ស្រុកបាត់ដំបង។

**ក្រាហ្វិកទី១៦ : ភាគរយនៃពលករកុមារដែលមិនពាក់អ្វីការពារពេលធ្វើការ**



ដូច្នេះ ការសិក្សាបានបញ្ជាក់យ៉ាងច្បាស់ថា មានគំលាតគ្នាយ៉ាងសំបើមរវាងការអនុវត្តន៏របស់ម្ចាស់ ឬមេការសិប្បកម្មដើម្បីធានាអោយមានបរិយាកាសការងារដែលមានសុវត្ថិភាពសំរាប់កុមារ ក៏ដូចជាច្បាប់ និងបទបញ្ជាក្នុងការលុបបំបាត់គ្រោះថ្នាក់ដែលអាចបង្កដល់ពលករកុមារនៅតាមឡឥដ្ឋ។

## ១២. ការរំពឹងទុកចំពោះអនាគតនៃពលករកុមារ

ក្រាហ្វិកទី១៧នឹងបង្ហាញអំពីអ្វីដែលពលករកុមារ និងឪពុកម្តាយរបស់ពួកគេរំពឹងទុកចំពោះអនាគតរបស់ពលករកុមារ។ គួរអោយចាប់អារម្មណ៏ថា ភាគច្រើននៃពលករកុមារមិនចង់បន្តការសិក្សារបស់ពួកគេឡើយ ដែលផ្ទុយនឹងការរំពឹងទុករបស់ឪពុកម្តាយកុមារដែលរស់នៅតាមសិប្បកម្ម។ នេះក៏ប្រហែលមកពីពលករកុមារទាំងនោះបានឈប់រៀនរួចទៅហើយ។ កុមារជាច្រើនចង់ស្វែងរកការងារធ្វើនៅកន្លែងផ្សេង ក្នុងខណៈដែលមានកុមារមួយចំនួនតូចនៅតែមានបំណងចង់បន្តធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ។ ការរកឃើញនេះគឺស្រដៀងគ្នាទៅនឹងចម្លើយដែលផ្តល់ដោយឪពុកម្តាយរបស់កុមារដែលមិនរស់នៅតាមសិប្បកម្ម។

**ក្រាហ្វិកទី១៧ : ការរំពឹងទុកទៅថ្ងៃអនាគតរបស់ពលករកុមារ**




## ១៣. សំណើដើម្បីកែលម្អស្ថានភាពការងាររបស់កុមារនៅសិប្បកម្មឡឥដ្ឋ

សំណើដើម្បីធ្វើអោយកាន់តែប្រសើរនូវស្ថានភាពការងាររបស់ពលករកុមារនៅតាមសិប្បកម្មឡឥដ្ឋ គឺជាសំណើរបស់ពលករកុមារ និងឪពុកម្តាយរបស់ពួកគេ (ក្រាហ្វិកទី១៨)។ គួរអោយចាប់អារម្មណ៏ថា អ្នកតបសម្ភាសន៏ភាគច្រើន ទាំងពលករកុមារ និងទាំងឪពុកម្តាយ មិនមានគំនិតថាត្រូវធ្វើដូចម្តេចដើម្បីធ្វើអោយស្ថានភាព

ការងារ បានកាន់តែប្រសើរនោះទេ ក្នុងខណៈពេលដែលឪពុកម្តាយ និងពលករកុមារខ្លះ បានផ្តល់នូវការយកចិត្តទុកដាក់ខ្លាំង ទៅលើការចេះប្រយ័ត្នប្រយែងរបស់ពលករកុមារខ្លួនឯង ជាជាងការលើកពីបញ្ហា ដែលអាចចូលរួមជាសំខាន់ ដល់ការកែលម្អស្ថានភាពការងាររបស់ពលករកុមារជារួម ។

ទោះជាយ៉ាងណាក៏ដោយ អ្នកតបសម្ភាសន៍ខ្លះបានបញ្ចេញនូវសំណើមួយចំនួន ទោះជាសមាមាត្រនៃអ្នកដែលផ្តល់សំណើនេះមានចំនួនទាបក៏ដោយ គឺភាគរយធំបំផុតគឺត្រឹមតែ ២១%នៃកុមារដែលរស់នៅតាមភូមិ, ១១.៨% នៃកុមារដែលរស់នៅតាមសិប្បកម្ម, ១៥.២%នៃឪពុកម្តាយដែលរស់នៅតាមសិប្បកម្ម, និង ៣០% នៃឪពុកម្តាយ ដែលនៅតាមភូមិ ។ សំណើរបស់ពួកគេមាន ការកាត់បន្ថយបន្ទុកការងារសំរាប់កុមារ, ការបង្កើនថ្លៃឈ្នួលសំរាប់កុមារ ការផ្តល់នូវឧបករណ៍ការពារសំរាប់កុមារ, ការអនុវត្តន៍ច្បាប់ដែលហាមឃាត់កុមារ មិនអោយធ្វើការងារគ្រោះថ្នាក់ ការបង្កើតច្បាប់ហាមឃាត់រាល់ការបង្ខិតបង្ខំកុមារអោយធ្វើការ ហួសសមត្ថភាព រូបកាយរបស់ខ្លួន ការផ្តល់ការឈប់សំរាកពេលមានជំងឺដោយសារបំពេញការងារ, និងការផ្តល់ការឧបត្ថម្ភគាំទ្រ ដល់ការសិក្សារបស់កុមារ ។

## ក្រាហ្វិកទី១៨ : ការកែលម្អស្ថានភាពការងារសំរាប់កុមារនៅសិប្បកម្មឡឥដ្ឋ



# ជំពូកទី៦: សេចក្តីសន្និដ្ឋាននិងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំឡើងដើម្បីពិពណ៌នាពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅរបស់កុមារ ដែលធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ ព្រមទាំងផលប៉ះពាល់នៃពលកម្មកុមារលើការរីកលូតលាស់របស់កុមារ។ លើសពីនេះទៅទៀត មូលហេតុនៃការធ្វើការងារ មូលហេតុនៃការធ្វើអោយកុមារចូលរួមក្នុងពលកម្មកុមារ និងមូលហេតុនៃការទទួល កុមារអោយធ្វើការ ត្រូវបានចងក្រងទុកជាឯកសារ ដោយផ្អែកលើកិច្ចសម្ភាសន៍ ជាមួយពលករកុមារ ឪពុកម្តាយរបស់ពួកគេ និងនិយោជករបស់ពួកគេ។ ទីតាំងស្រាវជ្រាវ គឺនៅសិប្បកម្មឡឥដ្ឋ ទាំងអស់ដែលស្ថិតនៅក្នុងស្រុកពីរនៃខេត្តបាត់ដំបង គឺស្រុកបាត់ដំបង និងស្រុកសង្កែ ដែលជាតំបន់នៅជុំវិញទីរួមខេត្តបាត់ដំបង។ ទិន្នន័យត្រូវបានប្រមូលដោយប្រើប្រាស់កម្រងសំណួរដែលបំពេញ ដោយអ្នកធ្វើសម្ភាសន៍ ដែលសម្ភាសន៍ប្រភពសំខាន់ៗចំនួន ៣ (ពលករកុមារ ចំនួន ១៣២ នាក់ ឪពុកម្តាយ ៤៣ នាក់ និងម្ចាស់ ឬអ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋចំនួន ១៥ នាក់) មកពីសិប្បកម្មឡឥដ្ឋចំនួន ២៦ កន្លែង។

ពលករកុមារនៅក្នុងសិប្បកម្មឡឥដ្ឋប្រហែល ៣០កន្លែង នៅក្នុងតំបន់គោលដៅ ត្រូវបានសន្និដ្ឋានថាមានកុមារ យ៉ាងហោចណាស់ពី ៤០០ ទៅ ៥០០ នាក់ធ្វើការ នៅក្នុងកំឡុងរដូវដែលមានតម្រូវការការងារខ្ពស់។ កុមារទាំងនេះជា កុមារដែលមកតែពីភូមិដែលនៅជិតសិប្បកម្មឡឥដ្ឋ ឬកុមារដែលរស់នៅក្នុងបរិវេណសិប្បកម្មឡឥដ្ឋ។ កុមារម្នាក់ក្នុងចំណោមកុមារធ្វើការ ៥ នាក់ ដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ ពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយពួក គេធ្លាប់ធ្វើការជាអ្នកបញ្ជាម៉ាស៊ីន យ៉ាងហោចណាស់ក៏ម្តងម្កាលនៅក្នុងកំឡុងអាជីពការងាររបស់ពួកគេ និងមិនដែលទៅសាលារៀន ឬឈប់ទៅសាលារៀន។ តួលេខគឺ ១៣,៣% ក្នុងចំណោមកុមារដែលមិនរស់នៅក្នុងសិប្បកម្មឡឥដ្ឋ ។ ម្យ៉ាងវិញទៀត កុមារប្រហែល ៥០% ចូលរួមក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ពីព្រោះពួកគេធ្វើការចន្លោះពី ៦ ទៅ ១០ ម៉ោងក្នុងមួយថ្ងៃ ដោយមិនបានទៅសាលារៀន។ ចំណុចនេះបង្ហាញអោយឃើញ អំពីទំហំប៉ាន់ស្មាននៃការចូលរួមរបស់កុមារ នៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

ពលករកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ មានទំនោរចាប់ផ្តើមធ្វើការនៅអាយុក្មេងជាងកុមារដែលរស់នៅក្នុងភូមិ ដោយសារតែឪពុកម្តាយពួកគេមានតម្រូវការអោយពួកគេធ្វើការ។ ចំណុចនេះ ហាក់ដូចជាបង្ហាញនូវការប្រឈមមុខយូរនឹងការងារ និងភាពងាយរងគ្រោះខ្ពស់ចំពោះការងារប្រកបដោយគ្រោះថ្នាក់ ក្នុងចំណោមកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ។ ការងារទូទៅបំផុតដែលធ្វើដោយកុមារមានដូចជា ជញ្ជូនឥដ្ឋ លើកដាក់ និងលើកចេញ។ បើតាមអ្នកឆ្លើយសម្ភាសន៍ស្ទើរតែទាំងអស់ ទាំងពលករកុមារខ្លួនឯង ឪពុកម្តាយ ឬម្ចាស់ ឬអ្នក

គ្រប់គ្រងសិប្បកម្មឡឥដ្ឋ ភាពខ្វះខាត ផ្នែកសេដ្ឋកិច្ចគ្រួសារគឺជាមូលហេតុចម្បងគេបង្អស់ ដែលនាំអោយកុមារត្រូវធ្វើការ បន្ទាប់គឺមូលហេតុធ្វើការដើម្បីរកប្រាក់សម្រាប់ការសិក្សា និង/ឬបំពេញតម្រូវការផ្ទាល់ខ្លួន។

គួរកត់សម្គាល់ផងដែរថា សិប្បកម្មឡឥដ្ឋមានលក្ខណៈពិសេសដាច់ដោយឡែកជាច្រើន ដែលទាក់ទាញកុមារអោយមកធ្វើការ។ លក្ខណៈពិសេសទាំងនេះមានដូចជា តម្រូវការខ្ពស់នូវពលកម្មកុមារ (ជញ្ជូនឥដ្ឋ លើកចូល និងលើកចេញ) ងាយស្រួលរកការងារធ្វើ មិនត្រូវការជំនាញ ឬបទពិសោធន៍ មិនមានបទបញ្ជាតឹងតែង ងាយស្រួលរកប្រាក់ និងងាយស្រួលសុំបើកប្រាក់មុន ។ម្យ៉ាងវិញទៀត ចំពោះកុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋ ការងារស្នូលនៃការផលិតឥដ្ឋ (រៀបចំដីឥដ្ឋ ផលិតឥដ្ឋឆៅ និងដុតភ្លើងឡឥដ្ឋ) បានក្លាយទៅជាការងារ ជាលក្ខណៈគ្រួសារ ពីព្រោះពួកគេធ្វើការដើម្បី មានកន្លែងស្នាក់នៅ។ ប្រការនេះជំរុញអោយកុមារចូលរួមក្នុង ពលកម្មកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ នៅទីបំផុត។ បើតាមទស្សនៈរបស់ម្ចាស់/អ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋ ភាពសម្បូរណ៍បែបនៃកម្លាំងពលកម្មកុមារ ទឹកចិត្តសប្បុរសធម៌របស់ពួកគេ សំណើរបស់ឪពុកម្តាយអោយទទួលយក កូនធ្វើការ កុមារងាយស្រួលគ្រប់គ្រង និងសមត្ថភាពរបស់កុមារក្នុងការធ្វើការងារ (មកធ្វើការទៀងទាត់ មានឯករាជ្យភាព រហ័សរហួន ខិតខំប្រឹងប្រែងធ្វើការ និងស័ក្តិសមសម្រាប់ការងារ ជញ្ជូនឥដ្ឋ) គឺជាមូលហេតុដែលធ្វើអោយពួកគេក្នុងការទទួលកុមារអោយធ្វើការ ។

បរិយាកាសការងារនៅក្នុងសិប្បកម្មឡឥដ្ឋមានគ្រោះថ្នាក់ចំពោះសុខភាពកុមារ ដោយសារបរិស្ថានគ្មានអនាម័យ (មិនស្អាត ផ្សែង ក្លិនមិនល្អនៃជីលាមកសត្វ និងការប្រើប្រាស់ទឹកស្រះ) បរិយាកាសការងារគ្មានសុវត្ថិភាព (ដូចជា ក្តៅ ផេះក្តៅ កំទេចផេះហុយ និងកំទេចឥដ្ឋបាក់បែកនៅគ្រប់ទីកន្លែង) និងការងារប្រកបដោយគ្រោះថ្នាក់ (ម៉ោងធ្វើការយូរ ការងារធ្ងន់ និងមានគ្រោះថ្នាក់)។ សិប្បកម្មឡឥដ្ឋស្ទើរតែទាំងអស់ដែលយើងបានធ្វើទស្សនកិច្ច ត្រូវបានរកឃើញថាមាន លក្ខខណ្ឌការងារមិនល្អ និងមានគ្រោះថ្នាក់ ដោយសារតែកម្តៅមិនអាចទ្រាំទ្របាន ផេះក្តៅ និងកំទេចផេះហុយ ឥដ្ឋធ្លាក់លើ ខ្វះបង្គន់អនាម័យ គ្មានប្រអប់ថ្នាំពេទ្យសង្គ្រោះបឋម និងគ្មានបទបញ្ជាសុវត្ថិភាពការងារ។ លើសពីនេះទៅទៀត ការពាក់សម្ភារៈការពារ មិនទាន់ជាការអនុវត្តន៍ទូទៅសម្រាប់ពលករកុមារទាំងអស់នៅឡើយទេ ដោយសារតែខ្វះឧបករណ៍ ការពារសុវត្ថិភាព។

ការឆាប់ប្រឡូកក្នុងការងារមានន័យថា មានការប្រឈមមុខយូរនឹងការងារមានគ្រោះថ្នាក់ និងភាពងាយរងគ្រោះខ្ពស់ខាងសុខភាព។ ផលប៉ះពាល់នៃពលកម្មកុមារលើការរីកលូតលាស់របស់កុមារ ត្រូវបានរកឃើញគួរអោយកត់សម្គាល់ ដោយផ្អែកលើសន្ទស្សន៍ពីរ។ សន្ទស្សន៍ទីមួយ គឺការប៉ះពាល់ដល់ការសិក្សារបស់កុមារដែលត្រូវបានរកឃើញថា មានកម្រិតខ្ពស់ ក្នុងចំណោមពលករកុមារដែលធ្វើការយូរជាងកុមារដែលទើបចាប់ផ្តើមធ្វើការថ្មីៗ។ ផលប៉ះពាល់លើការសិក្សាមានដូចជា ទំនោរបោះបង់ចោលការសិក្សា ពិន្ទុខ្សោយ និងការទៅសាលារៀនមិនទៀងទាត់។ សន្ទស្សន៍មួយទៀត គឺការប៉ះពាល់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់កុមារដោយសារតែរបួស និងជំងឺដែលបង្កឡើងដោយការងារប្រកបដោយគ្រោះថ្នាក់។ ពលករកុមារដែលធ្វើការរយៈ

ពេលវែង យល់ឃើញថា លក្ខខណ្ឌសុខភាពទូទៅរបស់ពួកគេបានចុះ ខ្សោយចាប់តាំងពីធ្វើការមក។ ជាពិសេស ពលករកុមារជាច្រើនបានរអ៊ូរទាំអំពីការកើតជំងឺហៀរទឹកភ្នែក ឬរមាស់ភ្នែក ដោយសារតែផ្សែង និងកំទេច ផេះហុយ ឈឺឆ្អឹងខ្នង ឈឺទ្រូង ឈឺក្បាលញឹកញាប់ កន្ទួលរមាស់លើស្បែក ពិបាកដកដង្ហើម ឈឺក្រពះ ដាច់រលាត់ និងរបួសស្រាល ព្រមទាំងរលាកស្រាល ។

## ២. អនុសាសន៍

១. ដោយសារតែមូលហេតុចម្បងដែលកុមារត្រូវធ្វើការ គឺភាពខ្វះខាតផ្នែកសេដ្ឋកិច្ចគ្រួសារ វាហាក់ដូចជាទង្វើ មិនសមស្រប ដែលត្រូវលុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារ។ ប៉ុន្តែ កុមារគប្បីត្រូវបានហាមឃាត់ មិនអោយធ្វើ ការងារប្រកបដោយគ្រោះថ្នាក់ ដូចជា បញ្ជាម៉ាស៊ីនកិនឥដ្ឋ ដុតភ្លើងឡឥដ្ឋ និងរៀបចំដីឥដ្ឋ។ លើសពីនេះទៅទៀត ត្រូវកំណត់និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទបញ្ញត្តិពីបន្ទុកការងារ និងអាយុធ្វើការងារ។ បទបញ្ញាទាំងនេះមានដូចជា ការកាត់បន្ថយបន្ទុកការងារបច្ចុប្បន្នសម្រាប់កុមារ មិនមានការងារដោយបង្ខំ មិនមានការងារចុះកិច្ចសន្យា មិនមានការងារពេញម៉ោងសម្រាប់កុមារដែលមានអាយុក្រោម ១៥ ឆ្នាំ នៅក្នុង កំឡុងពេលសិក្សា មិនមានការងារលើសពី ៥ ថ្ងៃក្នុងមួយសប្តាហ៍ ចំពោះពលករកុមារដែលធ្វើការពេញម៉ោង ។ល។

២. កុមារមានសិទ្ធិក្នុងការអភិវឌ្ឍន៍។ អាស្រ័យហេតុនេះ កិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងពលកម្មកុមារត្រូវធានាថា ពលករកុមារទទួលបានឱកាសស្មើភាពគ្នាក្នុងការសិក្សា កុមារទៅសាលារៀន និងយ៉ាងហោចណាស់ នៅ រៀនរហូត ដល់ចប់ការអប់រំជាមូលដ្ឋាន។ ប្រសិនបើកុមារមិនអាចទៅសាលារៀនបានទៀងទាត់ ទោះបីដោយ សារមូលហេតុអ្វីក៏ដោយ ជាពិសេសកុមាររស់នៅក្នុងសិប្បកម្មឡឥដ្ឋ ត្រូវផ្តល់ការអប់រំជាបន្តនៅកន្លែងធ្វើការ ឬនៅកន្លែងកំណត់ណាមួយ។

៣. ពលករកុមារត្រូវមានសិទ្ធិទទួលបានអត្ថប្រយោជន៍ខាងសុខភាពពេញលេញ។ ម្យ៉ាងវិញទៀត និយោជក ត្រូវ ទទួលខុសត្រូវទាំងស្រុងចំពោះកម្មករជាកុមារ ដោយរ៉ាប់រងថ្លៃចំណាយលើសុខភាព ក្នុងករណីមានរបួស ឬ ជំងឺ ដោយសារការងារ ក៏ដូចជាការថែទាំអោយជាសះស្បើយឡើងវិញ។ ត្រូវតែមានអាជ្ញាធរសុខាភិបាល ក្នុងមូលដ្ឋានចូលរួមផងដែរ ។

៤. បង្កើនចំណេះដឹង និងការយល់ដឹងអំពីភាពគ្រោះថ្នាក់នៃការងារ។ ត្រូវខិតខំប្រឹងប្រែងដើម្បីបង្កើន ការយល់ ដឹងជាសាធារណៈអំពីសិទ្ធិកុមារ និងការខូចខាតដល់កុមារដែលបង្កឡើងដោយពលកម្មកុមារ។ ការបង្កើន ការយល់ដឹងនេះ តម្រូវអោយមានការសហការជាដៃគូក្នុងចំណោមក្រុមផ្សេងៗជាច្រើន ដូចជា រាជរដ្ឋាភិបាល

សហគ្រាស សហជីព គ្រូបង្រៀន អ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល មេដឹកនាំ សហគមន៍ និងភាគីពាក់ព័ន្ធ ឪពុកម្តាយ ក៏ ដូចជាកុមារខ្លួនឯងផ្ទាល់។

៥. បទបញ្ញាស្តីពីសុវត្ថិភាពការងារគប្បីត្រូវបានបង្កើត និងធ្វើអោយមានស្តង់ដារ សម្រាប់គ្រប់សិប្បកម្មឡឥដ្ឋទាំងអស់។ ត្រូវផ្តល់ភាពធរមានផ្នែកច្បាប់ដល់បទបញ្ញាទាំងនេះ។ បទបញ្ញាត្រូវចែងផងដែរអំពីតម្រូវការខាងវិធានការសុវត្ថិភាពសម្រាប់ពលករកុមារទាំងអស់ ដែលរួមមានបរិយាកាសការងារមានសុវត្ថិភាព និងការប្រើប្រាស់សម្ភារៈការពារ សុវត្ថិភាព ដូចជា មួកសុវត្ថិភាព ស្បែកជើងធ្វើការ ស្រោមដៃ របាំងមុខ និងវ៉ែនតាការពារ។ និយោជកត្រូវទទួល ខុសត្រូវក្នុងការផ្តល់សម្ភារៈសុវត្ថិភាពទាំងនេះដល់ពលករកុមារ ហើយមិនត្រូវបញ្ជា ឬអនុញ្ញាតអោយកម្មករធ្វើការឡើយ ប្រសិនបើមិនមានពាក់សម្ភារៈការពារនៅពេលធ្វើការ។ ផ្លាកសញ្ញាព្រមាន ឬប័ណ្ណប្រកាសគ្រោះថ្នាក់ ត្រូវបិទនៅលើឧបករណ៍ធ្វើការនីមួយៗ និងនៅតំបន់ដែលគំរាមកំហែងដល់សុខភាព ឬបង្ករបួស ឬគ្រោះថ្នាក់។

៦. ត្រូវមានសម្ភារៈសុវត្ថិភាពសម្រាប់ម៉ាស៊ីនកិនឥដ្ឋទាំងអស់។ ខ្សែពានម៉ាស៊ីនត្រូវបិទគម្រប អោយបានជិតត្រឹមត្រូវ។ ប្រហោងម៉ាស៊ីនសម្រាប់ដាក់ដីឥដ្ឋត្រូវដាក់បំពង់ ធ្វើយ៉ាងណាកុំអោយប៉ះពាល់ដោយផ្ទាល់ដល់ដៃ និងម៉ាស៊ីន។

៧. ត្រូវបង្កើតយន្តការពិនិត្យតាមដាន និងអនុវត្ត ក៏ដូចជា ក្រមសីលធម៌សម្រាប់និយោជក ដែលដាក់កំហិតចំពោះការទទួលកុមារអោយធ្វើការ ដូចបានកំណត់ដោយបទបញ្ញាការងារ និងសុវត្ថិភាពការងារ សេចក្តីណែនាំ អំពីសុវត្ថិភាព ការងារចំពោះពលករកុមារទាំងអស់ អធិការកិច្ចការងារ អធិការកិច្ចសុវត្ថិភាព ការផាកពិន័យ និងការត្រួតពិនិត្យ សុខភាព។

៨. សិក្ខាសាលាអំពីស្ថានភាពបច្ចុប្បន្ននៃច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងប្រកាសដែលមានស្រាប់ផ្សេងទៀត ពាក់ព័ន្ធនឹងពលកម្មកុមារ ត្រូវរៀបចំឡើងសម្រាប់ម្ចាស់/អ្នកគ្រប់គ្រងសិប្បកម្មឡឥដ្ឋ កម្មករ និងពលករជាកុមារ។ ក្រៅពីនេះ ព័ត៌មានអំពីពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ផលប៉ះពាល់នៃពលកម្មកុមារទៅលើ ការរីកលូតលាស់របស់កុមារ វិធានការដែលត្រូវការ ដើម្បីកាត់បន្ថយ ផលប៉ះពាល់ និងបទបញ្ញាការងារ ត្រូវផ្សព្វផ្សាយតាមរយៈកម្មវិធីចុះអប់រំណែ នាំដល់ឪពុកម្តាយ ដោយសហប្រតិបត្តិការ និងមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ដូចជាអាជ្ញាធរមូលដ្ឋាន និយោជក គ្រូបង្រៀន អ្នកមានវិជ្ជាជីវៈ

សុខាភិបាល និងមន្ត្រីអនុវត្តច្បាប់។ ត្រូវលើកទឹកចិត្តអោយមានបរិយាកាស ការងារមានសុវត្ថិភាព និងការការពារនៅនឹងកន្លែង។

៩. តាមធម្មតា កុមារមិនអាចតស៊ូដើម្បីសិទ្ធិរបស់ខ្លួនបានទេ ពីព្រោះពួកគេគ្មានអំណាច ។ អាស្រ័យហេតុនេះ កម្មករជាកុមារ ត្រូវការអ្នកដទៃដើម្បីធ្វើការតស៊ូមតិ និងធ្វើយុទ្ធនាការជំនួសខ្លួន។ អ្នកតស៊ូមតិប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារត្រូវផ្តួចផ្តើមនូវសកម្មភាពសង្គម ក្នុងគោលដៅបង្កើតការយល់ដឹងជាសាធារណៈអំពីបញ្ហាពលកម្មកុមារ និងធ្វើអោយមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ និងភាគីមានសមត្ថកិច្ចទាំងអស់។ លើសពីនេះទៅទៀត អ្នកតស៊ូមតិត្រូវផ្តល់អាទិភាពដល់ការកំណត់អត្តសញ្ញាណកុមារដែលរស់នៅក្នុងគ្រួសារក្រីក្រ និងកុមារកំពុងពាក់ព័ន្ធនឹង ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ពីព្រោះកុមារទាំងនេះ ជាអ្នកប្រឈមមុខខ្ពស់បំផុតនឹងការបង្ខំអោយធ្វើការ។

# ឯកសារយោង


Ashagrie, Kebebew, 1998, *Statistics on Working Children and Hazardous Child Labour in Brief*, Geneva: International Labour Organization.

ILO. 1999. *Convention 182: Convention on* the *Worst Forms of Child Labour*, Geneva, International Labour Organization.

ILO/IPEC, 2002, *Study on the Legal Protection of Child Domestic Workers in the Asia-Pacific*, ILO/Japan/Korea, Asian Meeting on Action to Combat Child Domestic Labour, Chiang Mai, Thailand 2-4 October 2002.

Lansky, M. 1997. "Child Labour: How the Challenge is Being Met." *International Labour Review*, 136(2): 233-257.

*LICADHO Education and Advocacy Kit*, working document, 2001.

Ministry of Labour and Vocational Training. *Proclamation about Prohibiting Children to Work in Dangerous Places*. Dated: 28 April 2004.

Ministry of Industry, Mine, and Energy. Business Directory. Accessed on September 29, 2007 at http://www.mime.gov.kh/khmer/businessdirectory.asp

NIOSH, 1997, *Child Labour Research Needs: Recommendations from the National Institute for Occupational Safety and Health*, US Department of Health and Human Services and CDC. Accessed online at http://www.cdc.gov/niosh/97-143a.html.

NIS. 2002. *Cambodia Child Labour Survey 2001*. National Institute of Statistics. Phnom Penh, Cambodia: Ministry of Planning.

O'Donnell, Owen, Eddy Van Doorslaer, and Furio C. Rosati, 2002. "Child Labour and Health: Evidence and Research Issues." *Understanding Children's Work: An Inter-Agency Research Cooperation Project*. ILO, UNICEF, and the World Bank.

Pinder, Andrew D.J., 2000, *Manual Handling in the Brick Production Industry: Results of a Study of the Ergonomics of Brick Packing*, Health & Society Laboratory: Human Factors Group, UK. http://www.hse.gov.uk/research/hsl_pdf/2000/hsl00-20.pdf.

Rozemuller, Bas. 1999. *An Overview of the Brick and Tile Manufacturing Industry in North West Cambodia*. CAS and UNDP/CARERE.

UCW, 2006, *Children's Work in Cambodia: A Challenge for Growth and Poverty Reduction*, Inter-Agency Report to the Government of Cambodia, ILO/IPEC, UNICEF, and World Bank. Accessed online at www.ucw-project.org/ucw/cambodia_rpt.pdf

Woolf, A., 2002, "Health Hazards for Children at Work", *Journal of Toxicology and Clinical Toxicology*, 40(4): 477-482.

WVC, 2005, *How and Why We Work: Child Workers in the Informal Economy In Phnom Penh and Battambang*, WVC Report for the Combating the Worst Forms of Child Labour Project. Phnom Penh, Cambodia: Peace and Justice Programme, WVC.

WVC. July 2006. *Assessment of Public Health Risks and Positive Health Practices for Working Children*. A Report prepared by Dr. Poch Bunnak, CPS at RUPP, for the Combating the Worst Forms of Child Labour. Phnom Penh, Cambodia: WVC.

# ឧបសម្ព័ន្ធទី១: កម្រងសំណួរសម្ភាសន៍ជាមួយពលករកុមារ

លេខកូដកម្រងសំណួរ................. ឈ្មោះអ្នកសម្ភាសន៏..................... ថ្ងៃធ្វើការសម្ភាសន៏........... ០៧,២០០៧

ឡូត៍ដ្ឋ............... ភូមិ.........................ឃុំ........................... ផ្តើមនៅម៉ោង............. ចប់នៅម៉ោង...........

ត្រួតពិនិត្យដោយប្រធានក្រុមៈ ឈ្មោះ......................................... ហត្ថលេខា......................................

**ការណែនាំ :**

ខ្ញុំឈ្មោះ...........ជាអ្នកស្រាវជ្រាវអោយអង្គការលីកាដូ និងអង្គការទស្សនៈពិភពលោកកម្ពុជា ដើម្បីស្វែងយល់អោយកាន់តែ ច្បាស់អំពីការ រស់នៅ, ការសិក្សា, សុខភាព និងការងាររបស់កុមារដែលរស់នៅទីក្រុងបាត់ដំបងនេះ។ ការស្រាវជ្រាវនេះ អាចសំរេចទៅបាន គឺត្រូវមានការសហការរបស់ប្អូន។ ដូចនេះ ខ្ញុំចង់សូមអោយប្អូនចូលរួមឆ្លើយនូវសំណួរខ្លះៗដែលទាក់ទង នឹងប្រធានបទខាងលើ ។ រាល់ចំលើយទាំងអស់ មិនមានខុស រឺ ត្រូវទេ។ ប្រសិនបើមានសំណួរណាដែលប្អូនមិនចង់ឆ្លើយ ប្អូនអាចមិនឆ្លើយបាន ។ ការសម្ភាសន៏នេះចំណាយពេលប្រហែល ៣០នាទី ។ គ្រប់ព័ត៌មានទាំងអស់នឹងត្រូវរក្សាជាការសំងាត់ និងប្រើប្រាស់ដើម្បីសរសេររបាយការណ៍រួមតែប៉ុណ្ណោះ ។ តើប្អូនយល់ព្រម ចូលរួមសម្ភាសន៏រឺទេ (**ព្រម រឺមិន ព្រម**) ។ បើព្រមហើយ តើយើងអាចចាប់ផ្តើមបានទេ ?

**<u>ព័ត៌មានផ្ទាល់ខ្លួន</u>**

1. ភេទ: [ ] ប្រុស [ ] ស្រី
2. អាយុ: .....................ឆ្នាំ
3. តើ ផ្ទះប្អូននៅក្នុងបរិវេណឡូត៍ដ្ឋនេះឬ?
   ១. អត់ទេ។ ផ្ទះខ្ញុំនៅភូមិ.......................................... ឃុំ .....................................
   ២. បាទ-ចាស់
4. តើប្អូនរស់នៅជាមួយនរណា? (**ចំលើយអាចមានពីរ**)
   ១. រស់នៅជាមួយឪពុកបង្កើត ២. រស់នៅជាមួយឪពុកចុង
   ៣. រស់នៅជាមួយម្តាយបង្កើត ៤. រស់នៅជាមួយម្តាយចុង
   ៥.អាណាព្យាបាលផ្សេងទៀត (**សូមបញ្ជាក់**) .........................................................................
5. បើមាន ឪពុក ឪពុកចុង ឬអាណាព្យាបាល (ប្រុស) តើគាត់ប្រកបមុខរបរអ្វីជាចំបង ?
   .......................................................................................................................
6. បើមានម្តាយ ម្តាយចុង ឬអាណាព្យាបាល (ស្រី) តើគាត់ប្រកបមុខរបរអ្វីជាចំបង ?
   .......................................................................................................................

7. តើប្អូនមានបងប្អូនបង្កើតប៉ុន្មាននាក់ ? ............................... ( ប្រសិនបើមានតែម្នាក់ឯង សូមរំលងទៅសំនួរទី ១០)

8. មានបងប្អូនប៉ុន្មាននាក់ពីអាយុ៧-១៧ឆ្នាំ?...............................

9. តើអ្នកជាកូនទីប៉ុន្មាននៅក្នុងគ្រួសារ?....................................

10. សូមរៀបរាប់គ្រប់បងប្អូនបង្កើតដែលមានអាយុពី ៧-១៧ឆ្នាំ ( **មិនត្រូវរាប់បញ្ចូលទាំងប្អូនខ្លួនឯងទេ**)

| បងប្អូនបង្កើត | ភេទ **បស** | អាយុ | រៀនថ្នាក់ទី **( សូមកត់ 0 បើអត់ដែលទៅសាលា** | មុខរបរ **( សូមកត់ត្រាជា សិស្ស ប្រសិនបើគេនៅរៀនសូត្រ)** |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |

**<u>ឥឡូវ យើងចង់សាកសួរប្អូនអំពីការសិក្សារបស់ប្អូន</u>**

11. សព្វថ្ងៃនេះ តើប្អូនមានទៅរៀនដែរឺទេ?

១. អត់ទេ → តើពីមុនប្អូនធ្លាប់បានទៅរៀនដែរឺទេ?

១. ទេ។ ហេតុអ្វីបានជាប្អូនមិនបានទៅរៀន? ...............................................................

.......................................................................................................................

២. ចាស /បាទ ប្រសិនបើ ធ្លាប់បានរៀនៈ

-តើប្អូនបានរៀនថ្នាក់ខ្ពស់បំផុត ថ្នាក់ទីប៉ុន្មាន?..................................................

-តើប្អូនបានឈប់រៀនអស់រយៈពេលប៉ុន្មានហើយ? .........................ខែ...............ឆ្នាំ

-ហេតុអ្វីបានជាប្អូនឈប់ទៅរៀន?..................................................................

.........................................................................................( **ទៅសំណួរទី ២០**)

២. ចាស /បាទ

12. តើប្អូនរៀនថ្នាក់ទីប៉ុន្មានសព្វថ្ងៃនេះ? .....................................

13. តើប្អូនទៅរៀន ប៉ុន្មានថ្ងៃក្នុងមួយអាទិត្យ? .........................

14. ចាប់តាំងពីប្អូនធ្វើការមក តើការសិក្សារបស់ប្អូន ប្រសើរឡើងជាងមុន, នៅដដែល, រឺក៏មិនសូវល្អដូចមុន?

១. មិនសូវល្អ ២. ដូចមុន ៣. ប្រសើរឡើង

15. ចាប់តាំងពីប្អូនធ្វើការមក តើប្អូនធ្លាប់ទៅរៀនយឺតដែររឺទេ?

១. មិនដែល ២. ពេលខ្លះៗ ៣. ញឹកញាប់

បើ ២ រឺ ៣ ជាចំលើយ សូមសួរថា តើប្អូនធ្លាប់ទៅរៀនយឺតដូច្នេះរឺ ពីមុនមក? ១. ទេ ២. បាទ- ចាំស

16. ចាប់តាំងពីប្អូនធ្វើការមក តើប្អូនធ្លាប់គេចសាលា មិនចូលរៀនដែលរឺទេ?

១. មិនដែល ២. ពេលខ្លះៗ ៣. ញឹកញាប់

បើ ២ រឺ ៣ ជាចំលើយ សូមសួរថា តើប្អូនធ្លាប់គេចសាលាដូច្នេះរឺ ពីមុនមក? ១. ទេ ២. បាទ- ចាំស

17. ចាប់តាំងពីប្អូនធ្វើការមក តើទំនាក់ទំនងរបស់ប្អូនជាមួយសិស្សដទៃទៀត មានការប្រសើរជាងមុន រឺអាក្រក់ជាងមុន?

១. អាក្រក់ជាងមុន ២. នៅដដែល ៣. ប្រសើរជាងមុន

18. ចាប់តាំងពីប្អូនធ្វើការមក តើប្អូនធ្លាប់វាយគ្នាជាមួយសិស្សដទៃទៀតដែលរឺទេ?

១. មិនដែល ២. ពេលខ្លះ ៣. ញឹកញាប់

បើ ២ រឺ ៣ ជាចំលើយ សូមសួរថា តើប្អូនធ្លាប់ វាយគ្នាដូច្នេះរឺ ពីមុនមក? ១. ទេ ២. បាទ- ចាំស

19. ចាប់តាំងពីប្អូនធ្វើការមក តើប្អូនធ្លាប់ទទួលពិន័យរបស់សាលាដែលរឺទេ?

១. ទេ

២. ចាំស /បាទ ។ តើមកពីអ្វី?..........................................................................................................

.............................................................................................................................................

**ឥឡូវ យើងចង់សាកសួរប្អូនអំពីការងាររបស់ប្អូន**

20. តើការងារពិតប្រាកដរបស់ប្អូននៅទីនេះ គឺការងារអ្វី? (**ចំលើយអាចលើសពីមួយ**)

១. អ្នកកាន់ម៉ាស៊ីនធ្វើឥដ្ឋ
២. អ្នកកាត់ពុម្ពឥដ្ឋ
៣. អ្នកជីកដីឥដ្ឋ
៤. អ្នកកិនដីឥដ្ឋ
៥. អ្នកលាយដីឥដ្ឋ
៦. អ្នករ៉ែកដីឥដ្ឋ
៧. អ្នកដាក់ និងអ្នកយកឥដ្ឋចេញពីឡឥដ្ឋ
៨. អ្នកលើកឥដ្ឋដាក់លើឡាន
៩. អ្នករើឥដ្ឋដាក់ចូលក្នុង និងចេញពីរទេះ
១០. អ្នកអូសរទេះឥដ្ឋ
១១. អ្នករៀបឥដ្ឋដាក់ហាល
១២. ផ្សេងៗ **សូមបញ្ជាក់**

........................................................................................................

21. តើមានការងារអ្វីខ្លះ ដែលគេហាមមិនអោយប្អូនធ្វើនៅទីនេះ? (**សូមកុំអានចំលើយ ។ ចំលើយអាចលើសពីមួយ**)

១. គ្មានការហាមប្រាមទេ → (**ទៅសំណួរទី២៣**)

២. អ្នកកាន់ម៉ាស៊ីនធ្វើឥដ្ឋ

៣. អ្នកកាត់ពុម្ពឥដ្ឋ

៤. អ្នកជីកដីឥដ្ឋ

៥. អ្នកកិនដីឥដ្ឋ

៦. អ្នកលាយដីឥដ្ឋ

៧. អ្នករែកដីឥដ្ឋ

៨. អ្នកដាក់ និងអ្នកយកឥដ្ឋចេញពីឡឥដ្ឋ

៩. អ្នកលើកឥដ្ឋដាក់លើឡាន

១០. អ្នករើឥដ្ឋដាក់ចូលក្នុង និងចេញពីរទេះ

១១. អ្នកអូសរទេះឥដ្ឋ

១២. អ្នករៀបឥដ្ឋដាក់ហាល

១៣. ផ្សេងៗ **សូមបញ្ជាក់** ..........................................................................................

22. តើនរណាជាអ្នកហាមឃាត់?(សូមកុំអានចំលើយ)

១. គ្មាននរណាទេ

២. ម្ចាស់ឡ

៣. អ្នកគ្រប់គ្រងការងារ

៤. អ្នកត្រួតពិនិត្យការងារ

៥. ឪពុកម្តាយ-បងប្អូន

៦. អត់ដឹង

៧. ផ្សេងទៀត ...............................................................

23. តើប្អូនធ្វើការ នៅទីនេះបានរយៈពេលប៉ុន្មានខែឆ្នាំហើយ? ............................ខែ ,,,,,,,,,, ឆ្នាំ

24. ឥឡូវ ប្អូនរៀបរាប់ប្រាប់បងពីថ្ងៃធ្វើការ ម៉ោងធ្វើការ ដែលប្អូនបានធ្វើកន្លងមក

| **តើប្អូនធ្វើការថ្ងៃណាខ្លះ?** | **ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ** | **ម៉ោងដែលធ្វើការជាធម្មតា** |
|---|---|---|
| ១. ធ្វើម៉ៅការ | .....................ម៉ោង | ពីម៉ោង........ដល់........ និងពីម៉ោង............ដល់......... |
| ២. ធ្វើរាល់ថ្ងៃ | .....................ម៉ោង | ពីម៉ោង........ដល់........ និងពីម៉ោង............ដល់......... |
| ៣. ធ្វើ....ថ្ងៃរាល់សប្តាហ៍ | .....................ម៉ោង | ពីម៉ោង........ដល់........ និងពីម៉ោង.....,,,,..ដល់......... |
| ៤. ធ្វើរាល់ចុងសប្តាហ៍ | .....................ម៉ោង | ពីម៉ោង........ដល់........ និងពីម៉ោង............ដល់......... |
| ៥. ធ្វើរាល់ពេលទំនេរ | .....................ម៉ោង | ពីម៉ោង........ដល់........ និងពីម៉ោង............ដល់......... |

25. ហេតុអ្វីបានជាប្អូនទៅធ្វើការ? ( **មិនត្រូវអានចំលើយ ។ ចំលើយលើសពី១)**

១. ឪពុកម្តាយ/អាណាព្យាបាលរបស់ខ្ញុំ បង្ខំខ្ញុំអោយទៅធ្វើការ

២. គ្រួសាររបស់ខ្ញុំត្រូវការប្រាក់ទិញបាយ

៣. គ្រួសាររបស់ខ្ញុំត្រូវការលុយដើម្បីទិញថ្នាំ

៤. គ្រួសាររបស់ខ្ញុំត្រូវការលុយដើម្បីដោះបំណុល

៥. ជួយការងាររបស់ឪពុកម្តាយ/សាច់ញាតិ

៦. ដើម្បីមានលុយទៅរៀន ( ចំណាយអោយថ្លៃសាលា រឺក៏ទិញសំភារៈសិក្សា រឺក៏ទិញនំចំណីនៅសាលារៀន)

៧. ដើម្បីមានលុយសំរាប់តំរូវការផ្ទាល់ខ្លួន

៨. ដើម្បីជួបមិត្ត រឺតាមមិត្តភក្តិ

៩. ដើម្បីចេញអោយផុតពីផ្ទះ

១០. មិនចង់ទៅសាលារៀន រឺ រៀនមិនកើត

១១. បានវាយគ្នា/មានបញ្ហាជាមួយសិស្សនៅសាលារៀន

១២. ផ្សេងៗ **សូមបញ្ជាក់** ......................................................................................................

26. ហេតុអ្វីបានជាប្អូនទទួលធ្វើការនៅឡូតជ្ជនេះ ? ( **មិនទៅកន្លែងផ្សេង)**

........................................................................................................................................

........................................................................................................................................

27. តើប្អូនរកប្រាក់បានប៉ុន្មានក្នុង១ថ្ងៃ គិតជាមធ្យម?..................................រៀល

28. តើប្អូនយកប្រាក់ដែលរកបាននេះទៅធ្វើអ្វីខ្លះ?.......................................................................

........................................................................................................................................

.

........................................................................................................................................

29. តើប្អូនគិតថាលុយដែលប្អូនរកបានមានសារៈសំខាន់ប៉ុណ្ណាដែរ ក្នុងការជួយដោះស្រាយតំរូវការគ្រួសាររបស់ប្អូន?

១. មិនមានសារៈសំខាន់អ្វីទាំងអស់ ២. មានសារៈសំខាន់តិចតួច ៣. មានសារៈសំខាន់ណាស់

30. តើប្អូនគិតថាលុយដែលប្អូនរកបានមានសារៈសំខាន់ប៉ុណ្ណាដែរ សំរាប់ខ្លួនប្អូនផ្ទាល់?

១. មិនមានសារៈសំខាន់អ្វីទាំងអស់ ២. មានសារៈសំខាន់តិចតួច ៣. មានសារៈសំខាន់ណាស់

31. តើប្អូនធ្លាប់ធ្វើការកន្លែងផ្សេងទៀត មុនពេលមកធ្វើការនៅទីនេះដែររឺទេ?

១. ទេ

២. ចាស/បាទ។ ការងារអ្វីដែរ? ..........................................................................................

32. តើប្អូនចាប់ផ្តើមធ្វើការរកលុយដំបូងនៅអាយុប៉ុន្មាន?............................ឆ្នាំ

**ព័ត៌មានពីសុខភាព**

33. តើប្អូនធ្លាប់មានបញ្ហាដូចខាងក្រោមដែរឬទេ តាំងពីធ្វើការនៅឡូតឌ្ឋមក ហើយញឹកញាប់ប៉ុណ្ណា?

| | **បញ្ហាដោយសារការងារ** | **ហើយញឹកញាប់ប៉ុណ្ណា?** |
|---|---|---|
| ១ | មុត រឺរបួសតិចតួច | ១. មិនដែល ២. មានតែកំរ ៣.ម្តងម្កាល ៤. ញឹកញាប់ |
| ២ | មុត/របួសធ្ងន់ធ្ងរ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៣ | បាក់ឆ្អឹង | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៤ | គ្រេច ថ្លោះ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៥ | រលាកតិចតួច | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៦ | រលាកខ្លាំង | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៧ | ផ្សេងទៀត ................................ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |

34. (**បើមិនដែលមានសោះ សូមរំលងសំណួរនេះ**) តើគ្រោះថ្នាក់មួយណាដែលធ្ងន់ធ្ងរខ្លាំងជាងគេ? (**អាចមានលើសពីមួយ**)

| | **គ្រោះថ្នាក់ដែលធ្ងន់ធ្ងរខ្លាំងជាងគេ** | **តើវាកើតឡើងដូចម្តេច?** |
|---|---|---|
| ១ | | |
| ២ | | |

35. តើប្អូនធ្លាប់មានបញ្ហាសុខភាពដូចខាងក្រោមដែរឬទេ តាំងពីធ្វើការនៅឡូតឌ្ឋមក ហើយញឹកញាប់ប៉ុណ្ណា?

| | **បញ្ហាដោយសារការងារ** | **ហើយញឹកញាប់ប៉ុណ្ណា?** |
|---|---|---|
| ១ | ឈឺដើមទ្រូង | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ២ | ឈឺខ្នង | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៣ | ឈឺខ្លួន រឺ ឈឺសាច់ដុំ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៤ | ពិបាកដកដង្ហើម | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៥ | ឈឺក្បាល | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៦ | ក្តៅខ្លួន | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៧ | ក្អក | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៨ | វិលមុខ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ៩ | ឈឺពោះ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ១០ | រាគ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ១១ | រមាស់ | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ១២ | ស្បែកឡើងកន្ទួលក្រហម | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |
| ១៣ | ផេះចូលភ្នែក ចេញទឹកភ្នែក រឺរមាស់ភ្នែក | ១. មិនដែល ២. មានតែកំរ ៣. ម្តងម្កាល ៤. ញឹកញាប់ |

| | | |
|---|---|---|
| ១៤ | ផ្សេងទៀត ............................ | ១. មិនដែល ២. មានតែកំរ ៣. មួងម្កាល ៤. ញឹកញាប់ |

36. (**បើមិនដែលមានសោះ សូមរំលងសំណួរនេះ**) តើជំងឺមួយណាដែលប្អូនឈឺធ្ងន់ធ្ងរខ្លាំងជាងគេ? (**អាចមានលើសពីមួយ**)

| | **ជំងឺដែលធ្ងន់ធ្ងរខ្លាំងជាងគេ** | **តើវាកើតឡើងដូចម្ដេច?** |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |

37. តើប្អូនមានអារម្មណ៍យ៉ាងម៉េចដែរ ចំពោះសុខភាពរបស់ប្អូនសព្វថ្ងៃនេះ បើប្រៀបធៀបទៅនឹងមុនពេលដែលប្អូនមកធ្វើការ នៅទី នេះ ? តើវា ១. អាក្រក់ជាងមុន ២. ដូចពីមុន ៣. ប្រសើរជាងមុន

38. តើអ្នកដឹងថាមកពីហេតុអ្វីដែរ? ..................................................................................................

39. តាមប្អូនដឹង តើឃ្លានិមួយៗខាងក្រោមនេះ ពិត រឺមិនពិត ចំពោះប្អូន?

| | **តាំងពីធ្វើការនៅទីនេះមក** | |
|---|---|---|
| ១ | ខ្ញុំឈឺច្រើនជាងមុន | ១. ពិត ២. មិនពិត |
| ២ | ខ្ញុំញ៉ាំអាហារបានតិចជាងមុន | ១. ពិត ២. មិនពិត |
| ៣ | ខ្ញុំស្រកទំងន់ | ១. ពិត ២. មិនពិត |
| ៤ | ខ្ញុំយល់សប្តិអាក្រក់ច្រើន | ១. ពិត ២. មិនពិត |
| ៥ | ខ្ញុំពិបាកគេងយប់ | ១. ពិត ២. មិនពិត |
| ៦ | ខ្ញុំមានអារម្មណ៏អស់កម្លាំងជាទូទៅ | ១. ពិត ២. មិនពិត |
| ៧ | ភ្នែកខ្ញុំមើលពុំសូវច្បាស់ដូចមុន | ១. ពិត ២. មិនពិត |
| ៨ | ខ្ញុំស្តាប់ពុំសូវច្បាស់ដូចមុន | ១. ពិត ២. មិនពិត |
| ៩ | ខ្ញុំភ្លេចភ្លាំងច្រើនជាងមុន | ១. ពិត ២. មិនពិត |

## លក្ខខណ្ឌការងារ និង សុវត្ថិភាព

40. តើអ្នកធ្លាប់ត្រូវបានទទួលការបង្រៀនរឺក៏ប្រាប់ពីការធ្វើការដោយសុវត្ថិភាព និងការការពារ ក្នុងកំឡុងពេលដែលអ្នកធ្វើការនៅទីនេះដែលរឺទេ ?

    0. ទេ
    ១. ចាស/បាទ **ប្រសិនបើ ចាស /បាទ សួរបន្ត**

        ក. តើញឹកញាប់ប៉ុណ្ណាដែរ? .........................................................................................
        ខ. តើពេលចុងក្រោយបំផុតដែលប្អូនត្រូវបានគេប្រាប់នៅពេលណា? ..................................................
        គ. ដោយអ្នកណា? ..........................................................................................................
        ឃ. តើគេបានបង្រៀនអ្វីខ្លះដល់ប្អូនអំពីសុវត្ថិភាពនិងការការពារ......................................................

..........................................................................................................................................

..........................................................................................................................................

41. តើប្អូនមានពាក់បរិក្ខារការពារខាងក្រោម ក្នុងកំឡុងពេលធ្វើការដែលរឺទេ ហើយញឹកញាប់ប៉ុណ្ណា?

| | | ជានិច្ច | ញឹកញាប់ | ពេលខ្លះ | មិនដែល | ប្រសិនបើមិនដែល,ពន្យល់ហេតុអ្វី? |
|---|---|---|---|---|---|---|
| ១ | ពាក់ស្រោមដៃ | [] | [] | [] | [] | ............................................... |
| ២ | ពាក់ម៉ាស់ការពារ | [] | [] | [] | [] | ............................................... |
| ៣ | ពាក់មួកការពារគ្រោះថ្នាក់ | [] | [] | [] | [] | ............................................... |
| ៤ | ពាក់មួកការពារកំដៅ | [] | [] | [] | [] | ............................................... |
| ៥ | ពាក់ស្បែកជើងការងារ | [] | [] | [] | [] | ............................................... |
| ៦ | វ៉ែនតាការពារ | [] | [] | [] | [] | ............................................... |

42. តើប្រយោគនិមួយៗខាងក្រោមនេះ ត្រូវរឺខុស តាមការយល់ដឹងរបស់ប្អូន អំពីកន្លែងធ្វើការរបស់ប្អូន?

| | | |
|---|---|---|
| ១. កន្លែងធ្វើការរបស់ខ្ញុំមានសម្ភារៈពេទ្យសំរាប់សង្គ្រោះភ្លាមៗ | ១,ខុស | ២, ត្រូវ |
| ២. កន្លែងធ្វើការរបស់ខ្ញុំពិតជាក្តៅណាស់ | ១,ខុស | ២, ត្រូវ |
| ៣. ខ្ញុំតែងតែធ្វើការក្រោមកំដៅថ្ងៃ | ១,ខុស | ២, ត្រូវ |
| ៤. ខ្ញុំលើក រឺលីដឹ ឥដ្ឋ រឺរបស់ធ្ងន់ៗជាប្រចាំ | ១,ខុស | ២, ត្រូវ |
| ៥. មានធូលីដី រឺផេះហុយជាច្រើន ពេលខ្យល់បក់ម្តងៗ | ១,ខុស | ២, ត្រូវ |
| ៦. ឥដ្ឋអាចធ្លាក់លើខ្ញុំគ្រប់ពេល | ១,ខុស | ២, ត្រូវ |
| ៧. គេអនុញ្ញាតិ អោយខ្ញុំបញ្ជាម៉ាស៊ីនធ្វើឥដ្ឋ | ១,ខុស | ២, ត្រូវ |
| ៨. ខ្ញុំធ្វើការច្រើនម៉ោងណាស់ក្នុងមួយថ្ងៃ | ១,ខុស | ២, ត្រូវ |
| ៩. កន្លែងធ្វើការរបស់ខ្ញុំមានអនាម័យល្អ | ១,ខុស | ២, ត្រូវ |
| ១០. កន្លែងធ្វើការរបស់ខ្ញុំពុំមានសុវត្ថិភាពសំរាប់កុមារដែលរស់នៅទីនេះ | ១,ខុស | ២, ត្រូវ |
| ១១. ខ្ញុំមិនមានពេលសំរាកទាល់តែសោះ កំឡុងម៉ោងធ្វើការងារ | ១,ខុស | ២, ត្រូវ |
| ១២. ការងាររបស់ខ្ញុំគឺ វាធ្ងន់ណាស់សំរាប់ខ្ញុំ | ១,ខុស | ២, ត្រូវ |
| ១៣. ការងាររបស់ ខ្ញុំ ពុំបង្កគ្រោះថ្នាក់ដល់សុខភាពខ្ញុំទេ | ១,ខុស | ២, ត្រូវ |

43. តាំងពីប្អូនធ្វើការនៅទីនេះ តើប្អូនធ្លាប់ឃើញកុមារដទៃទៀតដែលធ្វើការងារនៅទីនេះ មានជំងឺនៅពេលធ្វើការដែររឺទេ ?

១. ទេ

២. ចាស/បាទ ចំនួនប៉ុន្មាននាក់? ..........................

តើពួកគេមានជំងឺដោយរបៀបណា? (**សួរមូលហេតុដែលសំខាន់ៗ**)

